សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

## លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា (២០១៣ - ២០១៨)

ស្រាវជ្រាវចាប់ពីថ្ងៃទី ០២ ខែ មេសា ថ្ងៃទី ៣១ ឆ្នាំ២០១៨ ដល់ខែ ឧសភា ឆ្នាំ២០១៨


តាក់តែងឡើងដោយ

និស្សិតឈ្មោះ ឈឹម វ៉ាន់ឌី

ជុំ ករុណា

លោកសាស្ត្រាចារ្យណែនាំ

បណ្ឌិត ឈុន ណាវ៉េត


ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ

ជំនាន់ទី ១៨

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០១៨

# សេចក្តីថ្លែងអំណរគុណ

ក្នុងនាមយើងខ្ញុំ ជានិស្សិតដែលបានឆ្លងកាត់ការសិក្សាអស់រយៈពេលបួនឆ្នាំនៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

**<u>សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ</u>**

- អ្នកមានគុណទាំងទ្វេ ដែលលោកបាននាំខ្ញុំមកពិភពមួយនេះ ហើយបានបង្រៀនខ្ញុំឲ្យស្គាល់អត្ថន័យនៃជីវិត រយលានរស់ជាតិដែលបង្កប់ទៅដោយការប្រកួតប្រជែង ភាពសប្បាយរីករាយ និងការឈឺចាប់។
- លោកគ្រូ អ្នកគ្រូ លោក - លោកស្រី សាស្ត្រាចារ្យទាំងអស់នៅលើសកលលោកដែលបានធ្វើការបណ្តុះបណ្តាលមនុស្សឲ្យមាន ចំណេះដឹង គុណធម៌ និងសច្ចធម៌។
- លោក - លោកស្រី សាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច លោកបានបង្រៀនខ្ញុំឲ្យ រឹងមាំ ស្គាល់ច្បាស់ពីសង្គម និងផ្លាស់ប្តូរផ្នត់គំនិតប្រកបដោយការពិចារណា។
- លោកសាស្ត្រាចារ្យ ឈុន ណារ៉េត ដែលបានធ្វើជាគ្រូណែនាំយើងខ្ញុំ លោកបានផ្តល់គំនិតយោបលល្អៗប្រកបដោយគតិបណ្ឌិតដែលជាតម្រុយមួយ រហូតដល់យើងខ្ញុំអាចបញ្ចប់ការសរសេរសារណាមួយនេះដោយមានទំនុកចិត្តជាទីបំផុត។

# ឧទ្ទិសស្នាដៃ

សូមឧទ្ទិសស្នាដៃប្រកបដោយចិត្តស្មោះអស់ពីបេះដូងជូនចំពោះ វីរៈជនស្នេហាជាតិ ស្នេហាប្រជាធិបតេយ្យទាំងអស់ដែលបានបូជាសាច់ស្រស់ ឈាមស្រស់ ដើម្បីបុព្វហេតុជាតិមាតុភូមិ និងបានទាមទារនូវបុព្វសិទ្ធិរបស់មនុស្សជាបន្តបន្ទាប់ពីមួយជំនាន់ទៅមួយជំនាន់ឲ្យរួចផុតនូវ ការរំលោភបំពានពីសំណាក់អ្នកនយោបាយដែលក្តោបក្តាប់អំណាចដោយភ្លេចគិតថា ប្រទេសជាតិមិនមែនជារបស់ពួកគេនោះទេ ផ្ទុយទៅវិញវាគឺជារបស់ប្រជាពលរដ្ឋដែលជាម្ចាស់ប្រទេស។ បើទោះបីជាប្រជាធិតេយ្យមិនទាន់បានសាបព្រោះឲ្យមានលក្ខណៈពេញលេញក៏ដោយ ក្នុងនាមខ្ញុំជាយុវជនជំនាន់ក្រោយ ខ្ញុំនឹងបន្តនូវកាតព្វកិច្ចមួយនេះ ហើយត្រៀមខ្លួន ត្រៀមចិត្ត ត្រៀមលោហិតរួចជាស្រេចដើម្បីធ្វើការផ្សព្វផ្សាយលទ្ធិមួយនេះ និងធ្វើឲ្យប្រជាពលរដ្ឋក្លាយជាម្ចាស់ប្រទេសយ៉ាងពិតប្រាកដ។

# អារម្ភកថា

យើងខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយណាស់ ដែលមានឱកាសបានបង្ហាញ នូវសមត្ថភាព និងការយល់ដឹងពាក់ព័ន្ធទៅនឹងលទ្ធិប្រជាធិបតេយ្យតាមរយៈការធ្វើសារណា និងធ្វើការការពារបកស្រាយបង្ហាញ ដើម្បីទទួលបានភាពជោគជ័យក្នុងការបញ្ចប់ថ្នាក់បរិញ្ញាបត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ មូលហេតុធ្វើឲ្យក្រុមយើងខ្ញុំជ្រើសរើសយកប្រធានបទ“**លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ២០១៣-២០១៨**”ពីព្រោះយើងខ្ញុំយល់ថាវាគឺជាចំណុចរសើបមួយ ដែលប្រជាពលរដ្ឋកម្ពុជាកំពុងតែយកចិត្តទុកដាក់ និងមានភាពចម្រូងចម្រាសយ៉ាងក្តៅគគុក។ តាមរយៈសារណានេះយើងខ្ញុំសង្ឃឹមថាវាអាចជាស្ពាន ឬជាប្រទីបមួយសម្រាប់ឲ្យប្រជាពលរដ្ឋយល់ដឹងកាន់តែច្បាស់ថា តើអ្វីទៅដែលហៅថាប្រជាធិបតេយ្យ? ប្រជាធិបតេយ្យពិតប្រាកដជាអ្វី? ហើយសព្វថ្ងៃប្រទេសកម្ពុជាយើងមានប្រជាធិបតេយ្យដែរឬទេ? តើអ្នកណាជាម្ចាស់ប្រទេសមួយនេះពិតប្រាកដ? ដើម្បីកុំឲ្យ ប្រជាពលរដ្ឋជឿជាក់ទៅលើអ្នកនយោបាលមួយចំនួនដែលបានប្រើកលល្បិច បោកប្រាស់ប្រជាពលរដ្ឋ ដើម្បីតែសន្លឹកឆ្នោត និងអំណាចរបស់ខ្លួនតែប៉ុណ្ណោះ។ ពួកគេគឺជាមេរោគមួយយ៉ាងសាហាវក្នុងការបំផ្លាញលទ្ធិប្រជាធិតេយ្យនៅកម្ពុជាដោយពួកគេមិនបានយកចិត្តស្មោះ សេចក្តីស្រឡាញ់ គុណធម៌ និងសច្ចធម៌មកធ្វើនយោបាយនោះទេ ផ្ទុយទៅវិញពួកគេប្រើតែកលល្បិច ការភូតកុហកថែមទាំងសន្យានូវអ្វីដែលពួកគេធ្វើមិនបាន។ លទ្ធិប្រជាធិបតេយ្យអាចរីកចម្រើនទៅបាន លុះត្រាតែប្រជាពលរដ្ឋមានចំណេះដឹង និងយល់ដឹងថាប្រជាធិតេយ្យគឺជាអ្វីពិតប្រកដ?ព្រមទាំងចូលរួមក្នុងការអនុវត្តន៍គ្រប់ៗគ្នាពេលនោះហើយយើងនឹងទទួលបានលទ្ធិប្រជាធិបតេយ្យមួយយ៉ាងពិតប្រាកដ។

យើងខ្ញុំសុំអភ័យទោសទុកជាមុននូវរាល់កំហុសឆ្គងទាំងឡាយដោយអចេតនា ដែលកើតចេញពីការអត្ថាធិប្បាយ ទាំងអត្ថន័យ និងពាក្យពេចន៍អក្ខរាវិរុទ្ធជាដើម។ ហើយយើងខ្ញុំសូមទទួលយកនូវរាល់មតិរិះគន់ក្នុងន័យស្ថាបនាទាំងឡាយ និងយល់ព្រមកែសម្រួលអត្ថបទមួយនេះឲ្យមានភាពត្រឹមត្រូវល្អប្រសើរជាងនេះ ដើម្បីរក្សាទុកជាឯកសារគ្រឹះមួយសម្រាប់សិស្សនិស្សិតជំនាន់ក្រោយយកទៅសិក្សាស្រាវជ្រាវបន្ថែម។

# មាតិកា

ទំព័រ


សេចក្តីផ្តើម ............................................................................................................ 1

ជំពូកទី១: ទ្រឹស្តីនៃលទ្ធិប្រជាធិបតេយ្យ ............................................................................. 3

១. អ្វីទៅដែលហៅថាប្រជាធិបតេយ្យ .................................................................................3

២. ការកកើតនៃលទ្ធិប្រជាធិបតេយ្យលើពិភពលោក ...........................................................4

៣. ទ្រឹស្តីលទ្ធិប្រជាធិបតេយ្យ ..........................................................................................6

៤. ទ្រឹស្តី លោក ណុប បូផាន់ ........................................................................................ 12

៤.១. សេរីភាព.................................................................................................. 13

៤.២. សមភាព................................................................................................... 14

៤.៣. យុត្តិធម៌ ................................................................................................. 18

៥. រដ្ឋធម្មនុញ្ញប្រជាធិបតេយ្យ..........................................................................................20

៥.១. ការយកអំណាចទៅនៃកនេរលើអំណាច............................................................20

៥.២. ការបែងចែកអំណាច.......................................................................................21

៥.៣. ការនៃកនេរនិងថ្លឹងថ្លែង.....................................................................................21

ជំពូកទី២ : លទ្ធិប្រជាធិបតេយ្យ នៅកម្ពុជា ២០១៣-២០១៨ ............................. 24

១. ប្រវត្តិលទ្ធិប្រជាធិបតេយ្យ នៅកម្ពុជា .........................................................................24

២. ដំណើរការនយោបាយ ...............................................................................................29

៣. ការបោះឆ្នោត និងគណកម្មការជាតិរៀបចំការបោះឆ្នោត.........................................33

៤. ប្រព័ន្ធឃោសនា និងផ្សព្វផ្សាយព័ត៌មាន.....................................................................35

៥. ទំនាក់ទំនងវប្បធម៌ និងលទ្ធិប្រជាធិបតេយ្យ ........................................36

៦. ដំណើរការសេដ្ឋកិច្ច ........................................37

៧. ការកសាងក្របខ័ណ្ឌច្បាប់ ........................................38

៨. តួអង្គសំខាន់ៗក្នុងការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ........................................41

៨.១. គណបក្សនយោបាយសេរីពហុបក្ស........................................41

៨.២. អង្គការសង្គមស៊ីវិល ........................................42

៨.៣. ប្រជាពលរដ្ឋ ........................................44

ជំពូកទី៣ : ភាពខ្លាំង និងភាពខ្សោយក្នុងការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ .... 47

១. ភាពខ្លាំងរបស់គណបក្សនយោបាយសេរីពហុបក្ស........................................47

២. ភាពខ្លាំងរបស់ស្ថាប័នទាំងបី ........................................48

២.១. ស្ថាប័ននីតិប្បញ្ញត្តិ........................................48

២.២. ស្ថាប័ននីតិប្រតិបត្តិ ........................................50

២.៣. ស្ថាប័នតុលាការ ........................................52

៣. ភាពខ្លាំងរបស់អង្គការក្រៅរដ្ឋាភិបាល ឬសង្គមស៊ីវិល ........................................53

៤. ភាពខ្លាំងប្រជាពលរដ្ឋ........................................53

៥. ភាពខ្សោយគណបក្សនយោបាយសេរីពហុបក្ស ........................................54

៦. ភាពខ្សោយរបស់ស្ថាប័នទាំងបី ........................................55

៦.១. នីតិប្បញ្ញត្តិ........................................55

៦.២. នីតិប្រតិបត្តិ........................................57

៦.៣. តុលាការ........................................57

៧. ភាពខ្សោយរបស់អង្គការក្រៅរដ្ឋាភិបាល ឬសង្គមស៊ីវិល ........................................59

៨. ប្រជាពលរដ្ឋ........................................60

**សេចក្តីសន្និដ្ឋាន** .......................................................................................................... 62

**អនុសាសន៍** .......................................................................................................................... 64

**ឯកសារយោង**

# សេចក្តីផ្តើម

នៅលើសកលលោកយើងនេះ គ្រប់ប្រទេសទាំងអស់មិនថារដ្ឋនោះមានបូរណភាពដែនដីតូចក្តី ធំក្តី ឬប្រជាជនតិចក្តី ច្រើនក្តី ចាំបាច់ត្រូវមានរបបនយោបាយមួយដើម្បីគ្រប់គ្រង និងដំណើរការនៃការប្រព្រឹត្តទៅរបស់រដ្ឋនោះប្រកបដោយប្រសិទ្ធិភាព។

ជាការពិតណាស់ប្រទេសមួយដែលមានភាពរីកចម្រើនកាន់តែខ្លាំង នោះក៏ដោយសារតែមានរបបនយោបាយ និងអ្នកដឹកនាំល្អដែរ។ យ៉ាងណាមិញរបបនយោបាយទាំងនោះមានលក្ខណៈខុសផ្លែកពីគ្នាទៅតាមផ្នត់គំនិត បរិបទ និងមនោគមន៍វិជ្ជារបស់ប្រទេសទាំងនោះ។ ជាក់ស្តែងប្រទេសកម្ពុជាយើងក៏មានរបបដឹកនាំមួយដែរ។ កន្លងមកប្រទេសកម្ពុជាយើងធ្លាប់បានឆ្លងកាត់នូវរបបដឹកនាំជាច្រើន ហើយរបបដឹកនាំទាំងនោះខុសៗប្លែកពីគ្នាទៅតាមសម័យកាលនីមួយៗ រហូតមកដល់បច្ចុប្បន្ននេះកម្ពុជាបានប្រកាន់ភ្ជាប់នូវរបបប្រជាធិបតេយ្យសេរីពហុបក្សដែលជារបបមួយត្រូវបានពិភពលោកទទួលស្គាល់។ គួររំលឹកផងដែរថា លទ្ធិប្រជាធិបតេយ្យមានដើមកំនើតនៅកម្ពុជា ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៤៧ នាំចូលដោយព្រះបាទស៊ីសុវត្ថិយុតវង្សហើយយកមកអនុវត្តនៅកម្ពុជានៅឆ្នាំ១៩៤៩ ក្នុងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។ លទ្ធិប្រជាធិបតេយ្យពិតមានសារៈសំខាន់ចំពោះប្រជាពលរដ្ឋក្នុងការកសាង និងការពារប្រទេសជាតិ។ ប្រជាពលរដ្ឋអាចជ្រើសរើស និងផ្លាស់ប្តូរអ្នកដឹកនាំតាមឆន្ទៈរបស់ខ្លួនដោយសន្តិវិធីមានសន្តិភាពសន្តិសុខ ស្ថិរភាពពិតប្រាកដ។ ប្រជាពលរដ្ឋមានសិទ្ធិសេរីភាពទូលំទូលាយជម្រុញអភិបាលកិច្ចល្អ ឬមានតម្លាភាព និងអាចទប់ស្កាត់អំពើពុករលួយបាន។ និយាយរួមទៅ លទ្ធិប្រជាធិបតេយ្យមានសារៈសំខាន់ច្រើនណាស់ ដោយបានផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋពេញបរិបូរណ៍ ក្នុងការការពារដល់ប្រយោជន៍របស់ខ្លួន ហើយរដ្ឋាភិបាលត្រូវធ្វើអ្វីៗដើម្បីរាស្ត្រ ដើម្បីជាតិ។ នៅថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩១ មានកិច្ចព្រមព្រៀមទីក្រុងបារីស ស្តីពីអំពីបញ្ហាបញ្ចប់ជម្លោះនៅកម្ពុជាដែលអូសបន្លាយអស់ជាងពីរទសវត្សរ៍។ ក្រោយពីព្រឹត្តិការណ៍នោះ កម្ពុជាបានបង្កើតរដ្ឋាភិបាលថ្មីមួយ ក្រោមបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ ដោយប្រកាន់យករបបប្រជាធិបតេយ្យសេរីពហុបក្ស តាមមាត្រា៥១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា។ កិច្ចព្រមព្រៀមនេះបានធ្វើឲ្យកម្ពុជាមានការទទួលស្វាគមន៍ ពីមជ្ឍដ្ឋានជាតិ និងអន្តរជាតិ ព្រមទាំងទទួលបានជំនួយ

យ៉ាងច្រើនសន្ធឹកសន្ធាប់។ ច្បាប់រដ្ឋធម្មនុញ្ញថ្មីនាឆ្នាំ១៩៩៣ ដែលជាច្បាប់កំពូលរបស់ជាតិបាន ចាត់ទុកថាប្រជាពលរដ្ឋគឺជាម្ចាស់វាសនាប្រទេសជាតិ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋអាចប្រើអំណាចតាមរយៈ រាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា និងសាលាជម្រះក្តី។ តែទោះជាយ៉ាងនេះក៏ដោយ នៅក្នុងអាណត្តិទី៥ ឆ្នាំ២០១៣-២០១៨ នេះ ប្រជាពលរដ្ឋកម្ពុជាមាន ការក្រោកឈរយ៉ាងខ្លាំងក្នុងការតវ៉ាជាមួយនឹងរដ្ឋាភិបាល ដោយពួគេយល់ឃើញថា កម្ពុជា កំពុងតែលុបបំបាត់របបប្រជាធិបតេយ្យដែលបានចងក្រងដោយរដ្ឋធម្មនុញ្ញ១៩៩៣ ជាច្បាប់ កំពូលរបស់ជាតិ។ ជាពិសេសនៅក្នុង ឆ្នាំ២០១៧ តុលាការកំពូលបានចាប់មេដឹកនាំគណបក្សស ង្គ្រោះជាតិដោយបានចោទប្រកាន់ថា បានរួមគំនិតជាមួយអន្តរជាតិដើម្បីផ្តួលរម្លំរដ្ឋាភិបាលស្រប ច្បាប់ និងបានរម្លាយគណបក្សសង្គ្រោះ ដោយយោងទៅតាមច្បាប់ស្តីពីគណបក្សនយោបាយ ទើបតែវិសោធនកម្មថ្មី។ បើទោះបីប្រជាពលរដ្ឋមួយចំនួនមានការមិនពេញចិត្តពីទង្វើដែលធ្វើឲ្យ ថយចុះនៃលទ្ធិប្រជាធិបតេយ្យនេះក៏ដោយ ក៏នៅមានប្រជាពលរដ្ឋមួយចំនួនទៀតរស់នៅក្នុង ប្រទេសកម្ពុជាដែលបានគាំទ្រនូវគោលជំហររបស់រាជរដ្ឋាភិបាលក្នុងនោះ ក៏មាន សហគមន៍អន្តរ ជាតិផងដែរ គឺមហាមិត្តចិន ដែលជាប្រទេសមហាអំណាចមួយក្នុងចំណោមប្រទេសមហាអំណាច នៅលើពិភពលោក។ ដោយកម្ពុជាមានបញ្ហាជាច្រើនអំពីលទ្ធិប្រជាធិបតេយ្យយ៉ាងនេះ ក្រុមយើង ខ្ញុំក៏ខិតខំស្វែងរកឯកសារពាក់ព័ន្ធជាច្រើនមានទាំងសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀង ច្បាប់ ប្រកាសរបស់ក្រសួងពាក់ព័ន្ធ សៀវភៅដែលចងក្រងឡើងដោយសាស្ត្រាចារ្យល្បីៗ និងសារណា ជាដើម។ ដើម្បីយកមកចងក្រងពន្លិចឲ្យឃើញច្បាស់ថា តើអ្វីទៅដែលហៅថាប្រជាធិបតេយ្យ? តើការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យនៅកម្ពុជាមានកម្រិតណា? ចំណោទបញ្ហាទាំងនេះ ទាមទារនូវ ដំណោះស្រាយ ហើយអត្ថបទសារណានេះគឺជាកូនសោសម្រាប់ដោះស្រាយបញ្ហាខាងលើ។ គោលបំណងរបស់ក្រុមយើងខ្ញុំក្នុងការជ្រើសរើសយកប្រធានបទនេះមកសរសេរគឺ ដើម្បីចូលរួម ចងក្រងព្រឹត្តការណ៍ផ្សេងៗដែលពាក់ព័ន្ធនឹងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា និងផ្តល់ចំណេះដឹង ទូទៅផ្នែកវិទ្យាសាស្ត្រនយោបាយ ហើយក៏ជាប្រធានបទមួយដ៏ក្តៅគគុកក្នុងសង្គមបច្ចុប្បន្ននេះ ដែរ។ នៅក្នុងសារណានេះក្រុមយើងបានចែកជា៣ជំពូក គឺ៖

- ✓ **ជំពូកទី១ : ទ្រឹស្តីនៃលទ្ធិប្រជាធិបតេយ្យ**
- ✓ **ជំពូកទី២ : លទ្ធិប្រជាធិបតេយ្យ នៅកម្ពុជា២០១៣-២០១៨**
- ✓ **ជំពូកទី៣ : ភាពខ្លាំង និងភាពខ្សោយក្នុងការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ**

# ជំពូកទី១: ទ្រឹស្តីនៃលទ្ធិប្រជាធិបតេយ្យ

## ១. អ្វីទៅដែលហៅថាប្រជាធិបតេយ្យ

តាមការបកស្រាយរបស់ទស្សនវិទូជនជាតិក្រិចឈ្មោះ អារីសស្តូល (Aristotle) កាលពីជំនាន់ប្រមាណ៣០០ឆ្នាំមុនគ្រឹស្តសករាជបានបង្ហាញថាលទ្ធិប្រជាធិបតេយ្យ (Democracy) គឺជាការគ្រប់គ្រងដោយប្រជាពលរដ្ឋ។ ពាក្យប្រជាធិបតេយ្យគឺជាការរួមផ្គុំរបស់ពាក្យ ប្រជាពលរដ្ឋ (demos) និងពាក្យ អធិបតេយ្យ (Kratis )។ អំណាចគ្រប់គ្រងដោយប្រជាពលរដ្ឋ ជាអំណាចសាធារណៈ។ អំណាចនេះមានលក្ខណៈផ្ទុយគ្នាពីអំណាចគ្រប់គ្រងទៅដោយមនុស្សមួយក្រុម (oligarchy) អំណាចគ្រប់គ្រងដោយមនុស្សម្នាក់ (autocracy) និង អំណាចគ្រប់គ្រងដោយស្តេច (monarchy)។[1]

លោក អាំប្រាហាំ លីងកូល (Abraham Lincoln ) អតីតប្រធានាធិបតីទី១៦របស់សហរដ្ឋអាមេរិកគាត់ធ្លាប់មានប្រសាសន៍ថា លទ្ធិប្រជាធិបតេយ្យ គឺជារដ្ឋាភិបាលមួយដែលជារបស់ប្រជាពលរដ្ឋ កើតឡើងដោយប្រជាពលរដ្ឋហើយសម្រាប់បម្រើប្រជាពលរដ្ឋ។[2]

លោកដៃយ៉ាន រ៉ាវិច (Daine Ravich) សរសេរថា ប្រជាធិបតេយ្យ គឺជាដំណើរការ របៀបរស់នៅ និង ធ្វើការជាមួយគ្នា។ ប្រជាធិបតេយ្យវាតែងតែវិវត្ត វាមិននៅនឹងមួយន្លែងទេ។ ប្រជាធិបតេយ្យទាមទារឲ្យមានកិច្ចសហប្រតិបត្តិការ ភាពចេះសម្រុះសម្រួលគ្នា និងការអត់អោនឲ្យគ្នានៅក្នុងចំណោមប្រជាពលរដ្ឋទាំងអស់។ ដើម្បីធ្វើឲ្យប្រជាធិបតេយ្យដំណើរការវាជាការលំបាកណាស់វាមិនមែនជាការងាយស្រួលទេ ។[3]

លោក ម៉ុងតេសស្គី (Montesquieux)អ្នកនិពន្ធជាតិបារាំង (១៦៨៩-១៧៥៥) បានសរសេរថា ប្រជាធិបតេយ្យ គឺសំដៅទៅលើប្រជាជនដែលមានអធិបតេយ្យភាពដ៏ខ្លាំងក្លាមួយ ត្រូវធ្វើដោយខ្លួនឯងនូវអ្វីដែលខ្លួនអាចធ្វើបាន ហើយអ្វីដែលខ្លួនមិនអាចធ្វើ ត្រូវឲ្យរដ្ឋមន្ត្រីរបស់ខ្លួនជាអ្នកធ្វើ(Le peuple qui a la souveraine puissance doit faire par lui meme tout ce qu il peut Le

[1] ការ ដេវីដ សៀវភៅគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីនិយម.រដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក.ឆ្នាំ១៩៩៦. ទំព័រទី១៣

[2] ក្រសួងឃោសនាសហរដ្ឋអាមេរិក.អ្វីទៅដែលហៅថាលទ្ធិប្រជាធិបតេយ្យ.ទីក្រុងវ៉ាស៊ិនតោន ឌីស៊ី. ឆ្នាំ១៩៩១.ទំព័រទី៤

[3] ក្រសួងឃោសនាសហរដ្ឋអាមេរិក.អ្វីទៅដែលហៅថាលទ្ធិប្រជាធិបតេយ្យ.ទីក្រុងវ៉ាស៊ិនតោនឌីស៊ី.ឆ្នាំ១៩៩១ទំព័រទី១១

reste il faut qu il le fasse par ses ministres )។[4] ហេតុដូចនេះហើយបានជាលោកប្រើពាក្យថា រដ្ឋាភិបាលរបស់ប្រជាជន កើតឡើងដោយសារប្រជាជន និងដើម្បីប្រជាជន មានន័យថារដ្ឋាភិបាល ត្រូវតែងតាំងដោយប្រជាជន ដើម្បីបម្រើផលប្រយោជន៍ ដូចនោះប្រជាជនមានសិទ្ធិរម្លាយ ឬ ទម្លាក់រដ្ឋាភិបាលនេះចេញ បើសិនមិនបម្រើផលប្រយោជន៍ប្រជាជន បានន័យថាប្រជាជនជា ម្ចាស់អំណាច។ ដូចនេះ យើងអាចឲ្យនិយមន័យរួមនៃ លទ្ធិប្រជាធិបតេយ្យ គឺជាដំណើរការដែល ប្រជាពលរដ្ឋជាធំជាម្ចាស់អំណាច ហើយអំណាចរបស់ពួកគេត្រូវបានប្រើតាមរយៈ តំណាងរបស់ ពួកគេ (តំណាងរាស្ត្រ) ធ្វើការចាត់ចែងរដ្ឋាភិបាល។ រីឯប្រជាពលរដ្ឋធ្វើការត្រួតពិនិត្យ និងតាម ដានរាល់សកម្មភាពរបស់រដ្ឋាភិបាល។ នៅត្រង់ចំណុចនេះមានន័យថា អ្នកតំណាងជាប់ឆ្នោត គឺ ជាខ្ញុំបម្រើរបស់ប្រជាពលរដ្ឋ ប្រសិនបើអ្នកតំណាងនោះធ្វើការមិនកើត ប្រជាពលរដ្ឋមានសិទ្ធិ អំណាច បញ្ឈប់នូវអំណាចរបស់អ្នកនោះបាន ឬក្រុមនោះក្នុងអាណត្តិមួយដែលកំណត់ដោយ ច្បាប់។ ក្នុងន័យនេះ ប្រជាធិបតេយ្យប្រកាន់ខ្ជាប់នូវសិទ្ធិសេរីភាព ច្បាប់ និងរបកគំហើញថ្មីៗដើម្បី អភិវឌ្ឍប្រទេស ។

## ២. ការកកើតនៃលទ្ធិប្រជាធិបតេយ្យលើពិភពលោក

កាលពីសម័យបុព្វកាលប្រហែល ៥០០០ឆ្នាំ មុនគ្រឹស្តសករាជដល់ ៣២០០ឆ្នាំ មុនគ្រឹស្ត សករាជ ពេលនោះមនុស្សរស់នៅបែបជាកុលសម្ព័ន្ធដោយមាន មេកន្ទ្រាញជាអ្នកគ្រប់គ្រងដឹកនាំ ហើយរស់នៅជាក្រុមៗ ដោយចេះបែងចែកចំណីអាហារគ្នាបរិភោគ ព្រមទាំងចេះបែងចែកការងារ គ្នាធ្វើ ចេះរួបរួមកម្លាំងគ្នាប្រឆាំងនឹងសត្វសាហាវ ចេះទប់ទល់នឹងបាតុភូតធម្មជាតិ។ សម័យកាល នោះហៅថាសម័យបុព្វកាល។ ជាពិសេសសម័យនោះប្រជាពលរដ្ឋចូលចិត្តធ្វើចំណាក់ស្រុក ណាស់ដែលជាហេតុធ្វើឲ្យពួកគេមិនរវល់ទៅនឹង កម្មសិទ្ធិឯកជន ការកេងប្រវ័ញ្ច និង ដណ្តើម អំណាចគ្នាឡើយ។ តែក្រោយមកដោយសារមានការវិវត្តន៍ទាំងគំនិត និងប្រាជ្ញា ពួកគេចេះកែច្នៃ ធម្មជាតិយកមកប្រើប្រាស់ ហើយមនុស្សក៏លែងពឹងផ្អែកលើធម្មជាតិទៀតហើយ។ ដោយម្នាក់ៗ ខិតខំដាំដំណាំ ចិញ្ចឹមសត្វ និងធ្វើឧបករណ៍សម្ភារៈផ្សេងៗហើយលែងផ្លាស់ប្តូរទីលំនៅដូចមុន ទៀតហើយ។ បញ្ហានេះបានធ្វើឲ្យសង្គមមានការប្រែមុខមាត់ ថ្មីមួយទៀត។ ចំណែកផលដែលនៅ សល់ពីសេចក្តីត្រូវការ ពួកគេទុកសម្រាប់ដោះដូរយករបស់ផ្សេងៗ ហើយការដោះដូរនេះ ភាគច្រើនគឺកើតចំពោះអ្នកប្រាជ្ញាវាងវៃ។ ចាប់តាំងពីពេលនោះមកពួកគេម្នាក់ៗអាចរស់នៅ

[4] អ៊ឹង ជុនហួរ.សេរីភាព និងយុត្តិធម៌.ឆ្នាំ១៩៩៥.ទំព័រទី១៥

ដោយខ្លួនឯង ដោយមិនចាំបាច់ពឹងពាក់លើកម្លាំង ឬក្រុមមួយទៀតឡើយ។ កម្មសិទ្ធិមានទ្រព្យផ្ទាល់ខ្លួនក៏ចាប់គំនិតប្រមូលទ្រព្យឲ្យបានច្រើនចេះតែកើនឡើង ហើយការលោភលន់កាន់តែខ្លាំងទៅៗ ដែលជាហេតុធ្វើឲ្យពួកអ្នកមានត្រូវការមនុស្សឲ្យមកធ្វើការឲ្យខ្លួន។ ដោយសារតែការវិវត្តន៍នៃកម្មសិទ្ធិឯកជននេះ បានធ្វើឲ្យកើតមានម្ចាស់បំណុល និងកូនបំណុល ដែលជាហេតុបង្កឲ្យកើតមានឡើងនូវសង្គ្រាមរវាងកុលសម្ព័ន្ធ និងកុលសម្ព័ន្ធដើម្បីដណ្តើមទឹកដី និងមនុស្សឲ្យមកធ្វើជាខ្ញុំរបស់ភាគីម្ខាងៗ។ ឯការតស៊ូវណ្ណៈ ដែលត្រូវគេជិះជាន់កើតមានឡើង ដើម្បីទាមទារសិទ្ធិ និងសេរីភាព ជាហេតុធ្វើឲ្យកើតមានសង្គ្រាមកើតឡើងជាបន្តបន្ទាប់ ដូចជាសង្គ្រាមលោកលើកទី១ នៅប្រទេសរ៉ូម៉ាំងក្នុង ឆ្នាំ១៣៥ មុនគ្រឹស្តសករាជសង្គ្រាមលើកទី២ក្នុង ឆ្នាំ១០៥ មុនគ្រឹស្តសករាជ និងលើកទី៣ នៅឆ្នាំ៧៣ នៃគ្រឹស្តសករាជ។ សង្គមទាសភាពនេះបានអូសបន្លាយមកដល់សតវត្សរ៍ទី១៩ ទើបចប់នៅរុស្ស៊ី ក្នុងរជ្ជកាលស្តេច នីកូឡាទី១ (១៨២៥-១៨៥៥) នៅប្រទេសតណ្ហា អាណានិគមអង់គ្លេសឆ្នាំ ១៨៣៣ បណ្តាប្រទេសអាណានិគមបារាំងឆ្នាំ ១៨៤៨ នៅសហរដ្ឋអាមេរិកឆ្នាំ ១៨៦៥ នៅប្រទេសប្រេស៊ីល ឆ្នាំ១៨៨៨ ។[5] តែទោះជាយ៉ាងណាក៏យើងមិនអាចភ្លេចបានអំពីប្រភពនៃលទ្ធិប្រជាធិបតេយ្យ ដំបូងគេបង្អស់ដែលបានកើតឡើងនៅប្រទេសក្រិចនាសម័យបុរាណ។ ដូចនេះហើយសូមលើកយកប្រវត្តិខ្លះៗនៃលទ្ធិប្រជាធិបតេយ្យនៅប្រទេសក្រិច ។ នៅក្នុងប្រវត្តិសាស្ត្រ ប្រជាធិតេយ្យបានចាប់កំណើតមុនដំបូងបង្អស់នៅប្រទេសក្រិចដោយទស្សនវិទូជាច្រើនរូបមានដូចជា លោកសូក្រាត ប្លាតុងជាដើម ។ កាលពីជំនាន់ដើមប្រជាពលរដ្ឋនៅទីក្រុងអាថែន (Athens) នៃប្រទេសក្រិច បានផ្លាស់ប្តូរវេនគ្នាតាក់តែងច្បាប់ទម្លាប់ ដើម្បីគ្រប់គ្រងស្រុកភូមិរបស់ខ្លួន។[6] លុះដល់ក្រោយមក ដោយហេតុចំនួនប្រជាពលរដ្ឋចេះតែកើនច្រើនឡើងៗ ការតែងច្បាប់ទម្លាប់ពុំអាចធ្វើគ្រប់គ្នាបានឡើយ។ ដូច្នេះគេចាំបាច់ជ្រើសរើស អ្នកដំណាងឲ្យទៅតាក់តែងច្បាប់ ជំនួស ដែលគេហៅថា ដំណាងពលរដ្ឋ និងជ្រើសរើសមនុស្សដ៏វាងវៃម្នាក់ទៀតឲ្យដឹកនាំសង្គមរបស់គេ ដែលត្រូវបានគេហៅថា ប្រធានាធិបតី។ ការគ្រប់គ្រងសង្គមរបៀបនេះ ទស្សនវិទូប៉្លេថូ (Plato) ដែលកើតនៅសតវត្សរ៍ទី៤មុនគ្រឹស្តសករាជបានឲ្យឈ្មោះថា របបគ្រប់គ្រងសាធារណៈ ឬរបបសាធារណរដ្ឋ The republic ។ ដូច្នេះរបបគ្រប់គ្រងសាធារណរដ្ឋនៅក្នុងលទ្ធិប្រជាធិបតេយ្យ មានន័យថាជាប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋាភិបាល ដែលនៅក្នុងនោះ

[5] អ៊ុំ សុភក្តិ.ហេង ឌី.អែល យុន. លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅកម្ពុជា.ឆ្នាំ២០០៦.ទំព័រទី៩

[6] ការ ដេវីដ សៀវភៅគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីនិយម. រដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក.ឆ្នាំ១៩៩៦.ទំព័រទី១៣

ក្រុមអង្គាធរដែលកាន់រដ្ឋអំណាចទាំងឡាយត្រូវគេជ្រើសរើសដោយការបោះឆ្នោត របៀបសេរី ដោយយុត្តិធម៌ និងអនុម័តតាមមតិភាគច្រើន។ ដើម្បីចៀសវាងការប្រើអំណាចរំលោភបំពានប្រជាពលរដ្ឋចាំបាច់ត្រូវតែកម្រិតព្រំដែនអំណាចគ្រប់គ្រងរបស់មេដឹកនាំ។ ទង្វើនេះអនុវត្តតាមរយៈរដ្ឋធម្មនុញ្ញដែលអនុញ្ញាតឲ្យមានការឆែកឆេរនិងថ្លឹងថ្លែង(checks and balances) ។ តម្លៃស្មើៗគ្នានេះជាកត្តាឲ្យគេមានសិទ្ធិសេរីភាពដូចៗគ្នា ។

## ៣. ទ្រឹស្តីលទ្ធិប្រជាធិបតេយ្យ

នៅលើពិភពលោកការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យមានលក្ខណៈផ្សេងៗពីគ្នា ទៅតាមបរិបទប្រទេសនីមួយៗហើយបរិយាកាសសេដ្ឋកិច្ច នយោបាយ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និងមនោគមន៍វិជ្ជា តែងតែមានភាពខុសគ្នាជាច្រើនពីទ្រឹស្តី។ មានមនុស្សជាច្រើនតែងតែយល់ឃើញខុសៗគ្នានូវពាក្យថាប្រជាធិបតេយ្យ ហើយក៏បានបង្កើតចងក្រងឯកសារទុកជាទ្រឹស្តី ជាគោលការណ៍ សម្រាប់ឲ្យមនុស្សធ្វើការស្វែងយល់។ ខាងក្រោយនេះជាទស្សនៈមួយចំនួនដែលពាក់ព័ន្ធទៅនឹងគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យះ

បើយោងតាមឯកសារ របស់គណៈកម្មាធិការ ដើម្បីការបោះឆ្នោតដោយសេរី និង យុត្តិធម៌នៅកម្ពុជាឆ្នាំ ២០០៣ បានលើកឡើងធាតុសំខាន់ៗរបស់ប្រជាធិបតេយ្យមានដូចជា សិទ្ធិជាមូលដ្ឋានដែលនៅក្នុងនោះមាន សិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិវប្បធម៌។ ប្រជាពលរដ្ឋមាន សេរីភាពសារព័ត៌មាន ផ្សព្វផ្សាយ ប្រជាពលរដ្ឋមានសិទ្ធិបង្កើត សារព័ត៌មាន ទូរទស្សន៍ វិទ្យុ មានសិទ្ធិទទួល និងផ្សព្វផ្សាយព័ត៌មាន សេរីភាពក្នុងការបង្កើតគណបក្សនយោបាយ និងសេរីភាពក្នុការជួបជុំ ការបោះឆ្នោតដោយសេរី យុត្តិធម៌ សម្ងាត់ ទៀងទាត់ ការផ្ទេរអំណាច គឺអ្នកចាញ់ផ្ទេរអំណាចឲ្យអ្នកឈ្នះដោយសន្តិវិធី ពហុនិយម និងការអធ្យាស្រ័យ ការសម្រេចអ្វីមួយដោយស្របតាមមតិភាគច្រើន ទំនាក់ទំនងរបស់អ្នកដឹកនាំ និងប្រជាពលរដ្ឋ គឺជាការបង្កើតច្បាប់ត្រូវមានការចូលរួមយោបលពីប្រជាពលរដ្ឋ និងយកទៅផ្សព្វផ្សាយឲ្យប្រជាពលរដ្ឋដឹងនឹងអនុវត្ត ។ នីតិរដ្ឋ គឺជារដ្ឋដែលដំណើរការតាមតែក្របខ័ណ្ឌច្បាប់ ហើយទាំងប្រជាពលរដ្ឋ ទាំងមន្ត្រីរាជការមានការយល់ពីច្បាប់បានល្អគ្រប់ៗគ្នា។[7]

[7] ខុមហ្វ្រែល.ជំនួយស្មារតីចំណោះដឹងពលរដ្ឋ ក្នុងអំឡុងពេលបោះឆ្នោត និងក្រោយពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ. ២០០៣.ទំព័រទី២

រីឯសៀវភៅមួយដែលមានឈ្មោះថាលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស ពលរដ្ឋវិជ្ជា ជាការរៀបចំឡើងដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សនៅកម្ពុជាបានរៀបរាប់យ៉ាងលម្អិតថា ប្រទេសដែលប្រកាន់នូវរបបប្រជាធិបតេយ្យពិតប្រាកដ យ៉ាងហោចណាស់ក៏ត្រូវអនុវត្តនូវគោលការណ៍សំខាន់ៗ ដូចខាងក្រោមនេះដែរះ

**១. ការគោរពសិទ្ធិមនុស្សះ** សិទ្ធិមនុស្ស គឺជាសេចក្ដីត្រូវការចាំបាច់របស់មនុស្សគ្រប់រូបដែលមានតាំងពីកំណើត ដើម្បីទាមទារនូវអ្វីៗដែលធ្វើឲ្យមនុស្សរស់នៅប្រកបដោយ គុណធម៌ និង សេចក្ដីថ្លៃថ្នូរ ។ ឧទាហរណ៍: សិទ្ធិក្នុងការនិយាយស្ដី (កើតមកស្រែកយំ) សិទ្ធិក្នុងការមើល (មានភ្នែកត្រូវបានឃើញ) សិទ្ធិក្នុងការស្ដាប់ (មានត្រចៀកត្រូវបានឮ) សិទ្ធិក្នុងការគិតពិចារណា (មានខួរក្បាលត្រូវចេះគិត)។ ដើម្បីឲ្យប្រជាពលរដ្ឋទទួលបាននូវផលប្រយោជន៍ពីសង្គម លុះត្រាណាតែប្រជាពលរដ្ឋមានអំណាច ដើម្បីឲ្យប្រជាពលរដ្ឋមានអំណាចលុះត្រាណាតែប្រជាពលរដ្ឋអាច និងហ៊ានប្រើប្រាស់សិទ្ធិរបស់ខ្លួនឲ្យបានទូលំទូលាយ។ ដូច្នេះសិទ្ធិជាប្រភពនៃអំណាច ហើយអំណាចរបស់ប្រជាពលរដ្ឋជាភាពរឹងមាំនៃលទ្ធិប្រជាធិបតេយ្យ។ ប្រទេសប្រជាធិបតេយ្យត្រូវមានច្បាប់ ដើម្បីធានាការពារសិទ្ធិប្រជាពលរដ្ឋ ហើយរដ្ឋាភិបាលត្រូវទទួលខុសត្រូវគោរពសិទ្ធិប្រជាពលរដ្ឋ ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ សិទ្ធិនាំមកនូវអំណាច អំណាចនាំមកនូវផលប្រយោជន៍។ សិទ្ធិសំខាន់ៗមាន: សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលនូវអាហារ និង ជំរកសមរម្យ សិទ្ធិទទួលនូវការអប់រំ សិទ្ធិទទួលបាននូវសេរីភាពខាងជំនឿ និងមនសិការផ្ទាល់ខ្លួន សេរីភាពក្នុងការបញ្ចេញមតិយោបល់ សិទ្ធិបង្កើត និងចូលរួមក្នុងសមាគមឬគណបក្សនយោបាយ សិទ្ធិបោះឆ្នោត និងឈរឈ្មោះឲ្យគេបោះឆ្នោត សិទ្ធិទទួលនូវសន្តិសុខផ្ទាល់ខ្លួន សិទ្ធិទទួលនូវការការពារខាងផ្លូវច្បាប់ សិទ្ធិស្មើភាពគ្នារវាងបុរស និងស្ត្រី។[8]

**២. ការចូលរួមពីប្រជាពលរដ្ឋះ** ប្រជាពលរដ្ឋនៅក្នុងប្រទេសប្រជាធិបតេយ្យ មិនត្រឹមតែបំពេញកាតព្វកិច្ចរបស់ខ្លួនជាប្រជាពលរដ្ឋប៉ុណ្ណោះទេ សំខាន់ជាងនេះទៅទៀតនោះគឺប្រជាពលរដ្ឋត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងសកម្មភាពផ្សេងៗ របស់សហាគមន៍ ឬរបស់ជាតិព្រមទាំងការតាក់តែងច្បាប់តាមការបញ្ចេញមតិយោបល់តាមរយៈ តំណាងរាស្ត្រ ឬតាមរយៈ សមាគមសហជីព បង្កើតជាអង្គការនានាក្នុងសង្គមស៊ីវិលដើម្បីបម្រើផលប្រយោជន៍ណាមួយរបស់ប្រជាពលរដ្ឋក្នុង សហាគមន៍របស់ខ្លួន។ នៅក្នុងប្រទេសមួយណាដែលប្រជាពលរដ្ឋធ្វើមិនដឹង មិនឮ

[8] គឹម សុខា. គៀត សុគន្ធ.លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងពលរដ្ឋវិជ្ជា.កម្ពុជា.ឆ្នាំ២០០៤.ទំព័រទី៩

បណ្តោយឲ្យអ្នកដឹកនាំធ្វើនូវអ្វីៗបានតាមអំពើចិត្ត ប្រទេសជាតិនោះមិនអាចរីកចម្រើនបានទេ ជាពិសេសប្រជាពលរដ្ឋនៅក្នុងប្រទេសនោះតែងតែមានភាពក្រីក្រទៀតផង។ ការចូលរួមពីប្រជាពលរដ្ឋគឺជាការផ្តល់ឱកាសឲ្យប្រជាពលរដ្ឋខ្លួនឯងគិតគូរ និងប្រាប់ទៅរដ្ឋាភិបាលថាត្រូវធ្វើអ្វីខ្លះដើម្បីបានផលប្រយោជន៍ទៅលើប្រជាពលរដ្ឋ និងធ្វើអ្វីខ្លះដែលប៉ះពាល់ដល់ផលប្រយោជន៍ប្រជាពលរដ្ឋ។ បើមានការចូលរួមពីប្រជាពលរដ្ឋកាន់តែច្រើន របបប្រជាធិបតេយ្យកាន់តែរឹងមាំ។[9]

៣. **ប្រព័ន្ធនយោបាយពហុបក្ស៖** គណបក្សនយោបាយ គឺជាក្រុមរបស់ប្រជាពលរដ្ឋក្នុងប្រទេសមួយដែលមានគំនិតនយោបាយដូចគ្នា ឬប្រហាក់ប្រហែលគ្នាបំផុតក្នុងការគិតគូររៀបចំ និងគ្រប់គ្រងប្រទេសនោះទៅតាមកម្មវិធី ឬបន្ទាត់នយោបាយដែលក្រុមពលរដ្ឋក្នុងគណបក្សនោះសម្រេចថា នឹងយកមកអនុវត្តនៅពេលដែលគណបក្សខ្លួនឈ្នះឆ្នោតកាន់អំណាចក្នុងរដ្ឋាភិបាល។ ដូចនេះហើយដើម្បីបើកឱកាសឲ្យក្រុមពលរដ្ឋដែលមានគោលនយោបាយផ្សេងៗគ្នាមានសេរីភាព និងមានឱកាសក្នុងការលើកយកគំនិត ឬគោលនយោបាយរបស់ខ្លួនមកដាក់ជូនប្រជាពលរដ្ឋទូទៅដើម្បីសម្រេចគាំទ្រ ឬមិនគាំទ្រ។ ក្នុងប្រទេសប្រជាធិបតេយ្យ គេត្រូវតែអនុញ្ញាតឲ្យមានគណបក្សច្រើនលើសពីមួយ។ គណបក្សច្រើន ឬពហុបក្ស គឺដើម្បីឲ្យប្រជាពលរដ្ឋមានជម្រើសមិនផ្តាច់មុខដែលជាកត្តាសំខាន់បំផុតឲ្យមេដឹកនាំនយោបាយ ឬគណបក្សនយោបាយទាំងឡាយខិតខំសម្រិតសម្រាំងខ្លួនឲ្យបានល្អប្រសើរ និងដើម្បីប្រលងប្រជែងគ្នាបង្ហាញស្នាដៃក្នុងការបម្រើប្រជាពលរដ្ឋ និង បម្រើប្រទេសជាតិ។ ផ្ទុយទៅវិញ បើគ្រាន់តែបើកឲ្យមានបក្សច្រើនហើយការជាក់ស្តែងអំណាចស្ថិតនៅលើតែបក្សមួយដដែល ក៏មិនពិតថាជាប្រទេសប្រជាធិបតេយ្យដែរ។ គណបក្សនយោបាយនីមួយៗនោះក៏ត្រូវមានប្រជាធិបតេយ្យក្នុងបក្សខ្លួនដែរ ពោលគឺគណបក្សជារបស់សមាជិកគណបក្សទាំងអស់គ្នា មិនមែនជាគណបក្សរបស់ប្រធានគណបក្សតែឯងឡើយ។ ប្រព័ន្ធនយោបាយពហុបក្សនាំមកនូវផលប្រយោជន៍កាន់តែច្រើន ជូនប្រជាពលរដ្ឋ។[10]

៤. **នីតិរដ្ឋ៖** នីតិរដ្ឋគឺជាការគ្រប់គ្រងនៃច្បាប់។ ប្រទេសមួយដែលគេហៅថានីតិរដ្ឋគឺជាប្រទេសមួយដែលមានច្បាប់ គោរពច្បាប់ និងអនុវត្តច្បាប់ដោយគតិយុត្តិធម៌។ ច្បាប់ដែលល្អគឺជាច្បាប់ដែលបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋ។ ដូច្នេះអ្នកធ្វើច្បាប់ត្រូវតែខំព្យាយាមធ្វើ

[9] គឹម សុខា.គៀត សុគន្ធ.លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងពលរដ្ឋវិជ្ជា.កម្ពុជា.ឆ្នាំ២០០៤.ទំព័រទី១០

[10] គឹម សុខា.គៀត សុគន្ធ.លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងពលរដ្ឋវិជ្ជា.កម្ពុជា.ឆ្នាំ២០០៤.ទំព័រទី១០-១១

ច្បាប់ហើយធ្វើយ៉ាងណាឲ្យស្របតាមឆន្ទៈរបស់ប្រជាពលរដ្ឋ។ ការគ្រប់គ្រងដែលប្រកបដោយនីតិរដ្ឋ គឺជាការគ្រប់គ្រងមួយដែលយកច្បាប់ជាធំ។ ការគ្រប់គ្រងនេះមានន័យថា បុគ្គលគ្រប់រូបទោះមានឋានៈ វណ្ណៈខ្ពស់ដល់កម្រិតណា មានលុយកាក់ច្រើនប៉ុណ្ណាក៏ដោយ ក៏ត្រូវតែគោរពច្បាប់ និងស្ថិតនៅក្រោមច្បាប់ទាំងអស់គ្នា។ គ្រប់ស្ថាប័នរដ្ឋទាំងអស់ត្រូវស្ថិតនៅក្រោមច្បាប់ ការអនុវត្តន៍ច្បាប់ដោយមន្ត្រីរាជការក្នុងរដ្ឋាភិបាល ឬតុលាការត្រូវធ្វើឡើងប្រកបដោយគតិយុត្តិធម៌ ពោលគឺមិនត្រូវយកច្បាប់ទៅប្រើដោយទាញយឺតដូចកៅស៊ូហើយតម្រូវតាមផលប្រយោជន៍របស់ខ្លួន ឬបក្សពួកខ្លួនឡើយ។ ការគោរពច្បាប់ គឺជួយពង្រឹងសិទ្ធិឲ្យកាន់តែមានរស្មីភ្លឺថ្លា។[11]

**៥. រដ្ឋាភិបាលត្រូវមានការទទួលខុសត្រូវ និងមានអភិបាលកិច្ចល្អ៖** រដ្ឋាភិបាលប្រជាធិបតេយ្យត្រូវតែទទួលខុសត្រូវចំពោះមុខប្រជាពលរដ្ឋរបស់ខ្លួន ចំពោះមុខជាតិ នូវអ្វីដែលមានធានាដោយច្បាប់ ហើយប៉ះពាល់ដល់ប្រយោជន៍ជាតិប៉ះពាល់ដល់ប្រជាពលរដ្ឋ និងអ្វីដែលរដ្ឋាភិបាល ឬអ្នកដឹកនាំរដ្ឋាភិបាលនោះបានសន្យា។ រដ្ឋាភិបាល ឬអ្នកដឹកនាំប្រទេសប្រជាធិបតេយ្យត្រូវក្លាហានហ៊ានចុះចេញពីតំណែងមុខអាណត្តិនៅពេលណាដែលប្រទេសជាតិ ឬប្រជាពលរដ្ឋខ្លួនធ្លាក់ក្នុងវិបត្តិណាមួយដោយសារតែខ្លួនអសមត្ថភាពក្នុងការដឹកនាំ។ លើសពីនេះទៅទៀត រដ្ឋាភិបាល ឬអ្នកដឹកនាំរដ្ឋាភិបាលត្រូវទទួលខុសត្រូវជាដាច់ខាតនូវអ្វីដែលខ្លួនបានអនុវត្តផ្ទុយពីច្បាប់ ឬផ្ទុយពីឆន្ទៈរបស់ប្រជាពលរដ្ឋ។ ក្នុងសង្គមប្រជាធិបតេយ្យប្រជាពលរដ្ឋអាចចោទប្រកាន់ ឬប្ដឹងរដ្ឋាភិបាល ឬអ្នកដឹកនាំទៅតុលាការបាន ហើយទាំងរដ្ឋាភិបាល ទាំងអ្នកដឹកនាំក៏ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ដែរ។ ទន្ទឹមនឹងការទទួលខុសត្រូវខាងលើនេះ រដ្ឋាភិបាលប្រជាធិបតេយ្យត្រូវមាន អភិបាលកិច្ចល្អ តម្លាភាពល្អ និងចាត់ចែងការងាររបស់ខ្លួនបានត្រឹមត្រូវតាមច្បាប់ជាតិ និងអន្តរជាតិ។ រដ្ឋាភិបាលត្រូវផ្សព្វផ្សាយព័ត៌មាន និងឯកសារផ្សេងៗស្ដីពីសកម្មភាពរបស់ខ្លួនឲ្យប្រជាពលរដ្ឋបានដឹងជាទូទៅ លើកលែងតែឯកសារ ឬព័ត៌មានណាដែលប៉ះពាល់ដល់សន្តិសុខជាតិ ហើយក៏ត្រូវទទួលស្គាល់កំហុស និងទទួលយកនូវការកែលម្អពីសំណាក់ ប្រជាពលរដ្ឋដើម្បីធ្វើឲ្យកាន់តែមានការជឿជាក់ទៅលើការដឹកនាំរបស់ខ្លួន។ ឧទាហរណ៍ ការបាត់បង់ទឹកដី ការបំផ្លិចបំផ្លាញធនធានធម្មជាតិ ភាពក្រីក្ររបស់ប្រជាពលរដ្ឋ អសន្តិសុខ អំពើពុករលួយ។[12]

[11] គីម សុខា.គៀត សុគន្ធ.លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងពលរដ្ឋវិជ្ជា.កម្ពុជា.ឆ្នាំ២០០៤.ទំព័រទី១១-១២

[12] គីម សុខា.គៀត សុគន្ធ.លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងពលរដ្ឋវិជ្ជា.កម្ពុជា.ឆ្នាំ២០០៤.ទំព័រទី១២-១៣

**៦. តុល្យភាពរវាងអំណាចទាំងបី (នីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ)៖** យន្តការសំខាន់បំផុតបីសម្រាប់ដំណើរការគ្រប់គ្រងរដ្ឋក្នុងប្រទេសប្រជាធិបតេយ្យគឺ ស្ថាប័ននីតិបញ្ញត្តិ (សភា) ស្ថាប័នីតិប្រតិបត្តិ (រដ្ឋាភិបាល) និង ស្ថាប័នតុលាការ។ ដើម្បីឲ្យអំណាចទាំបីនេះបម្រើប្រយោជន៍ពិតប្រាកដសម្រាប់ប្រទេស និងសម្រាប់ប្រជាពលរដ្ឋស្របតាមគោលការណ៍ប្រជាធិបតេយ្យដែលប្រជាពលរដ្ឋជាម្ចាស់អំណាចលុះត្រាតែស្ថាប័នទាំងបីនេះបែងចែកអំណាចឲ្យដាច់ពីគ្នា មានតុល្យភាពរវាងអំណាចនីមួយៗ ជាពិសេសត្រូវមានប្រព័ន្ធតុលាការមួយឯករាជ្យ។ សភាប្រជាធិបតេយ្យគឺជា តំណាងយ៉ាងពិតប្រាកដរបស់ប្រជាពលរដ្ឋមិនមែនគ្រាន់តែជាតំណាងខ្លួនឯង ឬគ្រាន់តែជាតំណាងគណបក្សខ្លួនប៉ុណ្ណោះទេ ពេលធ្វើច្បាប់ ឬមុននឹងអនុម័តអ្វីមួយដែលជាបញ្ហាធំៗរបស់ប្រទេសជាតិ ឬបញ្ហាដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ អ្នកតំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភាត្រូវតែស្ទាបស្ទង់យោបល់ ប្រជាពលរដ្ឋនៅតាមមណ្ឌល។ លើសពីរនេះទៅទៀត សមាជិកសភាត្រូវតែមកដល់មណ្ឌលខ្លួនជាទៀងទាត់ដើម្បីស្វែងយល់អំពីបញ្ហា កង្វល់របស់ម្ចាស់ឆ្នោត ហើយលើកយកបញ្ហាទាំងនោះទៅធ្វើអន្តរាគមន៍ដើម្បីជួយដោះស្រាយ។ ចំពោះរដ្ឋាភិបាលដែលជាស្ថាប័ននីតិប្រតិបត្តិ ត្រូវតែមានការទទួលខុសត្រូវចំពោះមុខប្រជាពលរដ្ឋដោយផ្ទាល់ ឬតាមរយៈសភាផ្ទាល់ ហើយមិនត្រូវសម្រេចកិច្ចការធំរបស់ជាតិ របស់ប្រជាពលរដ្ឋដោយគ្មានការសម្រេចយល់ព្រមពីសភាឡើយ។ ជាពិសេសគេសង្កេតឃើញនៅក្នុងប្រទេសមួយចំនួន រដ្ឋាភិបាលច្រើនតែប្រើអំណាចរបស់ខ្លួនរំលោភទៅលើអំណាចសភា និងតុលាការ។ តុលាការដែលត្រូវមានឯករាជ្យភាពនោះមិនមែនមានន័យថា ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការទាំងនោះធ្វើអ្វីស្រេចតែចិត្តខ្លួនដោយលម្អៀងដោយពុករលួយ ឬដោយបក្សពួកនោះទេ។ ឯករាជ្យភាពរបស់តុលាការគឺ ឯករាជ្យពីការគំហែងរបស់អ្នកមានអំណាច ឯករាជ្យពីបក្សពួក ឬគណបក្សនយោបាយ ឯករាជ្យពីការទិញដោយទឹកលុយ។ ប៉ុន្តែត្រូវធ្វើតាមច្បាប់ គោរពច្បាប់ អនុវត្តច្បាប់ឲ្យបានយុត្តិធម៌ឥតលម្អៀង ។[13]

**៧. រដ្ឋបាល និងកម្លាំងប្រដាប់អាវុធអព្យាក្រឹត្យ៖** គឺជាការចាំបាច់ណាស់ដើម្បីអាចអនុវត្តលទ្ធិប្រជាធិបតេយ្យបានលុះត្រាតែរដ្ឋបាលគ្រប់ជាន់ថ្នាក់ និងកម្លាំងប្រដាប់អាវុធដូចជាអាជ្ញាធរថ្នាក់លើ និងមូលដ្ឋាន ប៉ូលីស ទាហាន ប៉េអឹមជាដើមត្រូវបំពេញការងារដោយអព្យាក្រឹត្យ។ ជាការពិតណាស់បុគ្គល់ដែលបម្រើក្នុងស្ថាប័នរដ្ឋបាល ឬកម្លាំងប្រដាប់អាវុធនោះក៏ជាប្រជាពលរដ្ឋដែរ

[13] គឹម សុខា.គៀត សុគន្ធ.លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងពលរដ្ឋវិជ្ជា.កម្ពុជា.ឆ្នាំ២០០៤.ទំព័រទី១៣-១៤

ហើយក៏មានចូលរួមជាសមាជិក ឬគាំទ្រគណបក្សនយោបាយណាមួយ ឬបុគ្គលណាមួយក៏ប៉ុន្តែរ បុគ្គលដែលកាន់ការងាររដ្ឋបាល ឬជាកម្លាំងប្រដាប់អាវុធ មិនត្រូវយកតួនាទីមុខតំណែង ឋានៈទៅបម្រើតែគណបក្សណាមួយនោះទេ គឺបម្រើទូទៅដោយមិនគិតពីនិន្នាការនយោបាយឡើយ។ ជាពិសេសគេមិនត្រូវយកទ្រព្យសម្បត្តិ សម្ភារៈ ថវិការដ្ឋទៅបម្រើគណបក្សដែលគេគាំទ្រនោះទេ។ ការ យកទូនាទីមុខតំណែងទៅបម្រើជាអំណាចដើម្បីឲ្យគេផ្តល់ជាសគុណាឲ្យខ្លួននោះជាអំពើពុករលួយ ហើយការយកលុយកាក់សម្ភារៈដែលបានមកពីអំពើនេះទៅសម្រាប់ខ្លួន ក្រុមខ្លួន បក្សខ្លួនគឺជាអ្នកដឹកនាំផ្តាច់ការ។[14]

**៨. សេដ្ឋកិច្ចផ្សារសេរី៖** សេដ្ឋកិច្ចផ្សារសេរីគឺជាប្រព័ន្ធសេដ្ឋកិច្ចដែលផ្ទុយពីសេដ្ឋកិច្ចប្រមូលផ្តុំ ឬសេដ្ឋកិច្ចផ្តាច់មុខ។ ដើម្បីឲ្យផលប្រយោជន៍សេដ្ឋកិច្ចបានទៅប្រជាពលរដ្ឋផង បានទៅប្រទេសជាតិផង និងអាចឲ្យមានការរីកចម្រើនផ្នែកសេដ្ឋកិច្ចផង ប្រទេសប្រជាធិតេយ្យត្រូវបើកឲ្យមានការប្រកួតប្រជែងក្នុងការលក់ ការទិញ និងជួលឲ្យមានលក្ខណៈតម្លាភាពជៀសវាងការកាន់កាប់ផ្តាច់មុខ។ សេដ្ឋកិច្ចផ្សារសេរីមិនមែនមានន័យថា ឲ្យអ្នករកស៊ីធ្វើអ្វីតាមអំពើចិត្ត និងមិនមែនបើកដៃឲ្យរដ្ឋាភិបាល ឬសមត្ថកិច្ចនានាមានឱកាសដើម្បីប្រព្រឹត្តអំពើពុករលួយដើម្បីបក្សពួកនោះទេ។ សេដ្ឋកិច្ចផ្សារសេរីគឺជាសេដ្ឋកិច្ចដែលមានតម្លាភាព និងគុណាភាព។[15]

**៩. ការបោះឆ្នោតដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងទៀងទាត់៖** ការបោះឆ្នោតគឺជាកត្តាសំខាន់បំផុតសម្រាប់បើកផ្លូវឲ្យលទ្ធិប្រជាធិបតេយ្យអាចអនុវត្តនៅក្នុងសហគមន៍ ឬប្រទេសនីមួយៗ។ ក៏ប៉ុន្តែរក្នុងរបបដឹកនាំខ្លះមានការបោះឆ្នោតដែរ តែផ្ទុយទៅវិញបើសិនការបោះឆ្នោតគ្រាន់តែជាការឡប់ឡែមិនមានលក្ខណៈ សេរី មិនត្រឹមត្រូវ មិនយុត្តិធម៌ ឬមិនទៀងទាត់ពេលវេលាក៏មិនអាចហៅថា ការបោះឆ្នោតតាមលទ្ធិប្រជាធិបតេយ្យដែរ និងមិនអាចធ្វើឲ្យលទ្ធិប្រជាធិបតេយ្យដំណើរការបាននោះទេ។ ការបោះឆ្នោតដោយសេរីមានន័យថា ប្រជាពលរដ្ឋអាចធ្វើការសម្រេចចិត្តជ្រើសរើស អ្នកដឹកនាំ ឬធ្វើការសម្រេចចិត្តលើកិច្ចការអ្វីមួយទៅតាមឆន្ទៈរបស់ខ្លួនដោយប្រើប្រាស់សិទ្ធិតាមរយៈសន្លឹកឆ្នោតដោយគ្មានការបង្ខិតបង្ខំ គម្រាមកំហែង បំភិតបំភ័យ ឬរារាំងតាមរូបភាពផ្សេងៗ ឡើយ។ ចំណែកការបោះឆ្នោតដោយត្រឹមត្រូវមានន័យថា មិនមានការទិញដូរមិន

[14] កឹម សុខា.គៀត សុគន្ធ.លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងពលរដ្ឋវិជ្ជា.កម្ពុជា.ឆ្នាំ២០០៩.ទំព័រទី១៤-១៥
[15] កឹម សុខា.គៀត សុគន្ធ.លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងពលរដ្ឋវិជ្ជា.កម្ពុជា.ឆ្នាំ២០០៩.ទំព័រទី១៥

កេងបន្លំ ឬមិនលួចសន្លឹកឆ្នោតទោះជាតាមរូបភាពណាក៏ដោយ។ ចំណែកឯការបោះឆ្នោតដោយយុត្តិធម៌មានន័យថា មិនលម្អៀងទៅលើគណបក្សនយោបាយណាមួយជាពិសេសអាជ្ញាធររៀបចំការបោះឆ្នោតដូចជា គណកម្មការជាតិរៀបចំការបោះឆ្នោត គឺត្រូវតែអព្យាក្រឹត្យជាដាច់ខាត គ្រប់គណបក្ស និងគ្រប់បេក្ខជនទាំងអស់ត្រូវទទួលបាននូវភាពស្មើគ្នាក្នុងការប្រើប្រាស់ ប្រព័ន្ធផ្សព្វផ្សាយមធ្យោបាយ និងទីកន្លែងសាធារណៈ របស់រដ្ឋ។ រីឯការបោះឆ្នោតដោយទៀងទាត់មានន័យថា ពេលវេលានៃការបោះឆ្នោតត្រូវតែធ្វើទៅតាមកាលកំណត់ មិនត្រូវពន្យាពេលហួសអាណត្តិដោយយកលេសផ្សេងៗនោះទេ លើកលែងតែមានសង្គ្រាមដែលបណ្តាលឲ្យមានការរាំងស្ទះដល់ដំណើរការរៀបចំការបោះឆ្នោត។ បើការបោះឆ្នោតមិនសេរី មិនត្រឹមត្រូវ និងមិនយុត្តិធម៌ទេ រដ្ឋសភា រដ្ឋាភិបាលដែលកើតឡើងដោយការបោះឆ្នោតនោះ ក៏មិនអាចជាតំណាងឆន្ទៈពិតប្រាកដរបស់ប្រជាពលរដ្ឋដែរ ។[16]

បើយើងក្រឡេកមកមើលឯកសារមួយដែលមានចំណងជើងថា អ្វីទៅដែលហៅថាលទ្ធិប្រជាធិបតេយ្យ គេបានរៀបរាប់សសរស្តម្ភនៃលទ្ធិប្រជាធិបតេយ្យមានដូចជា៖ អធិបតេយ្យភាពប្រជាជន រដ្ឋាភិបាលឈរលើការព្រមព្រៀងពីសំណាក់ជនដែលអភិបាលខ្លួនគ្រប់គ្រង ការគ្រប់គ្រងដោយមតិភាគច្រើន គោរពសិទ្ធិជនជាតិភាគតិច ធានាសិទ្ធិមនុស្សជាមូលដ្ឋាន បោះឆ្នោតដោយសេរី និង ត្រឹមត្រូវ ស្មើភាពគ្នាចំពោះមុខច្បាប់ ដំណើការរៀបចំកាត់ក្តីដ៏សមស្របតាមច្បាប់ ការកម្រិតរដ្ឋធម្មនុញ្ញលើអំណាចរដ្ឋបាល ពហុភាពសង្គមនិងសេដ្ឋកិច្ច តម្លៃនៃការចេះអត់អោនឲ្យគ្នា ការនិយមសហប្រតិបត្តិការ និងសម្រុះសម្រួលគ្នា។[17]

## ៤. ទ្រឹស្តី លោក ណុប ប៊ូផាន់

ដើម្បីធ្វើឲ្យប្រទេសមួយអាចអនុវត្តនូវលទ្ធិប្រជាធិបតេយ្យបានត្រឹមត្រូវ ចាំបាច់ត្រូវបង្កើតអង្គការសំខាន់ៗ ៣ គឺ៖ រដ្ឋសភា (នីតិបញ្ញាតិ) គណរដ្ឋមន្ត្រី (នីតិប្រតិបត្តិ) និងតុលាការជាន់ខ្ពស់ (អំណាចតុលាការ) ហើយអំណាចទាំង៣នេះត្រូវតែឈរលើ ឯករាជ្យភាពចែកដាច់ពីគ្នា និងមានសិទ្ធិអំណាចលើគ្នាទៅវិញទៅមក។ ជាពិសេសប្រទេសមួយដែលមានប្រជាធិបតេយ្យពិតប្រាកដគេត្រូវមើលគោលការណ៍ ៣ ទៀតគឺ សេរីភាព សមភាព យុត្តិធម៌។

[16] គឹម សុខា.លោក គៀត សុគន្ធ.លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងពលរដ្ឋវិជ្ជា.កម្ពុជា.ឆ្នាំ២០០៤.ទំព័រទី១៥-១៦

[17] ក្រសួងឃោសនាសហរដ្ឋអាមេរិក(ខែតុលាឆ្នាំ១៩៩១)អ្វីទៅដែលហៅថាលទ្ធិប្រជាធិបតេយ្យ.ទំព័រទី២២

### ៤.១. សេរីភាព

ដើមឡើយ សេរីភាព សមភាព យុត្តិធម៌មិនបានផ្តល់ឲ្យប្រជាជនគ្រប់ជាន់ថ្នាក់មាន កសិករ កម្មករជាដើមដែលទើបនឹងបំរះខ្លួនរួចពីការជិះជាន់នៃជនសក្តិភូមិអធិរាជ។ ទោះជាយ៉ាងណាក៏ដោយ សេរីភាព សមភាព និងយុត្តិធម៌សម្រាប់ប្រជាជនគ្រប់ជាន់ថ្នាក់មានតែក្នុងតម្រាច្បាប់ តាមហេតុការណ៍ជាក់ស្តែងជនខ្សត់ខ្សោយពុំអាចទទួលអំណាចនៃវត្ថុមានតម្លៃទាំងនេះទេ។ យ៉ាងណាមិញឧបមាថាបើម្នាក់ៗមានសេរីភាពក្នុងការនិយាយស្តី និងបោះពុម្ពផ្សាយនូវយោបល់ ឬមតិរបស់ខ្លួន។ ដើម្បីនឹងប្រតិបត្តិសេរីភាពនេះបាន សាមីខ្លួនត្រូវមានមធ្យោបាយគ្រប់គ្រាន់ទាំងខាងសម្ភារៈ និងខាងគំរិះវិជ្ជាម្ល៉ោះហើយ កសិករ និងកម្មករដែលរស់នៅក្រីក្រលំបាក ល្ងង់ខ្លៅ តាំងតែពីក្រោម ការជិះជាន់នៃពួកសក្តិភូមិមក ពុំអាចបំពេញបំណងរបស់ខ្លួនបានឡើយ។ ជនសក្តិភូមិអធិរាជខំរក្សាសភាពនេះដោយច្រណែន ទុកអត្ថប្រយោជន៍សម្រាប់តែជាន់ថ្នាក់គេ។ គេជាអ្នកកាន់កាប់កិច្ចការរដ្ឋគ្មានគិតការពង្រឹងការសិក្សា គេគ្មានយកចិត្តទុកដាក់ខំសម្រួលការសិក្សាធ្វើយ៉ាងណាឲ្យជនដែលខ្សត់ខ្សោយបាន ក្រេបរស់ជាតិនៃចំណេះវិជ្ជាទេ គេទុកឲ្យជនទាំងនេះនៅល្ងង់ខ្លៅ ដើម្បីងាយស្រួលជួលបានថោកយកមកប្រើប្រាស់ដូចសត្វដូចធាតុក្នុង ឧស្សាហកម្មរបស់គេ។ បើមានការអនុគ្រោះឲ្យចេះដឹងបន្តិចបន្តួចនោះក៏គ្រាន់តែសម្រាប់ឲ្យឯង វក់បុណ្យ វក់សក្តិជិះជាន់គ្នាឯង បម្រើប្រយោជន៍គេតែប៉ុណ្ណោះ។ ចំពោះសេរីភាពក្នុងជំនឿក៏មិនខុសគ្នាប៉ុន្មានដែរ។ ក្នុងទុរគិតខ្សត់ខ្សោយ គ្មានសេរីភាពក្នុងជំនឿទេ ឬក៏មានដែរតែសេរីភាពនោះត្រូវគេរិតត្បិត។ ការជិះជាន់សេរីភាពក្នុងជំនឿអាចធ្វើឡើងបានដោយផ្លូវពីរគឺ ផ្លូវសង្គមកិច្ច និងផ្លូវនយោបាយដោយគ្មានកម្លាំង។ តាមផ្លូវសង្គមកិច្ច គេចាត់តាំងអង្គការសកលដែលបានទទួលការឧបត្ថម្ភសព្វបែបសព្វយ៉ាងពីបក្សពួកគេ ជាន់ថ្នាក់គេ ដើម្បធ្វើការផ្សាយលទ្ធិគេ ជំនឿគេគ្របសង្កត់លើលទ្ធិលើជំនឿឯទៀតៗដែលផ្ទុយនឹងប្រយោជន៍គេ។ ម្ល៉ោះហើយអ្នកដែលខ្វះមធ្យោបាយនឹងធ្វើដូចគេក៏បានឃើញលទ្ធិខ្លួនស្ថិតទៅៗរហូតដល់សាបសូន្យក៏មាន បើសិនណាជាលទ្ធិនោះ ឬជំនឿនោះគ្មានឫសកែវ គ្មានមូលដ្ឋានវិទ្យាសាស្ត្រ។ ឧទាហរណ៍ ដូចគ្រីស្តសាសនា នឹងជំនឿ ឬសាសនាតូចតាចឯទៀតៗ។ តាមផ្លូវនយោបាយដោយកម្លាំងគ្រង់នេះរត់ចូលមកក្នុងឆាកតែម្តង។ ដូចជានៅក្នុងសហរដ្ឋអាមេរិកប្រជាជនអាមេរិកគ្មានសេរីភាពនឹងជឿលើលទ្ធិកុម្មុយនីស្តទេ។ ជនណាដែលរាជការ ម៉ាក់ការទិស្តិអាមេរិកសង្ស័យថាជាកុម្មុយនីស្តជននោះត្រូវទទួលទណ្ឌកម្ម។ នៅអឺរ៉ុបដូចជានៅប្រទេសអង់គ្លេស ឬបារាំងជាដើម គេអនុញ្ញាតឲ្យមានគណបក្សកុម្មុយនីស្ត ប៉ុន្តែ

រាជការរករឿង រកហេតុចោទប្រកាន់សព្វបែបយ៉ាង ដើម្បីរាលត្បាតលទ្ធិកុម្មុយនីស្ត។ សេរីភាពក្នុងជំនឿ និងសេរីភាពក្នុងការនិយាយស្តីបោះពុម្ពជាសេរីភាពសំខាន់បំផុតក្នុងរបបប្រជាធិបតេយ្យ ហេតុដូច្នេះហើយបានជាគេហៅសេរីភាពនេះថា ជាសេរីភាពប្រជាធិបតេយ្យ។ ដូចនេះ ប្រសិនណាខ្វះសេរីភាពខាងជំនឿ ឬសេរីភាពខាងបោះពុម្ពផ្សាយគេមិនអាចសន្មតថា មានលទ្ធិប្រជាធិបតេយ្យបានជាដាច់ខាត។ ពីព្រោះហេតុនេះហើយទើបប្រជាជនត្រូវតម្កល់ទុកជាករណីយកិច្ច ប្រសើរជាងនេះទៅទៀតត្រូវតម្កល់ទុកជាកាតព្វកិច្ចផ្ទាល់ខ្លួននូវកិច្ចការពារយ៉ាងម៉ឺងម៉ាត់ នៃសេរីភាពទាំងពីរខាងលើនេះ សេរីភាពខាងជំនឿ សេរីភាពខាងនិយាយស្តី បោះពុម្ពផ្សាយ បើប្រជាជននោះស្រលាញ់ចង់បានលទ្ធិប្រជាធិបតេយ្យពិតៗ។ ដរាបណាមានការបំពានរំលោភលើសេរីភាពប្រជាធិបតេយ្យ ដរាបនោះត្រូវតែមានការតស៊ូតវ៉ាប្រឆាំងទល់មកវិញ ។[18]

### ៤.២. សមភាព

លក្ខណៈចរិតនៃលទ្ធិប្រជាធិបតេយ្យមួយទៀតគឺ សមភាព។ ចំពោះសមភាពនេះប្រជាជនត្រូវយល់ដូចម្តេចខ្លះ? គំនិតមួយដំបូងគឺ សមភាពរវាងភេទទាំងពីរ សមភាពរវាងភេទប្រុស និងភេទស្រី ។ បានសេចក្តីថា បើបុរសមានសិទ្ធិនឹងធ្វើអ្វីបាន ត្រូវបើកសិទ្ធិឲ្យស្ត្រីធ្វើដូចគ្នាបានដែរ ។

ឧទាហរណ៍៖ ស្ត្រីឲ្យមានសិទ្ធិដូចបុរស និងកាន់តំណែងជាអ្នករាជការតាំងពីនិយោជិតធម្មតារហូតដល់រដ្ឋមន្ត្រី ស្ត្រីមានសិទ្ធិបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឬឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្រដូចបុរស។ សព្វថ្ងៃនេះនៅក្នុងប្រទេសនានា គេមិនជំទាស់នឹងសមភាពរវាងភេទទៀតទេ។ ប៉ុន្តែនៅមានសមភាពរវាងមនុស្សលោកមួយយ៉ាងទៀតដែលនៅមាន អ្នកទ្រឹស្តីក្នុងប្រទេសខ្លះមិនទាន់ព្រមទទួលស្គាល់នៅឡើយទេ គឺសមភាពរវាងសាសន៍។ គេនៅប្រកាន់ថាសាសន៍នេះជាសាសន៍ខ្ពង់ខ្ពស់ ចំណែកសាសន៍នោះជាសាសន៍ថោកទាប ដូចជាថា សាសន៍ស្បែកសជាសាសន៍ថ្លៃថ្នូរ បន្ទាប់មកមានសាសន៍ស្បែកលឿង រួចស្រទាប់ក្រោមបង្អស់មានសាសន៍ស្បែកខ្មៅដែលគេទុកជាសាសន៍ខ្ញុំកំដរគេ។ យើងគ្មានបំណងនឹងពិនិត្យទ្រឹស្តីសាសន៍និយមទេ វាទូលាយហួសក្របខ័ណ្ឌនៃឯកសារយើង។ យើគ្រាន់តែសូមរំលឹកថា សាសន៍និយមគឺជាលទ្ធិមួយដែរ។ បើដូច្នេះដើម្បីដឹងយល់លទ្ធិសាសន៍និយមនេះ យើងត្រូវពិនិត្យវាក្នុងរង្វង់នៃសេដ្ឋកិច្ច ឬសកែរវាជុះក្នុងជីវជាតិនៃកិច្ចផលិតកម្ម។ ឥឡូវនេះយើងត្រឡប់មកមើលសមភាពវិញ។ យើងដឹងបានថាសមភាពដែលត្រូវមានដំបូងបង្អស់ក្នុងប្រជាជាតិនីមួយៗ គឺសមភាពរវាង

[18] ណុប បូផាន់.សៀវភៅលទ្ធិប្រជាធិបតេយ្យ.ភ្នំពេញ.ឆ្នាំ១៩៥៦.ទំព័រទី៣០-៣៤

ភេទប្រុស និងភេទស្រី។ ទើបមានសំនួរមួយចោទឡើង សមភាពត្រូវមានក្នុងនាទីណាខ្លះ ហើយក្នុងនាទីនីមួយៗ សមភាពស្ថិតនៅលើអ្វី? យើងឃើញមាននាទីពីរះ នយោបាយ និងសង្គមកិច្ច។ តាមន័យនយោបាយសមភាពស្ថិតនៅលើសិទ្ធិមនុស្ស។ ក្នុងរបបប្រជាធិបតេយ្យដែលយើងកំពុងតែពិនិត្យនេះយើងឃើញមានសិទ្ធិសំខាន់ៗបីះ

**១. សិទ្ធិនៃពលរដ្ឋម្នាក់ៗដើម្បីកាន់តំណែងរាជការសាធារណៈ**

លទ្ធិប្រជាធិបតេយ្យគ្មានផ្អែកលើអ្វីក្រៅពីតំរិះវិជ្ជា និងសមត្ថភាពនៃសាមីខ្លួនទេក្នុងការរើសយកអ្នកកាន់តំណែងរាជការ។ ការប្រកាន់បុរស ឬស្ត្រី ការយោគយល់មុខ ឬមិត្តភ័ក្តិ ការប្រកាន់បក្សពួកទើបប្រគល់តំណែងរាជការឲ្យមិនស្របទៅនឹង លទ្ធិប្រជាធិបតេយ្យបន្តិចណាសោះ។ មិនតែប៉ុណ្ណោះ ការរើសអើងបែបនេះនាំតែបំបែកប្រជាជាតិ ជាបក្សពួក ជាមិត្ត ជាសត្រូវ ដែលជាហេតុនាំឲ្យអន្តរាយបំផុតដល់សាមគ្គីជាតិទាំងមូល ហើយអ្នកដែលកាន់អាកប្បកិរិយាដូច្នេះ តែងតែសង្ឃឹមលើកម្លាំងរាតត្បាតដោយទាហាន ប៉ូលីស គុកច្រវាក់ ដើម្បីនឹងពង្រឹងជំហរខ្លួន។ អំពើនេះផ្ទុយស្រឡះនឹងលទ្ធិប្រជាធិបតេយ្យ។[19]

**២. សិទ្ធិនៃពលរដ្ឋដើម្បីមានការងារធ្វើ**

ពលរដ្ឋម្នាក់ៗ ត្រូវមានសិទ្ធិស្មើៗគ្នាដើម្បីមានការងារធ្វើសមតាមតំរិះវិជ្ជាតាមសមត្ថភាព។ រាជការត្រូវតែទំនុកបម្រុងពលរដ្ឋទាំងអស់គ្នា មិនប្រកាន់ថាអ្នកនេះជាកូនចៅឯកឧត្តមនេះ ឬលោកនោះ ទើបជួយឧបត្ថម្ភ ចំណែកកូនចៅអ្នកកម្មករ ឬកសិករមិនអើពើឡើយ។ បើទំនុកបម្រុងដោយរើសមុខដូច្នេះ សន្មតបានថា គ្មានលទ្ធិប្រជាធិបតេយ្យឡើយ។[20]

**៣. សិទ្ធិនៃពលរដ្ឋដើម្បីប្រាស្រ័យចូលក្នុងកិច្ចការប្រយោជន៍រួម**

កិច្ចការដែលរាជការសាធារណៈ បានធ្វើទាំងអំបាលម៉ានប្រជាជនទាំងមូលទទួលរងអំណោយផលទោះល្អក្តី អាក្រក់ក្តី។ ហេតុដូច្នេះ លទ្ធិប្រជាធិបតេយ្យតម្រូវឲ្យប្រជាពលរដ្ឋម្នាក់ៗមានសិទ្ធិស្មើគ្នាក្នុងការគិតដល់ប្រយោជន៍រួម។ កម្មករ កសិករ ឬអ្នកបង់ពន្ធម្នាក់ណាទៀតត្រូវមានសិទ្ធិនេះស្មើនឹងឯកឧត្តមរដ្ឋមន្ត្រី ឬតំណាងរាស្ត្រដែរ។ យើងលើកយកឧទាហរណ៍រូបីយ៍មួយមកបញ្ជាក់រឿងនេះ។ ដូចជាបញ្ហាជំនួយយោធាអាមេរិកបម្រុងនឹងផ្តល់ឲ្យប្រទេសខ្មែរដែលកំពុងតែធ្វើឲ្យប្រជាជនយើងព្រួយបារម្ភគ្រប់ៗគ្នា ចំពោះអនាគត់ប្រទេសយើង។ ជំនួយយោធា

[19] ណុប បូផាន់.សៀវភៅលទ្ធិប្រជាធិបតេយ្យ.ភ្នំពេញ.ឆ្នាំ១៩៥៦.ទំព័រទី៣៦-៣៧

[20] ណុប បូផាន់.សៀវភៅលទ្ធិប្រជាធិបតេយ្យ.ភ្នំពេញ.ឆ្នាំ១៩៥៦.ទំព័រទី៣៧

អាមេរិកនេះនឹងផ្តល់អំណោយផល ទោះល្អក្តី អាក្រក់ក្តីទៅដល់ប្រជាជាតិខ្មែរទាំងមូល មិនថាជាន់ថ្នាក់សង្គមណាទេ។ ហើយក៏ព្រោះហេតុនេះហើយពលរដ្ឋខ្មែរគ្រប់រូបត្រូវមានសិទ្ធិនឹងបញ្ចេញមតិខ្លួនអំពីរឿងនេះ ដើម្បីឲ្យអ្នកទទួលខុសត្រូវ មានរដ្ឋសភា ក្រុមប្រឹក្សាព្រះរាជាណាចក្រ និងគណៈរដ្ឋមន្ត្រីសម្រេចឲ្យបានប្រកបតាមឆន្ទៈច្រើន។ តាមរបបប្រជាធិបតេយ្យពលរដ្ឋម្នាក់ៗមានមធ្យោបាយច្រើនយ៉ាងដើម្បីសំដែងនូវមតិខ្លះ អត្ថបទចុះផ្សាយតាមទំព័រការសែត សំបុត្រប្បញ្ញត្តិផ្ញើ ចំពោះទៅរដ្ឋសភាជាតិ ឬគណៈរដ្ឋមន្ត្រី ឬពិភាក្សាជួយយោបល់គ្នា។ ចុះតាមន័យសង្គមកិច្ច យើងត្រូវយល់សមភាពដូចម្តេចក្នុងរបបប្រជាធិបតេយ្យ? យើងឃើញមាននាទីពីរះ

**ក. សមភាពក្នុងឋានៈជាពលរដ្ឋ**

បុគ្គលខ្មែរម្នាក់ៗទោះជាបុរសក្តី ស្ត្រីក្តី ក៏ជាពលរដ្ឋខ្មែរម្នាក់ដែរ។ ហេតុដូច្នេះខ្មែរត្រូវមានការគោរពគ្នាទៅវិញទៅមក មិនប្រកាន់ឋានៈនៃស្ថានភាពសង្គមដរាបណាដែលយើងរស់នៅដោយស្លូតត្រង់ មិនប្រកបរបររកទទួលទានដោយទុច្ចរិត ឬអមនុស្សធម៌។ អ្នករាជការ នាម៉ឺន មន្ត្រីតូចធំ ត្រូវតែគោរព រាប់រកប្រជានុរាស្ត្រ ក៏ដូចជាផ្ទុយទៅវិញប្រជានុរាស្ត្រត្រូវស្រលាញ់គោរពអ្នករាជការទាំងឡាយព្រោះថា សាមគ្គីភាព និងកិច្ចបដិសណ្ឋារៈទៅវិញទៅមកនាំឲ្យ មានសហប្រតិបត្តិប្រសើរណាស់ ក្នុងប្រទេសឲ្យបានរីកចម្រើនថ្កុំថ្កើងរុងរឿងទៅអនាគត់ឲ្យទាន់សម័យ នៃប្រទេសដែលមានអរិយធម៌ខ្ពង់ខ្ពស់។ នេះហើយគឺជាដើមគំនិតដំបូងនៃលទ្ធិប្រជាធិបតេយ្យចំពោះរឿងនេះ។ ក៏ប៉ុន្តែរបបមូលធននិយដែលផ្អែកលើកិច្ចអាជីវកម្មនៃមនុស្ស ធ្វើដោយមនុស្សមិនអាចឲ្យសម្រេច គោលការណ៍ល្អប្រពៃនេះបានទេ។ ការទាក់ទងរវាងមនុស្សក្នុងកិច្ចផលិតកម្មមូលធននិយម នាំឲ្យមនុស្សមិនទុកចិត្តមនុស្ស នាំឲ្យមនុស្សខ្លាចមនុស្ស នាំឲ្យមនុស្សមើលថោកមនុស្ស។ ស្រួល និងងាយយល់ណាស់ អ្នកសួរឧស្សាហករមេទុនម្នាក់មើល គេមុខជានឹងឆ្លើយមកវិញថាៈ កម្មករជាបាវព្រាវរបស់ខ្ញុំវារស់ដោយសារខ្ញុំ ខ្ញុំចង់ដេញវាចោលក្នុងពេលណាក៏បាន អ្នកណាចង់ឲ្យខ្ញុំលើកស្ទួយវាស្មើមុខនឹងខ្ញុំឯណាបាន ម្តេចបាន? ហេតុដែលមានមនុស្សមួយក្រុមមានជាទ្រព្យនូវប្រដាប់ប្រដាសម្រាប់បង្កើតផលទាំងអស់ ឯមនុស្សមួយក្រុមទៀតរាប់កោដិលាននាក់ មានតែកម្លាំងកាយសម្រាប់បង្កើតផលឲ្យគេចិញ្ចឹមខួរក្បាលមនុស្សនូវគំនិតមិនសមម្យេរកគ្នាទៅវិញទៅមក។ ដើម្បីនឹងមើលជំងឺសង្គមនេះពួកមេទុន ដែលកាន់កាប់ការគ្រប់គ្រងប្រទេសខំចំរាញ់ឱសថមួយមុខដែលគេបំពោកពេញទាំងសាលាសិក្សាជាតិ តាំងពីកុមារដ្ឋានរហូតដល់

មហាវិទ្យាល័យ តែឥតទទួលផលល្អសោះ ហើយព្រោះហេតុអ្វី ! ឱសថនោះគឺធម្មក្រិត្យា ឬចរិយាសាស្ត្រអ្វីៗមួយពាន់មួយជំពូកទៀតបែបធុននេះ។ គេមិនលាងគំនិតខួរក្បាលមនុស្សបានទេបើគេមិនរំលើងបំបាត់ឫសកែវសម្ភារៈនៃគំនិតនេះការអប់រំតាមផ្លូវចិត្ត នឹងទទួលផលល្អតែកាលណាលក្ខខណ្ឌសង្គមមានអនុគ្រោះផងដែរ។[21]

**ខ. សមភាពក្នុងកិច្ចផលិតកម្ម**

សមភាពនេះមានន័យថាៈ អ្នកណាបានបង្កើតផលប៉ុន្មាន នឹងត្រូវទទួលផលប៉ុណ្ណោះ។ គោលការណ៍នេះសុចរិតណាស់ សមហេតុសមផល ជាមនុស្សធម៌ណាស់។ ធ្វើបានប៉ុន្មានត្រូវបានប៉ុណ្ណឹង។ ប៉ុន្តែយើងសង្កេតមើលទៅក្នុងសង្គមមូលធននិយមយើងពុំបានឃើញដូច្នេះទេ។ ពួកមេទុនដែលមានសព្វមានគ្រប់ប្រើមធ្យោបាយជញ្ជក់ញើសឈាម នៃកម្មករដើម្បីនឹងយកចំណេញកប់ក្តោង។ គេឲ្យឈ្នួល អ្នក**ទុគិតសម្រាប់ឲ្យតែអ្នកកម្មកររស់ទាំងត្រដរមានកម្លាំងល្មមត្រឹមតែស្អែកឡើងទៅធ្វើការឲ្យមេទុនទៀត**ប៉ុណ្ណោះ។ ដោយសារតែកម្មករវេទនាពេកបានជាគេឃើញនៅក្នុងបណ្តាប្រទេសមូលធននិយម កម្មករតស៊ូ តវ៉ានឹងមេទុន ដើម្បីទាមទារបៀវត្សន៍គ្រប់គ្រាន់ និងរស់នៅជាមនុស្ស។ ក្នុងការតស៊ូ តវ៉ា ទាមទាររស់នៅឲ្យបានសមរម្យកុំឲ្យខ្វះមុខ ខ្វះក្រោយពេក កម្មករតែងតែជួបប្រទះនឹងអំពើឃោរឃៅនៃពួកជិះជាន់ សង្កត់សង្កិន តបមកវិញដោយកម្លាំងប៉ូលីសទាហាន។ កម្មករឃើញថា នៅពីមុខការឃោរឃៅនៃពួករាតត្បាតដូច្នេះ មានតែសាមគ្គីរវាងអ្នករងគ្រោះ រងទុក្ខវេទនាទាំងអស់គ្នាទើបប្រឡេះកម្រៃខ្លះពីឈ្លើងមេទុន។ សហជីពគឺជាអង្គការមួយមានសារៈសំខាន់ណាស់សម្រាប់នាំកម្មករប្រយុទ្ធ ការពារសិទ្ធិរបស់ខ្លួននិងរស់នៅឲ្យសមល្មមនឹងកម្លាំងដែលខ្លួនចាយវាយដើម្បីបង្កើនផល។ ដូចបានពណ៌នាពីខាងលើសមភាពក្នុងឋានៈជាពលរដ្ឋ និងសមភាពនៅក្នុងកិច្ចផលិតកម្ម មិនមែនពេញបរិបូរណ៍ទេ ក្នុងរបបមូលធននិយម ដោយមានការបំពានរំលោភពីអ្នកជិះជាន់ទៅលើអ្នកណា បើមិនមែនអ្នកដែលត្រូវគេជិះជាន់នោះទេ ជនជំពូកនេះ ដើម្បីនឹងការពារសិទ្ធិរបស់ខ្លួនត្រូវសាមគ្គី រួមជាបាច់បង្កើតសហជីពធ្វើបាតុកម្មជាដើម។ ហេតុដូច្នេះហើយបានជានៅក្នុងបណ្តាប្រទេសប្រកាន់របបប្រជាធិបតេយ្យ គេឃើញមានអង្គការប្រជាធិបតេយ្យផ្សេងៗ សម្រាប់ការពារប្រយោជន៍នៃអ្នកធ្វើការ ដូចជា សហជីព និងសមាគមន៍វិជ្ជាជីវៈឯទៀតៗជាដើម។ អង្គការកាន់កាប់ការគ្រប់ប្រទេសនោះគឺកើតឡើងដោយចិត្តល្អ ស្មោះសរនៃពួកមេទុនកាន់កាប់ការគ្រប់គ្រងប្រទេសនោះ គឺកើត

[21] ណុប បូផាន់.សៀវភៅលទ្ធិប្រជាធិបតេយ្យ.ភ្នំពេញ.ឆ្នាំ១៩៥៦.ទំព័រទី៣៧-៤១

មានឡើងដោយសារកម្លាំងតស៊ូ តវ៉ានៃអ្នកធ្វើការងារដែលបានបង្ខំឲ្យមេទុនត្រូវទទួលស្គាល់សិទ្ធិនៃអ្នកត្រូវជិះជាន់ឲ្យមានអង្គការសម្រាប់ការពារប្រយោជន៍ពួកខ្លួន។ នេះជាដំណើរការសង្គមជាក់ស្តែងបង្ហាញមេរៀនឲ្យកម្មករឃើញថា មានតែកម្លាំងខ្លួនទេដែលអាចរំដោះទុក្ខខ្លួនបានឯកម្លាំងនោះឯង គឺកម្លាំងតស៊ូជាសកម្ម មិនមែនកម្លាំងត្អូញត្អែរ យំយែកអង្វរករសង្ឃឹមលើចិត្តសន្តានល្អនៃពួកមេទុនសោះឡើយ។ ម៉្យាងទៀតកម្លាំងកម្មករនឹងទៅជាកម្លាំងមានផលលុះត្រាតែកម្លាំងនៅផ្តុំគ្នាជាចាំបាច់ មានអង្គការនាំមុខប្តូរផ្តាច់ដែលមានទ្រឹស្តីត្រឹមត្រូវជាមូលដ្ឋាននៃកិច្ចប្រតិបត្តិការព្រោះដំណើរការសង្គមដើរទៅតាមលំអានរបស់ធម្មជាតិរបស់វាពុំអាចឃ្លាតបានឡើយ គោលការណ៍ទី៣ នៃលទ្ធិប្រជាធិបតេយ្យ។[22]

### ៤.៣. យុត្តិធម៌

គោលការណ៍យុត្តិធម៌នេះ គេច្រើនតែពុំសូវនឹកនាដល់វានោះទេក្នុងគំនិតនៃលទ្ធិប្រជាធិតេយ្យ។ កាលណាគេនិយាយអំពីលទ្ធិប្រជាធិបតេយ្យ គឺគេសំដៅតែត្រង់សេរីភាព និងសមភាពដែលយើងបានអធិប្បាយពីខាងលើរួចមកហើយ។ សេរីភាព និងសមភាពមិនទាន់គម្រប់លក្ខខណ្ឌនៃលទ្ធិប្រជាធិបតេយ្យបានទេត្រូវមានវត្ថុធាតុយុត្តិធម៌ទៀត ទើបបានពេញលេញ។យើងនឹងពិនិត្យយុត្តិធម៌ក្នុងនាទីពីរ៖ សង្គម និងច្បាប់ ។[23]

#### ១. ក្នុងនាទីសង្គមកិច្ច

យុត្តិធម៌ស្ថិតលើការដែលសិទ្ធិត្រូវឲ្យបានដល់ពលរដ្ឋទាំងអស់គ្នាជាទូទៅ។ រីឯសិទ្ធិប្រជាធិបតេយ្យសំខាន់ៗ ដូចជាសិទ្ធិក្នុងការបោះពុម្ពផ្សាយប្រជុំគ្នា។ មិនត្រឹមតែឲ្យកត់ចុះក្នុងឯកសារសម្រាប់រដ្ឋប៉ុណ្ណោះទេ អ្នកកាន់កាប់រដ្ឋត្រូវចាត់វិធានការណ៍យ៉ាងណា ឲ្យទាល់តែសិទ្ធិទាំងនេះបានទទួលការប្រតិបត្តិជារូបីយ៍ ដោយធ្វើសេចក្តីអនុគ្រោះសព្វបែបសព្វយ៉ាង ។

ឧទាហរណ៍៖ ដើម្បីនឹងបោះពុម្ពផ្សាយបានដំបូងបង្អស់សាមីខ្លួនត្រូវមានតំរិះវិជ្ជាយ៉ាងហោចណាស់ក៏ចេះអានចេះសរសេរដែរ។ រដ្ឋាភិបាលត្រូវតែពង្រីកនូវការសិក្សាជាតិឲ្យបានគឺយុត្តិធម៌ទូលំទូលាយ បង្កើតសាលារៀនឲ្យមានច្រើនសម្បុរឲ្យអាហារូបករណ៍ដល់សិស្ស និងនិស្សិតគ្រប់ប្រភេទសង់បណ្ណាល័យបោះពុម្ពសៀវភៅរៀនសូត្រឲ្យមានបរិបូរណ៍។ បើពុំដូច្នេះទេ ចំនួនអ្នករៀនសូត្របានតិចណាស់ ហើយសិទ្ធិក្នុងការបោះពុម្ពផ្សាយក៏បានជ្រាបដល់ប្រជាជនទូទៅ

---
[22] ណុប បូផាន់.សៀវភៅលទ្ធិប្រជាធិបតេយ្យ.ភ្នំពេញ.ឆ្នាំ១៩៥៦.ទំព័រទី៤១-៤៤

[23] ណុប បូផាន់.សៀវភៅលទ្ធិប្រជាធិបតេយ្យ.ភ្នំពេញ.ឆ្នាំ១៩៥៦.ទំព័រទី៤៤-៤៥

និងសន្មតទុកថាមានយុត្តិធម៌ពុំបាន។ មិនតែប៉ុណ្ណោះអ្នកដែលមានតំរិះវិជ្ជាហើយត្រូវតែមាននូវមធ្យោបាយគ្រប់គ្រាន់និងប្រើប្រាស់តំរិះវិជ្ជាខ្លួនទៀត បើពុំនោះសោតមានតែអ្នកមានទ្រព្យមួយក្តាប់ប៉ុណ្ណោះឯងដែលអាចប្រើតំរិះរបស់ខ្លួនបានការ។ រដ្ឋាភិបាលត្រូវរិះរកវិធានការណ៍យ៉ាងណាឲ្យបានបំពេញលក្ខខណ្ឌនេះទៀតទើបមានយុត្តិធម៌ ដូចជាការបង្កើតរោងពុម្ពជាតិ និងអង្គការជាតិសម្រាប់ចែកចាយក្រដាសទឹកខ្មៅឲ្យមានតម្លៃល្មមនឹងសន្ទុះថវិកាជនធម្មតា។

ឧទាហរណ៍មួយទៀត៖ ការប្រជុំគ្នានឹងធ្វើបានអាស្រ័យដោយមានមធ្យោបាយនិងសម្ភារៈគ្រប់គ្រាន់ដែរ ដូចជាផ្សាយដំណឹងប្រជុំដល់សាធារណជន គ្រឹះស្ថានសម្រាប់ប្រជុំ។ ដើម្បីផ្សាយដំណឹង និងជួលទីកន្លែងប្រជុំក៏សុទ្ធតែត្រូវការប្រាក់ទាំងអស់។ ម្ល៉ោះហើយជនធម្មតាដែលគ្មានភ័ព្វវាសនាល្អកើតមកជា ថៅតាប្រាក់ ហើយពុំអាចនឹងប្រើសេរីភាពប្រជាធិបតេយ្យនេះបានឡើយ។ នេះសឲ្យឃើញថាអយុត្តិធម៌ក្នុងនាទីសង្គមកិច្ចមានតែនៅលើក្រដាស ឬអាចនិយាយម៉្យាងទៅវិញក៏ត្រូវណាស់ដែរ មានតែថៅៗតា ប្រាក់ ពោលគឺជនមួយក្តាប់រាប់នឹងម្រាមដៃបាន ក្រេបឱជារសនៃយុត្តិធម៌ ចំណែកឯជនធម្មតារាប់លាននាក់ត្រូវប្រានចោលក្រៅក្របខ័ណ្ឌប្រើសិទ្ធិប្រជាធិបតេយ្យ ។[24]

### ២. ក្នុងនាទីច្បាប់

តាមអត្ថន័យច្បាប់គឺវិញ្ញត្តិនៃឆន្ទៈរបស់ប្រជាជាតិ។ ក្នុងអត្ថបទតូចមួយយើងនេះ យើងមិនពិនិត្យបញ្ហាប្រជាជាតិឲ្យជ្រៅជ្រះទេ យើងគ្រាន់តែជម្រាបក្នុងសង្គមវណ្ណៈប្រជាជាតិ គឺមិនមែនជាន់ថ្នាក់នេះ ពួកនោះ ឬបក្សណាទេ។ ប្រជាជាតិគឺទាំងអស់ប្រជុំផ្តុំគ្នាឡើងប្រកបទៅដោយយុត្តិធម៌ច្បាប់ត្រូវធ្វើសម្រាប់ប្រយោជន៍រួម តែដោយអពមង្គល មិនមែនដូច្នេះឡើយ ! ដូច្នោះហើយច្បាប់ត្រូវបម្រើប្រយោជន៍នៃភាគច្រើន។ នេះជាគំនិតនៃលទ្ធិប្រជាធិបតេយ្យចំពោះគោលការណ៍យុត្តិធម៌។ ប៉ុន្តែមេទុនក្រោយពីបានកាន់កាប់អំណាចស៊ុបកាលណា ឈ្លីនឹងជើងចោលនូវគំនិតសុចរិតល្អបរិសុទ្ធនេះ។ ដោយដំណើរសេដ្ឋកិច្ច ពួកមេទុនប្រែក្លាយទៅជាសត្រូវនឹងសម្ព័ន្ធមិត្តពីមុនវិញ ការនៅក្រោមការជិះជាន់របស់ពួកសក្តិភូមិទាំងអស់គ្នា ពោលគឺ កម្មករ កសិករ។ ក្នុងលក្ខខណ្ឌសេដ្ឋកិច្ចមូលធននិយម កម្មករ និងកសិករប្រមូលបានជាភាគច្រើនចំណែកឯមេទុនជាភាគតិច។ បើអនុវត្តគំនិតបរិសុទ្ធនេះមេទុនអ្នកជិះជាន់គេលែងធ្វើជាឈ្លើងទៀតបានហើយ។ ហើយដើម្បីរក្សាសភាពខ្លួន ជញ្ជក់ឈាមគេដោយសុខសាន្តឥតធ្វើការខ្លួនឯងនោះ ពួកនេះប្រើ

---

[24] ណុប បូផាន់.សៀវភៅលទ្ធិប្រជាធិបតេយ្យ.ភ្នំពេញ.ឆ្នាំ១៩៥៦.ទំព័រទី៤៥-៤៧

កម្លាំងរដ្ឋដែលខ្លួនកាន់កាប់ គឺកម្លាំងទាហាន ប៉ូលីស។ ច្បាប់សម្រាប់រដ្ឋទាំងប៉ុន្មាន គេអនុវត្តតែរវាងគ្នាហើយគេបង្កើតច្បាប់ផ្សេងៗទៀតសម្រាប់បង្រួញ និងរាគត្បាតសកម្មភាពគតិយុទ្ធនឹងវណ្ណៈកម្មករ កសិករ។ អ្វីៗដែលគេធ្វើបាន កម្មករ កសិករធ្វើមិនបាន។ អ្វីៗ ដែលគេធ្វើត្រូវ កម្មករនិងកសិករធ្វើខុស។ ច្បាប់សង្គមមូលធននិយមគឺច្បាប់សម្រាប់ការពារទូដែកមេទុន។[25]

## ៥. រដ្ឋធម្មនុញ្ញប្រជាធិបតេយ្យ

រដ្ឋធម្មនុញ្ញ ពុំមែនគ្រាន់តែគ្រោងនៃច្បាប់របស់ប្រទេសប៉ុណ្ណោះទេ ប៉ុន្តែគឺជាច្បាប់កំពូល ជាចំណងនៃច្បាប់ដែលចងផ្ដោបកត្តាសំខាន់២យ៉ាងគឺ ការប្រគល់អំណាច និងការកម្រិតព្រំដែននៃអំណាច។ លោកជេម្ស ម៉ាឌិសុន (James Madison) ប្រធានាធិបតីទី៦នៃសហរដ្ឋអាមេរិក បានពោលថា នៅក្នុងក្របខ័ណ្ឌរដ្ឋាភិបាល ដែលយកមនុស្សទៅគ្រប់គ្រងមនុស្សជាបន្តបន្ទាប់គ្នាបញ្ហាពិបាកស្ថិតនៅលើកត្តាដូចតទៅនេះ ដំបូងអ្នកត្រូវប្រគល់រដ្ឋអំណាចឲ្យរដ្ឋាភិបាលគ្រប់គ្រងត្រួតពិនិត្យទៅលើអ្នកដែលនៅស្រទាប់ខាងក្រោម បន្ទាប់មកអ្នកត្រូវបង្ខំរដ្ឋាភិបាលឲ្យត្រួតពិនិត្យទៅលើកិច្ចការរបស់ខ្លួនដោយខ្លួនឯងផ្ទាល់ (In framing a govemment which is to be administered by men over men the great difficulty lies in this you must first enable the govemment and in the next place oblige it control itself) ដូច្នេះ រដ្ឋធម្មនុញ្ញនៃរបបសាធារណរដ្ឋប្រជាធិបតេយ្យសេរីអនុញ្ញាតឲ្យរដ្ឋាភិបាលមានអំណាចគ្រប់គ្រងប្រជាពលរដ្ឋ នឹងអនុញ្ញាតឲ្យប្រជាពលរដ្ឋមានអំណាច ឆែកឆេរ ត្រួតពិនិត្យ ព្រមទាំងថ្លឹងថ្លែង ទៅលើនយោបាយគ្រប់គ្រងដឹកនាំ របស់រដ្ឋាភិបាលវិញដែរ។[26]

### ៥.១. ការយកអំណាចទៅឆែកឆេរលើអំណាច

ការយកអំណាចទៅឆែកឆេរលើអំណាច (checking power with power) ជាការចម្លែកមួយដែលរដ្ឋធម្មនុញ្ញនៃលទ្ធិប្រជាធិបតេយ្យកម្រិតព្រំដែនលើការអនុវត្តន៍ រដ្ឋអំណាចរបស់រដ្ឋាភិបាលនៅទន្ទឹមគ្នានឹងការចង់ឲ្យមានរដ្ឋាភិបាលមួយ ដែលមានប្រសិទ្ធិភាពខ្លាំងពូកែសម្រាប់ដឹកនាំប្រទេសជាតិមានឆន្ទៈនៃការស្វែងរកប្រសិទ្ធិភាព ឲ្យរដ្ឋាភិបាលមានអនុភាពខ្លាំពូកែ ពុំមែនមានន័យថាជាការបន្ធូរបន្ថយសិទ្ធិសេរីភាពនិងអំណាចរបស់ប្រជាពលរដ្ឋឡើយ។ ដូចទស្សនៈ វិទូប្លេច្ច

[25] ណុប បូផាន់.សៀវភៅលទ្ធិប្រជាធិបតេយ្យ.ភ្នំពេញ.ឆ្នាំ១៩៥៦.ទំព័រទី៤៧-៤៩

[26] ការ ដេវីដ សៀវភៅគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីនិយម.រដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក.ឆ្នាំ១៩៩៦.ទំព័រទី១៩

(Plato) និងអារីស្តូល (Anstotle) បានថ្លែងថារដ្ឋាភិបាលដែលខ្លាំងពូកែ គឺជារដ្ឋាភិបាល ដែលចេះបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋ។ មូលដ្ឋាននៃការកម្រិតព្រំដែនរដ្ឋអំណាចរដ្ឋាភិបាល គឺស្ថិតនៅលើការបោះឆ្នោតដោយសេរី ពីព្រោះវាជាមធ្យោបាយដែលអនុញ្ញាតឲ្យប្រជាពលរដ្ឋច្រានចោលអ្នកកាន់រដ្ឋអំណាចណាដែលរំលោភបំពានលើច្បាប់ ប្រព្រឹត្តអំពើឃោរឃៅជិះជាន់លើសិទ្ធិសេរីភាពប្រជាពលរដ្ឋ។ សំនួរមួយសួរថា តើគេត្រូវធ្វើយ៉ាងណា បើសិនជាបុគ្គលដែលប្រជាពលរដ្ឋទុកចិត្ត និងបោះឆ្នោតជ្រើសរើសឲ្យឡើងទៅកាន់ដំណែងជាអ្នកដឹកនាំនោះ ប្រែក្លាយទៅជាជនផ្តាច់ការនិយមទៅវិញ? ក្នុងករណីនេះ ប្រជាពលរដ្ឋដែលជាម្ចាស់អំណាច ម្ចាស់ទឹកដី ម្ចាស់នគរ ត្រូវប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋធម្មនុញ្ញ ដែលផ្អែកលើស្ថាប័ននៃលិទ្ធិប្រជាធិបតេយ្យសេរីជាមូលដ្ឋានដើម្បីប្រឆាំងជំទាស់នឹងសភាពការណ៍ដ៏អាក្រក់របស់មេដឹកនាំ។[27]

### ៥.២. ការបែងចែកអំណាច

ជំហានទីមួយនៃការបែងចែកអំណាច (separation of powers) គឺការផ្តល់ដល់អង្គការទាំងបីរបស់រដ្ឋាភិបាល នូវច្បាប់នៃការឆែកឆេរនិងថ្លឹងថ្លែង (checks and baiances) ចំពោះគ្នាទៅវិញទៅមក។ កង្វះនៃការបែងចែកអំណាច និងជាកត្តានាំឆ្ពោះទៅរកការក្តោបក្តាប់យករដ្ឋអំណាចទាំងមូលតែម្តង ហើយដែលគេហៅថា អំណាចផ្តាច់ការនិយម។ គ្រោះថ្នាក់នៃលទ្ធិប្រជាធិបតេយ្យសេរី ប្រាកដជានឹងកើតមានឡើង នៅពេលណាដែលក្រុមល្មោភអំណាចក្នុងអង្គការទាំងបីរបស់រដ្ឋាភិបាលគឺ នីតិប្រតិបតិបត្តិ និតិប្បញ្ញត្តិ និងតុលាការ រួមគ្នា ចែកផលប្រយោជន៍ដល់គ្នា ប្រព្រឹត្តសកម្មភាពជាមួយគ្នា ដើម្បីកាន់កាប់យករដ្ឋអំណាចឲ្យបានយូរអង្វែង។[28]

### ៥.៣. ការឆែកឆេរនិងថ្លឹងថ្លែង

ការឆែកឆេរនិងថ្លឹងថ្លែង (checks and baiances) គឺជាសន្តិសុខដ៏ចំបង ដែលការពារចំពោះការប្រមូលផ្តុំ ការក្រសោបឱបយកអំណាច នៃអង្គការណាមួយរបស់រដ្ឋាភិបាល។ វាជាការផ្តល់ដល់ក្រុមកាន់រដ្ឋអំណាចនៃអង្គភាពនីមួយៗ នូវមធ្យោបាយគ្រប់គ្រាន់សម្រាប់ត្រួតពិនិត្យនិងឆែកឆេរការអនុវត្តិនៃអំណាចគ្នាទៅវិញទៅមក ពោលគឺគេត្រូវបង្កើតមហិច្ឆតាដើម្បីផ្ទាញ់ផ្ទាល

[27] ការ ដេវីដ សៀវភៅគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីនិយម.រដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក.ឆ្នាំ១៩៩៦.ទំព័រទី១៩-២០

[28] ការ ដេវីដ សៀវភៅគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីនិយម.រដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក.ឆ្នាំ១៩៩៦.ទំព័រទី២០-២១

ចំពោះមហិច្ឆតា (ambition must made to counteract ambition)។ អង្គភាពនីមួយៗត្រូវមានទំនាក់ទំនងពាក់ព័ន្ធជាមួយគ្នាដូចជា អង្គការសភា មានអំណាចតាក់តែងច្បាប់ រីឯប្រធានាធិបតីគឺមានអំណាចជំទាស់នឹងគោលការណនៃច្បាប់តាក់តែងដោយក្រុមសភា។ ប្រធានាធិបតីគឺមានអំណាចចាយវាយថវិការជាតិ រីឯសភា ក៏មានអំណាចកម្រិតការចាយវាយនោះដែរ។ តុលាការកំពូល (supreme court) មានអំណាចប្រកាសបដិសេធលើគំរោងច្បាប់ ដែលអនុម័តដោយរដ្ឋសភានិងចុះហត្ថលេខាដោយប្រធានាធិបតី បើសិនជាគំរោងច្បាប់នោះ មានភាពអវិជ្ជមានមិនស្របតាមច្បាប់រដ្ឋធម្មនុញ្ញ។ ប្រធានាធិបតីមានសិទ្ធិអំណាចតែងតាំងតុលាការកំពូល ប៉ុន្តែការតែតាំងនោះក៏ត្រូវតែមានការយល់ព្រមពីព្រឹទ្ធសភា។ ប្រធានាធិបតីយកច្បាប់ទៅអនុវត្តន៍នៃច្បាប់នោះ។ ក្រុមព្រឹទ្ធសភា និងក្រុមតំណាងរបស់ប្រជាពលរដ្ឋមានអំណាចជំទាស់ (veto) លើការរៀបចំតាក់តែងច្បាប់ទម្លាប់របស់គ្នាទៅវិញទៅមក ពីព្រោះគំរោងច្បាប់ត្រូវតែទទួលការយល់ព្រមពីអង្គភាពទាំងពីរនេះជាដាច់ខាតមុននឹងបញ្ជូនទៅឲ្យ អង្គការនីតិប្រតិបត្តិអនុវត្ត។ ចំពោះអង្គភាពនីមួយៗ ដែលជាមែកធាងនៃរដ្ឋាភិបាលពុំគ្រាន់តែមានអំណាចឆែកឆេរនិងត្រួតពិនិត្យ លើគ្នាទៅវិញទៅមកប៉ុណ្ណោះទេ តែអង្គការទាំងនោះមានអំណាចឯករាជ្យដាច់ដោយឡែកចេញពីគ្នា។ ទង្វើនេះជាមធ្យោបាយដ៏ល្អប្រពៃដែលអាចឲ្យអង្គការនីមួយៗ ធ្វើការសម្រេចចិត្តរបស់ខ្លួនដោយខ្លួនឯងប្រកបដោយការទទួលខុសត្រូវខ្ពស់ និងមិនរណបចុះញ៉មក្រោមរដ្ឋអំណាចនៃអង្គភាពណាមួយផ្សេងទៀត។ ដោយសាររដ្ឋធម្មនុញ្ញប្រជាធិបតេយ្យនៃរបបសាធារណរដ្ឋ លើកតម្កើនអំណាចប្រជាពលរដ្ឋឲ្យធំជាងអ្វីៗទាំងអស់ដូច្នេះការប្រើអំណាចរបស់ប្រធានាធិបតី ដែលជាមេដឹកនាំប្រទេសជាតិ ត្រូវស្ថិតនៅក្នុងស្ថានភាពមួយ ក្រោយការឃ្លាំមើលរបស់ប្រជាពលរដ្ឋជានិច្ច។ ទាំងប្រធានាធិបតី ទាំងក្រុមសភាទាំងពីររបស់ជាតិ ត្រូវតែបានទទួលការជ្រើសរើសដោយប្រជាពលរដ្ឋ។ រីឯតុលាការកំពូលវិញ ទោះបីគេទទួលការតែងតាំងពីប្រធានាធិបតីក៏ដោយក៏ការចាត់តាំងនោះត្រូវតែមានការទទួលស្គាល់ និងការយល់ព្រមពីអង្គការសភាជាតិទាំងពីរក្រុមជាដាច់ខាតទើបអាចចាត់ទុកថាត្រឹមត្រូវតាមច្បាប់បាន។ រដ្ឋធម្មនុញ្ញប្រជាធិបតេយ្យអនុញ្ញាតឲ្យ ចៅក្រមតុលាការកំពូល កាន់ដំណែងធ្វើការអស់មួយជិវិត។ ទង្វើលនេះគឺជាយុទ្ធវិធីមួយដែលរាំងស្ទះមិនឲ្យចៅក្រមតុលាការ ស្ថិតនៅក្រោមអំណាចបញ្ជារបស់ប្រធានាធិបតី ឬក្រោមអំណាចរបស់សភាជាតិឡើយ។ លទ្ធិប្រជាធិបតេយ្យបង្កើតឡើងនូវវិធានការសម្រាប់ការពារ សមភាព និងយុត្តិធមនៃការបែងចែករដ្ឋអំណាចរបស់អង្គការទាំង៣ ឲ្យស្ថិតស្ថេរយូរអង្វែង។ ការបែងចែករដ្ឋអំណាចក្តី

ការផែកឆេរនិងថ្លឹងថ្លែងក្តី ជារូបមន្តសម្រាប់បំបាត់ការស្រវ៉ាក្តាប់យករដ្ឋអំណាច នៃក្រុមដែលមានសម្លេងភាគច្រើននៅក្នុងរង្វង់ រដ្ឋាភិបាល និងចៀសវាងកុំឲ្យមានការហួងហែងអសនៈរដ្ឋាភិបាល ដើម្បីបម្រើកិច្ចការផ្ទាល់ខ្លួន និងរបស់បក្សពួកខ្លួន។ ដូច្នេះរដ្ឋធម្មនុញ្ញនៃរបបសាធារណរដ្ឋប្រជាធិបតេយ្យសេរីការពារមិនឲ្យមាន ការប្រមូលផ្តុំរដ្ឋអំណាចធ្លាក់ទៅក្នុងកណ្តាប់ដៃបុគ្គលណាមួយ ឬ គណៈបក្សណាមួយ និងការពារមិនឲ្យអង្គការនីមួយៗនៃរដ្ឋាភិបាល យកអំណាចទៅប្រើហួសពីរង្វង់អំណាចដែលខ្លួនមាន។ ជាពិសេសនោះគឺការពារកុំឲ្យមានការរំលោភបំពាន ពីសំណាក់ក្រុមអាជ្ញាធរកាន់រដ្ឋអំណាច ទៅលើសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋខ្លួន។[29]

សរុបសេចក្តីមកប្រជាធិបតេយ្យមានដើមកំនើតដំបូងគេបង្អស់នៅប្រទេសក្រិច ដែលជាលទ្ធិមួយចាត់ទុកប្រជាពលរដ្ឋជាធំ ប្រជាពលរដ្ឋជាម្ចាស់ប្រទេស។ ទ្រឹស្តីសកលលោកបានទទួលស្គាល់ថាប្រជាពលរដ្ឋមានសិទ្ធិក្នុងការសម្រេចជោគវាសនាប្រទេសជាតិតាមរយៈ ការបោះឆ្នោតឲ្យតំណាងរបស់ខ្លួន។ តំណាងដែលឈ្នះក្នុងលទ្ធផលបោះឆ្នោតត្រូវបង្កើតរដ្ឋាភិបាលដើម្បីបម្រើរាស្ត្រ ហើយប្រជាពលរដ្ឋមានសិទ្ធិទម្លាក់នាយករដ្ឋមន្ត្រីតាមរយៈ ការបោះឆ្នោតប្រសិនបើរដ្ឋាភិបាលនោះមិនបានបំពេញនូវកាតព្វកិច្ចរបស់ខ្លួនបានល្អនោះទេ។ ប្រជាពលរដ្ឋនៅក្នុងប្រទេសប្រជាធិបតេយ្យមានសិទ្ធិសេរីភាពពេញលេញក្នុងការបញ្ចេញមតិ សេរីភាពទទួលបានភាពយុត្តិធម៌ សេរីភាពក្នុងការផ្សព្វផ្សាយនិងទទួលបានព័ត៌មាន។ ការដឹកនាំបែបប្រជាធិបតេយ្យត្រូវមាន រដ្ឋធម្មនុញ្ញមួយដែលស្របទៅគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យដែលជាទ្រឹស្តីពិភពលោក ហើយការបង្កើតច្បាប់ក៏ត្រូវតែស្របទៅតាមរដ្ឋធម្មនុញ្ញផងដែរ។

[29] ការ ដេវីដ សៀវភៅគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីនិយម.រដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក.ឆ្នាំ១៩៩៦.ទំព័រទី២១-២៣

# ជំពូកទី២ : លទ្ធិប្រជាធិបតេយ្យ នៅកម្ពុជា ២០១៣-២០១៨

## ១. ប្រវត្តិលទ្ធិប្រជាធិបតេយ្យ នៅកម្ពុជា

ប្រទេសកម្ពុជាគឺជារដ្ឋមួយដ៏បុរាណជាងគេ ហើយធ្លាប់មានអរិយធម៌ខ្ពង់ខ្ពស់នៅអាស៊ីអាគ្នេយ៍ ពិសេសក្នុងសម័យអង្គរដ៏រុងរឿងដែលពិភពលោកទទួលស្គាល់ក្នុងរវាងសតវត្សរ៍ទី៩ ដល់ទី១៥។ ហើយ ប្រទេសមួយនេះមានប្រជាជនរស់នៅតាំងពីរាប់ពាន់ឆ្នាំមុនគ្រឹស្តសករាជមកម្លេះ ព្រមទាំងបានកសាងនូវវប្បធម៌ អរិយធម៌ របស់ខ្លួនរួចជាស្រេចមុនវប្បធម៌អរិយធម៌ បរទេសហូរចូលមក។ ក្នុងន័យនេះមិនមែនយើងអភិរក្សវប្បធម៌ជាតិខ្លួនហួសហេតុពេកទេ តែអ្វីដែលល្អត្រឹមត្រូវ សមស្រប ប្រហាក់ប្រហែលនឹងទំនៀមទម្លាប់ប្រពៃណីខ្មែរនោះយើងគួរតែទទួលយកដោយគ្មានញញើតឡើយ ប៉ុន្តែអ្វីដែលមិនល្អត្រឹមត្រូវ មិនសមស្រប និងធ្វើឲ្យមានការប៉ះពាល់ដល់អារម្មណ៍ ឬការរស់នៅរបស់ប្រជាពលរដ្ឋខ្មែរនោះ យើងត្រូវតែបោះបង់ចោលដោយពុំមានការសោកស្តាយស្រណោះអ្វីឡើយ។ យ៉ាងណាមិញលទ្ធិប្រជាធិបតេយ្យក៏ដូចគ្នានេះដែរ យើងពុំអាចយកវាទាំងស្រុងពីក្រៅប្រទេសនោះទេ គឺយើងចេះកែច្នៃឲ្យមានលក្ខណៈសមស្របទៅតាមវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ខ្មែរ។ យោងទៅតាមការសិក្សាស្រាវជ្រាវអំពី ការវិវត្តន៍របស់មនុស្សខ្មែរតាមបណ្តាស្ថានីយ៍បុរេប្រវត្តិនានាឃើញថា ការវិវត្តន៍របស់មនុស្សខ្មែរក៏មានលក្ខណៈស្រដៀងគ្នាទៅនឹង ការវិវត្តន៍របស់មនុស្សនៅលើសកលលោកដែរ ហើយធាតុនៃលទ្ធិប្រជាធិបតេយ្យនេះក៏កើតមានការវិវត្តន៍បត់បែនតាមដំណាក់កាលប្រវត្តិសាស្ត្រផងដែរ។ ប៉ុន្តែគ្រាន់តែពុំមានរូបភាពច្បាស់លាស់ ឬកំណត់ន័យ និងតាក់តែងបែបផែនដំណើរការនោះក៏គ្មានឡើយ គ្រាន់តែសង្កេតទៅតាមរយៈនៃការរស់នៅរបស់ពួកគេ ដូចជាការមិនចង់ឲ្យអ្នកណាកេងប្រវ័ញ្ចលើញើសឈាមខ្លួនបំបិទសិទ្ធិសេរីភាព មានការទាមទារសេរីភាពនេះជាហូរហែ ចង់បានអ្នកដឹកនាំពូកែ នាំសេចក្តីសុខ និងការរីកចម្រើនជូនប្រទេសជាតិ។ ធាតុទាំងនេះហើយដែលមនុស្សលោកតែងតែមានតាំងពីយូរលង់ណាស់មកហើយ។ នៅក្នុងប្រទេសកម្ពុជាយើងធាតុនៃលទ្ធិប្រជាតិបតេយ្យនេះ បានកើតឡើងជាលំដាប់លំដោយពីសម័យមួយទៅសម័យមួយ ហើយគួរឲ្យកត់សម្គាល់ជាងគេនោះគឺនៅសម័យមហានគរដ៏រុងរឿង ព្រះមហាក្សត្រទ្រង់ប្រទាននូវសវនាការពីរដងក្នុងមួយថ្ងៃសម្រាប់ការដោះស្រាយបញ្ហារាជកិច្ច។ ត្រង់នេះហើយក្នុងសង្គមកម្ពុជាបច្ចុប្បន្នដែល

កំពុងកាន់របបលទ្ធិប្រជាធិតេយ្យ ក៏កំពុងអនុវត្តតាមលំនាំឥរិយាបថប្រជាធិបតេយ្យនេះដែរ។[30] លក្ខណៈបែបនេះ គឺគ្រាន់តែជាទំនៀមទម្លាប់របស់ប្រជាជនខ្មែរដែលកើតមានតាំងពីសម័យយូរលង់មកហើយ។[31] ឯការដែលសំខាន់នោះត្រង់អ្នកដឹកនាំកំពូលរបស់ប្រទេសជាតិចេះធ្វើការដោះស្រាយបញ្ហាផ្សេងៗ ជូនដល់ប្រជារាស្ត្រដោយមានការពិភាក្សាជាមួយមន្ត្រីតូចធំនូវអ្វីដែលប្រជារាស្ត្រកើតទុក្ខមិនសុខចិត្ត ផ្តល់ឱកាសឲ្យរាស្ត្របញ្ចេញមតិនានា ដែលពាក់ព័ន្ធទៅនឹងការរស់នៅរបស់ពួកគេ។ មានន័យថាទុក្ខរបស់ប្រជារាស្ត្រ គឺជាទុក្ខរបស់ព្រះអង្គ នេះគឺជាព្រះរាជបន្ទូលរបស់ព្រះបាទជ័យវរ្ម័នទី២។ បញ្ជាក់កាន់តែច្បាស់ទៅទៀតនោះគឺ ដើម្បីរំដោះប្រទេសជាតិទាមទារសិទ្ធិសេរីភាពពីពួកជ្វា ព្រះរាជាខ្មែរ ព្រះបាទជ័យវរ្ម័នទី២ មុននឹងឡើងគ្រងរាជព្រះអង្គបានធ្វើការបង្រួមបង្រួមទឹកដីឲ្យបានសិន ទ្រង់ក៏បានបង្កើតពិធីថ្មីមួយហៅថា ពិធីទេវរាជ ក្នុងគោលបំណងឲ្យខ្មែររួចផុតពីចំណុះជ្វា។ សូមរំលឹកផងដែរថា នៅវាងចុងសតវត្សរ៍ទី៨ ប្រទេសខ្មែរត្រូវបែងចែកទឹកដីជាពីរ គឺចេនឡាដីគោក និងចេនឡាទឹកលិច ហើយចេឡាទឹកលិចនេះត្រូវបែងចែកជាក្សត្របុរីជាច្រើន។ ឆ្លៀតឱកាសដែលខ្មែរកំពុងតែ ទន់ខ្សោយបែកបាក់គ្នាយ៉ាងនេះ ជនជាតិជ្វា ក្រោមការដឹកនាំរបស់រាជវង្ស សៃលេន្ទ្រ បានលើកទ័ពមករាតត្បាតដុតបំផ្លាញក្រុងសម្ភុបុរៈ ចាប់បានព្រះរាជាខ្មែរជាចំណុះថែមទៀត...។ យើងសង្កេតឃើញថាការធ្វើពិធីនេះដំណើរការទៅប្រកបដោយជោគជ័យ មិនមែនតែព្រះរាជាមួយអង្គឯងគត់ដែលអាចសម្រេចបាននោះទេ គឺត្រូវមានការចូលរួមពីមនុស្សគ្រប់ស្រទាប់វណ្ណៈ ទាំងមន្ត្រីតូច ធំ និងប្រជារាស្ត្រ សហការឯកភាពគ្នាតាមមតិភាគច្រើននិងចេះស្គាល់អ្វីដែលហៅថាសិទ្ធិសេរីភាព ជៀសវាងស៊ូទ្រាំឲ្យគេជិះជាន់សង្កត់សង្កិន បំបិទសិទ្ធិសេរីភាព និងដកហូតទ្រព្យសម្បត្តិតាមតែអំពើចិត្ត។ ផ្ទុយទៅវិញបើការរៀបចំលទ្ធិទេវរាជរបស់ព្រះបាទជ័យវរ្ម័នទី២ មានកំហិតផ្តាច់ការឃោរឃៅ សម្រាប់បម្រើតែប្រយោជន៍ផ្ទាល់ខ្លួន ឬក្រុមញាតិវង្សរបស់ព្រះអង្គខុសពីគោលការណ៍ប្រជាធិតេយ្យនោះផែនការរបស់ទ្រង់អាចបរាជ័យ។

នៅក្នុងសម័យអាណានិគមនិយមបារាំងវិញ ថ្វីត្បិតតែប្រជាពលរដ្ឋខ្មែររស់នៅក្រោមអាណានិគមនិយមបារាំងក៏រូបភាពប្រជាធិបតេយ្យមួយចំនួនរដ្ឋាភិបាលបារាំងមិនលុបបំបាត់ ឬបំបិទ

[30] អ៊ុំ សុភក្តិ.ហេង ឌី.អែល យុន. លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅកម្ពុជា.ឆ្នាំ២០០៦.ទំព័រទី
[31] អ៊ុំ សុភក្តិ.ហេង ឌី.អែល យុន. លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅកម្ពុជា.ឆ្នាំ២០០៦.ទំព័រទី១៧

ទាំងស្រុងដែរ ដូចជាសិទ្ធិធ្វើដំណើរ សិទ្ធិនិយាយស្តី និងសារព័ត៌មាន ពិសេសសិទ្ធិរស់រានមានជីវិតជាដើម ជាក់ស្តែងព្រឹត្តិការណ៍ថ្ងៃទី១៨ ខែមេសាឆ្នាំ១៩២៦ ប្រជាពលរដ្ឋរស់នៅភូមិក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង បានងើបឡើងតស៊ូប្រឆាំងនឹងរបបអាណានិគមនិយមបារាំង និងផ្តែបម្រើ រហូតដល់សម្លាប់ លោក បាដែល រ៉េស៊ីដង់បារាំងប្រចាំខេត្ត ដើម្បីទាមទារ នូវសិទ្ធិសេរីភាពក្នុងខេត្តរបស់ខ្លួនក៏ដូចជាសិទ្ធិសេរីភាពប្រជាជនទូទាំងប្រទេស។ នេះហើយជាសញ្ញាណនៃការរីកចម្រើនប្រជាធិបតេយ្យនៅកម្ពុជាយើង។ រីឯនៅចុងសម័យអាណានិគមនិយមបារាំងការរីកចម្រើនឥតឈប់ឈរនៃលទ្ធិប្រជាធិបតេយ្យនៅក្នុង សង្គមខ្មែរ ហើយលេចរូបរាងកាន់តែច្បាស់លាស់ក្នុងរវាងឆ្នាំង ១៩៤៦ ដោយព្រះអង្គម្ចាស់ ស៊ីសុវត្ថិ យុត្តិវង្ស ដែលជាស្ថាបត្យករ និងវិចិត្រករនៃលទ្ធិប្រជាធិបតេយ្យ រួមជាមួយក្រុមការងាររបស់ព្រះអង្គជាច្រើននាក់ទៀត ដូចជាលោក អៀវ កើស លោក ឈាន វ៉ម និងលោក ស៊ឹម វ៉ា ជាដើម ។ ថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៤៦ គឺជាថ្ងៃដែលគណបក្សប្រជាធិបតេយ្យដំបូងបង្អស់ចាប់កំណើតនៅប្រទេសកម្ពុជា។ ពេលនោះលោក ឈាន វ៉ម ជាអគ្គលេខាធិការ លោក អៀវ កើស និងលោក ស៊ឹម វ៉ា ជាសមាជិកស្ថាបនិក។ គណបក្សនេះបានយកសញ្ញារូបដំរី កាន់ផ្កាឈូកបី ជានិមិត្តរូបតំណាងពាក្យស្លោកថា ជាតិ សាសនា ព្រះមហាក្សត្រ បាវចនាជាតិនេះ គឺជាបន្ទាត់គោលនយោបាយរបស់គណបក្សតែម្តង។ មិនតែប៉ុណ្ណោះគណបក្សនយោបាយនេះ បានបង្កើតការសែតពីរគឺ កាសែតប្រជាធិបតេយ្យ ជាភាសាខ្មែរ និងកាសែតដេម៉ូក្រាត ជាភាសាបារាំង។ សូមបញ្ជាក់ថាព្រះអង្គម្ចាស់ ស៊ីសុវត្ថិ យុត្តិវង្ស ពុំមានងារជាផ្លូវការនៅក្នុងគណបក្សនោះទេ តែព្រះអង្គត្រូវបានគេផ្តល់នូវកិត្តិនាមជាវីរៈជនស្នេហាជាតិខ្មែរមួយរូបមានប្រាជ្ញាឈ្លាសវៃ និងបានបង្កើតប្រជាធិបតេយ្យនៅកម្ពុជានាពេលនោះ។ ចាប់ពីពេលនោះមកលទ្ធិប្រជាធិតេយ្យនេះហាក់បីដូចជាកប់បាត់ទៅក្នុងស្រទាប់មហាជន ឬផ្នត់គំនិតរបស់អ្នកដឹកនាំខ្មែរ ត្បិតពាក្យនេះមិនបានប្រើប្រាស់ជាផ្លូវការ ក្នុងរបបនយោបាយក៏ដោយ ប៉ុន្តែធាតុ និងរូបភាពនៃលទ្ធិនេះ ក៏ត្រូវបានគេយកមកប្រើប្រាស់លាយឡំជាមួយនិន្នាការថ្មីៗ របស់ចរិតលក្ខណៈអ្នកដឹកនាំខ្មែរផងដែរ ។[32] ក្នុងសម័យសង្គមរាស្ត្រនិយម ដែលគ្រប់គ្រងដោយសម្តេចព្រះបាទ នរោត្តម សីហនុ ត្បិតថារបបនេះជារបបរាជានិយមពិតមែន ក៏ព្រះអង្គបានយករូបភាពប្រជាធិបតេយ្យនេះមកប្រើប្រាស់ជាច្រើនដែរ ដូចជានៅចុងរាជ្យរបស់ព្រះអង្គ មានសារព័ត៌មានប្រឆាំងជាច្រើនបានបង្កើតឡើង រួមទាំងគណបក្សប្រឆាំងផងដែរ។ ពេលនោះព្រះអង្គ

[32] អ៊ុំ សុភក្តិ.ហេង ឪ.អែល យុន. លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅកម្ពុជា.ឆ្នាំ២០០៦.ទំព័រទី១៨-១៩

បានដាក់រាជ្យហើយបានបង្កើតគណបក្សនយោបាយមួយដើម្បីធ្វើការប្រកួតប្រជែងគ្នា។ ក្រៅពីនេះយើងឃើញមានសិទ្ធិជាច្រើនត្រូវបានរាជរដ្ឋាភិបាលផ្តល់ជូនប្រជារាស្ត្រ ដូចជាសិទ្ធិក្នុងការប្រកបរបរចិញ្ចឹមជិវិត សិទ្ធិមានជិវិត សិទ្ធិក្នុងការសិក្សា។ លើសពីនេះកាលពីថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៤៦ ព្រះបាទសម្តេចនរោត្តម សីហនុវរ្ម័ន ទ្រង់បានប្រកាសប្រទានសិទ្ធិបីយ៉ាងដល់ពលរដ្ឋ សិទ្ធិទាំងនោះមានសេរីភាពសារព័ត៌មាន សិទ្ធិបង្កើតសមាគម និងសិទ្ធិប្រជុំគ្នា។ ទាំងអស់នេះគឺចង់ឆ្លុះបញ្ចាំងឲ្យឃើញពីនិរន្តរភាពនៃលទ្ធិប្រជាធិបតេយ្យ ដែលមានអត្ថិភាព និងបន្តជីវិតជាយូរមិនដាច់ក្នុងសង្គមខ្មែរយើង។ តែគួរឲ្យសោកស្តាយ ពន្លកនៃលទ្ធិប្រជាធិបតេយ្យខ្មែរត្រូវរលាយទាំងស្រុង ក្នុងដែកម្ពុជាប្រជាធិបតេយ្យ ដែលមាន ប៉ុល ពត ជាមេក្លោង រួមជាមួយបក្សពួកជាច្រើននាក់ទៀត។ សម័យនោះពួកនេះបានបំបិទអស់នូវសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ព្រមទាំធ្វើការកាប់សម្លាប់មកលើប្រជាពលរដ្ឋស្លូតត្រង់ ហើយគេចាត់ទុកប្រជាពលរដ្ឋដូចសត្វធាតុ។ លុះថ្ងៃរំដោះ ៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាបានរស់រានមានជីវិតឡើងវិញ មានសិទ្ធិសេរីភាព គ្មានការកាប់សម្លាប់។ ថ្វីត្បិតពេលនោះប្រទេសកម្ពុជាពុំទាន់មានសន្តិភាព ស្ថេរភាពពេញលេញ និងប្រកាន់យករបបប្រជាធិបតេយ្យនៅឡើយក៏ដោយ តែរូបភាពមួយចំនួននៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា បានយកចិត្តទុកដាក់ និងអនុវត្តជាហូរហែ ដូចជាការផ្តល់សិទ្ធិសេរីភាពក្នុងការរស់នៅ ក្នុងការប្រកបអាជីវកម្ម ក្នុងការនិយាយស្តីជាដើម ទាំងអស់នេះហើយជាធាតុ និងរូបភាព ដែលជាចំណុចចាប់ផ្តើមនៃលទ្ធិប្រជាធិបតេយ្យ។ តែក្រោយមកដោយសារចលនានៃការរីកចម្រើនផ្លាស់ប្តូរនៃសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងចរន្តនិន្នាការរបស់បណ្តាប្រទេសមហាអំណាចសេដ្ឋកិច្ចនាសម័យសកលភាវូបនីយកម្ម ដែលតម្រូវឲ្យប្រទេសកម្ពុជាត្រូវដើរតាមចរន្តនៃការអភិវឌ្ឍន៍របស់ខ្លួនឲ្យកាន់តែរីកចម្រើន ទៅមុខនោះ ចាំបាច់តម្រូវឲ្យប្រទេសកម្ពុជាងាកទៅរករបត់ថ្មីមួយ ដែលជានិន្នាការរបស់ប្រទេសជាច្រើននៅលើសកលលោកកំពុងអនុវត្ត របត់ថ្មីនោះគឺ របបប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស។ ដោយសារមានរបត់ថ្មី និងដោយសារការរលំរលាយនៃសង្គ្រាមត្រជាក់ នាឆ្នាំ១៩៩១ នៅពេលដែលកំផែងនៃទីក្រុងប៊ែរឡាំង (Berlin) ត្រូវបានដួលរលំផងនោះ និងដោយសារសុឆន្ទៈស្វែងរកសន្តិភាពរបស់ភាគីខ្មែរជម្លោះទាំងបួនភាគីផងនោះ ទើបលេចឡើងនូវកិច្ចព្រមព្រៀងសន្តិភាពក្រុងបារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ បានផ្តល់ផ្លែផ្កាជាធំធេងណាស់សម្រាប់ប្រទេសកម្ពុជា ព្រោះបានធ្វើឲ្យ ភាគីខ្មែរ

ជម្លោះទាំងបួនភាគីចូលមកកាន់តុចរចា ដោយបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះទាំងបួនភាគី ក្រោមអធិបតីភាពនៃអង្គការសហប្រជាជាតិ។[33] កិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងបារីស បានចែងថា ប្រទេសកម្ពុជានឹងសន្យាធានាគោរព និងប្រតិបត្តិសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននៅកម្ពុជា។ ផ្តើមចេញពីកិច្ចព្រមព្រៀងនេះហើយបានធ្វើឲ្យប្រទេសកម្ពុជាឆ្លងកាត់ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រចំនួន៥លើក គឺនៅឆ្នាំ ១៩៩៣ ១៩៩៨ និងឆ្នាំ២០០៣ ២០០៨ និងឆ្នាំ២០១៣ ដែលបានផ្តល់នូវទស្សនីយភាពនៃការបោះឆ្នោតទាំ៥លើកនេះថា មានកម្រិតអន្តរជាតិ ហើយបានប្រដេញទៅរកលទ្ធិប្រជាធិបតេយ្យ។ តាំងពីពេលនោះពាក្យប្រជាធិបតេយ្យនេះ បានក្លាយទៅជាមានប្រជាប្រិយភាពជិតដាមក្នុងអារម្មណ៍ប្រជាពលរដ្ឋខ្មែរគ្រប់ស្រទាប់វណ្ណៈក្នុងសង្គមកម្ពុជា។ ចំពោះអ្នកដឹកនាំប្រទេសវិញ ពាក្យប្រជាធិបតេយ្យនេះនៅតែជាបញ្ហាចោទថ្មីស្មុគស្មាញក្នុងអារម្មណ៍ ពីព្រោះថាវាមានការលំបាកយ៉ាងច្រើនក្នុងការបង្វែរចលនាសម្ព័ន្ធគ្រប់គ្រងសង្គមចាស់ឲ្យស៊ីសង្វាក់ទៅនឹងប្រព័ន្ធថ្មីនេះ។ អាស្រ័យហេតុនេះហើយបានហើយបានជារដ្ឋាភិបាលកម្ពុជា យកបញ្ហាទាំងនេះទៅតាក់តែងចងក្រងក្នុងច្បាប់រដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ជាតិ។ ច្បាប់នេះបានចែងថា ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស។ ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិខ្លួន។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋខ្មែរប្រើអំណាចរបស់ខ្លួនតាមរយៈ រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជម្រះក្តី។ លើសពីនេះទៀតរាល់ស្មារតីច្បាប់ និងផែនការនានា ដែលបានប្រសូតឡើងរបស់រដ្ឋាភិបាល ត្រូវតែឈរលើគោលការណ៍ប្រជាធិបតេយ្យទាំងអស់។ តួយ៉ាងផែនការមេនៃការកែទម្រង់កិច្ចការរដ្ឋាភិបាល ដែលមានសម្តេច ហ៊ុន សែន នាយរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រមុខនោះ សម្តេចបានចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើ ប្រព័ន្ធគ្រប់គ្រងតាមបែបវិជ្ឈការ ដែលបានធ្វើការបោះឆ្នោតកាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ ២០០២ ជាទិសដៅដ៏សំខាន់ក្នុងការផ្តល់សិទ្ធិអំណាចពីថ្នាក់កណ្តាលទៅឲ្យប្រជាពលរដ្ឋនៅមូលដ្ឋាន សំដៅលើកស្ទួយលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន ពង្រឹងអភិបាលកិច្ចល្អ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។[34] ប៉ុន្តែរហូតមកដល់អាណត្តិទី៥ ឆ្នាំ២០១៣ នេះបានជួបប្រទះបញ្ហាជាច្រើនដោយសារតែមានទស្សនៈមួយចំនួនពីសំណាក់ សង្គមជាតិ និងអន្តរជាតិបានលើក

[33] អ៊ុំ សុភក្តិ.ហេង ឌី.អែល យុន. លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅកម្ពុជា.ឆ្នាំ២០០៦.ទំព័រទី១៩-២០

[34] អ៊ុំ សុភក្តិ.ហេង ឌី.អែល យុន. លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅកម្ពុជា.ឆ្នាំ២០០៦.ទំព័រទី២០-២១

ឡើងថាប្រទេសកម្ពុជាកំពុងបំពានទៅលើគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ និងបន្តការរំលោភបំពានសិទ្ធិមនុស្សយ៉ាងខ្លាំង។ តែទោះជាយ៉ាងណាក៏ដោយដើម្បីឲ្យកាន់តែច្បាស់ថា តើប្រទេសកម្ពុជាមានប្រជាធិបតេយ្យដល់កម្រិតណានោះយើងមកមើលដំណើរការជាច្រើន ដែលជាឬសគល់នៃប្រជាធិបតេយ្យវិញ។

## ២. ដំណើរការនយោបាយ

ព្រះរាជាណាចក្រកម្ពុជាប្រកាន់យករបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ដែលមានព្រះមហាក្សត្រគ្រងរាជសម្បត្តិនឹងជាព្រះប្រមុខរដ្ឋអស់មួយជីវិតប៉ុន្តែមិនកាន់អំណាច។ ការបោះឆ្នោតជ្រើសរើសសភាធម្មនុញ្ញត្រូវបានរៀបចំឡើងជាលើកដំបូងឆ្នាំ ១៩៩៣ ដោយអាជ្ញាកណ្តាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា (UNTAC) តាមស្មារតីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ ស្តីពីដំណោះស្រាយនយោបាយនៅកម្ពុជា ហើយសភាធម្មនុញ្ញនេះបានតាក់តែង នឹងអនុម័តធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមុននឹងក្លាយទៅជា រដ្ឋសភានីតិកាលទីមួយ។ រដ្ឋធម្មនុញ្ញថ្មីនេះគឺជាច្បាប់កំពូលរបស់ជាតិដែលក្នុងនោះខ្លឹមសារសំខាន់ៗ នៃកិច្ចព្រមព្រៀងនេះ ត្រូវបានច្របាច់បញ្ចូល។ តាមរយៈធម្មនុញ្ញនេះស្ថាប័នកំពូលៗរបស់ជាតិត្រូវបានបង្កើតឡើង និងចាប់ដំណើរការ។ នៅឆ្នាំ២០១៦អតីតអ្នកការទូតជាន់ខ្ពស់នៃក្រសួងការបរទេសបារាំង ដែលបានចូលរួមយ៉ាងសកម្មក្នុងដំណើការសន្តិភាពនៅកម្ពុជា បានកត់សម្គាល់ថា បន្ទាប់ពីការបោះឆ្នោតដែលរៀបចំដោយ (UNTAC) នៅឆ្នាំ ១៩៩៣ រដ្ឋជាហត្ថលេខីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសត្រូវបានបញ្ចប់បេសកកម្មនៅកម្ពុជា ហើយក្នុងនាមជារដ្ឋអធិបតេយ្យមួយកម្ពុជាបានស្ថិតលើមាគ៌ាសន្តិភាពនឹងការអភិវឌ្ឍន៍។ ប៉ុន្តែក្នុងរយៈពេលមួយឆ្នាំ២០១៧នេះស្ថានភាពនយោបាយនៅក្នុងប្រទេសកម្ពុជាកើតមានរឿងរ៉ាវជាច្រើនទាំងក្តៅ និងត្រជាក់។ តែទោះជាបែបនេះក្តី ការគ្រប់គ្រងស្ថេរភាពទូទៅ នៅតែដំណើរការបានល្អ។ ខាងក្រោយនេះជាបញ្ហាជាច្រើនដែលបានកើតឡើងនៅអាណត្តិទី៥នេះ។

លោក កឹម សុខា ប្រធានគណបក្សសង្គ្រោះជាតិ ត្រូវបានអាជ្ញាធរសម្រុកចូល ចាប់ខ្លួនចេញពីក្នុងផ្ទះរបស់លោក នៅរាជធានីភ្នំពេញ ទាំងកណ្តាលយប់រំលងអធ្រាត្រ ចូលថ្ងៃទី៣ ខែកញ្ញា ដោយចោទថា លោកបានរៀបចំផែនការសម្ងាត់ ដោយមានសហរដ្ឋអាមេរិកនៅពី

ក្រោយ ដើម្បីផ្តួលរំលំរដ្ឋាភិបាលបច្ចុប្បន្ន ដែលដឹកនាំដោយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន។[35] ទាក់ទងព្រឹត្តការណ៍ប្រវត្តិសាស្ត្រ មួយទៀតគឺ ដំណើរការរម្លាយគណបក្សសង្គ្រោះជាតិ ដែលជាគណបក្សដ៏ធំនៅកម្ពុជា ដោយតុលាការកំពូលនៅថ្ងៃទី១៦តុលា។ និងការផ្អាកសិទ្ធិធ្វើនយោបាយរបស់មន្ត្រីបក្សនេះ១១៨នាក់។ អំពីការបែងចែកអសនៈ គណបក្សហ៊្វុនស៊ិនប៉ិច របស់សម្តេចក្រុមព្រះនរោត្តម រណឫទ្ធ បាន៤១អាសនៈ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ របស់លោក ខឹម វាសនា ទទួលបាន៦អាសនៈ ឯគណបក្សខ្មែរឈប់ក្រ៥អាសនៈ គណបក្សសញ្ជាតិកម្ពុជា២អាសនៈ និងគណបក្សខ្មែរអភិវឌ្ឍសេដ្ឋកិច្ច១អាសនៈ។ តែយ៉ាងណាក៏ដោយ គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ និងគណបក្សខ្មែរឈប់ក្រ បដិសេធមិនទទួលយកព្រោះជាការក្បត់ឆន្ទៈពលរដ្ឋ។ ទន្ទឹមនឹងនេះ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ នឹងក្លាយជាតំណាងរាស្ត្រ មណ្ឌលកំពង់ចាម។ ប៉ុន្តែព្រះអង្គថា មិនធ្វើជាអនុប្រធានសភាទេ ពីព្រោះព្រះអង្គធ្លាប់ធ្វើប្រធានសភាហើយ។ រដ្ឋសភា នៅព្រឹកថ្ងៃទី០៨ ខែធ្នូនេះ បានបោះឆ្នោតជ្រើសរើស លោក យូ ហុកគ្រី ជាកូតាមកពីគណបក្ស ហ្វ៊ុន ស៊ិនប៉ិច ដែលពលរដ្ឋមិនបោះឆ្នោតឲ្យនោះ ឲ្យធ្វើជាអនុប្រធានទី១ នៃរដ្ឋសភា ក្រោយពីរម្លាយ គណបក្សសង្គ្រោះជាតិ។ ជាមួយគ្នានោះតំណែងប្រធាន និងអនុប្រធានគណៈកម្មការជំនាញនៃរដ្ឋសភា ចំនួន១០ទៀតក៏ត្រូវបានបោះឆ្នោត ជ្រើសតាំងផងដែរ។

សំណុំរឿងនយោបាយ លោក គឹម សុខ ជាអ្នកវិភាគនយោបាយ និងសង្គម ត្រូវបានតុលាការក្រុងភ្នំពេញ សម្រេចឃុំខ្លួនកាលពី ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៧ ក្រោមបទចោទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាថ៌ និងបរិហារកេរ្តិ៍ជាសាធារណៈ។ ការឃុំខ្លួនធ្វើឡើងក្រោយលោកចោទបក្សកាន់អំណាចថា ជាអ្នកនៅពីក្រោយឃាតកម្ម លោកបណ្ឌិត កែម ឡី។ ក្រោយមកទៀត លោក គឹម សុខ បានរងបណ្តឹងបន្ថែមទៀតពីបទ «ចោទរដ្ឋាភិបាលបច្ចុប្បន្នបានបង្កើតឲ្យមានប្រព័ន្ធមួយ ដែលមានការសម្លាប់មនុស្សហើយ រកមុខឃាតករមិនឃើញ»។[36]

កាលពីថ្ងៃទី៣ខែសីហា អតីតឧបនាយករដ្ឋមន្ត្រី កូតាខាងគណបក្សរាជានិយមហ្វ៊ុនស៊ិនប៉ិច ត្រូវបានកម្លាំងនគរបាលរាជធានីភ្នំពេញ ចាប់ខ្លួន និងកំពុងសាកសួរ នៅស្នងការក្រុងភ្នំពេញ ពាក់ព័ន្ធបទល្មើសគ្រឿងញៀន នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ ក្រោយត្រូវបានឃុំខ្លួន ប្រធានគណបក្សខ្មែររួបរួមជាតិ លោក ញឹក ប៊ុនឆៃ សរសេរលិខិតសារភាពកំហុស និងសុំទោសពីក្នុង

[35] ដោយ ដើមអំពិល ID:117 ព្រហស្បតិ៍, ២៨ ធ្នូ ២០១៧ 12:17

[36] ដោយ ដើមអំពិល ID:117 ព្រហស្បតិ៍, ២៨ ធ្នូ ២០១៧ 12:17

ពន្ធនាគារ ព្រោះសម្រេចចិត្តខុសឆ្គងដែលប៉ះពាល់ដល់គណបក្សខ្មែររួបរួមជាតិ ទាំងមូល។ លោក ញឹក ប៊ុនឆៃ បានសម្តែងសេចក្តីសោកស្តាយ និងវិប្បដិសារីយ៉ាងខ្លាំង ដែលមិនអាចបន្តបេសកកម្ម រួមជាមួយមន្ត្រី គណបក្សខ្មែររួបរួមជាតិ របស់លោក ដោយសារលោក បានប្រព្រឹត្តមិនគប្បី ចំពោះសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន។ លោក ញឹក ប៊ុនឆៃ អំពាវនាវសូមឲ្យអ្នកគាំទ្រគណបក្សខ្មែររួបរួមជាតិ កុំងាករេទៅតាមការអូសទាញ ដើម្បីឲ្យមានការផ្លាស់ប្តូរឲ្យសោះ ព្រោះលោកបញ្ជាក់ថា រដ្ឋាភិបាលសព្វថ្ងៃកំពុងដើរផ្លូវត្រូវ។

លោក សួន សេរីរដ្ឋា ប្រធានគណបក្ស អំណាចខ្មែរ ដាក់ពន្ធនាគារ រយៈពេល៥ឆ្នាំ និងពិន័យជាប្រាក់ចំនួន១០លានរៀល ពាក់ព័ន្ធការប្រមាថធ្ងន់ធ្ងរ ដល់កងទ័ពកម្ពុជា ហើយតុលាការបើក សិទ្ធិឲ្យជនជាប់ចោទប្តឹង ឧទ្ធរណ៍តាមកំណត់ច្បាប់ ។[37]

លោក លី ឡាយស្រេង និងលោកស្រី គី លម្អង អតីតមន្ត្រីគណបក្សហ្វ៊ុនស៊ិនប៉ិច បានប្រមាថដល់ព្រះចេស្តាព្រះមហាក្សត្រ និងសម្តេចក្រុមព្រះ។ ក្រោយការលើកឡើងនេះ បណ្តឹងកើតឡើងជាបន្តបន្ទាប់រួមមានៈ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានដាក់ចូល ទៅកាន់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា តាមរយៈមេធាវី គី តិច ក៏បានដាក់ចូល សាលាដំបូងរាជធានីភ្នំពេញផងដែរ ដោយប្តឹងលោក លី ឡាយស្រេង ពីបទប្រមាថយ៉ាងធ្ងន់ធ្ងរ ដល់អង្គព្រះមហាក្សត្រ និងចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ដែលថាសម្តេចបានផ្តល់លុយ ដល់មន្ត្រីរបស់គណបក្សហ្វ៊ុនស៊ិនប៉ិច ម្នាក់ៗ២ម៉ឺនដុល្លារ។[38]

និយាយពីបញ្ហាចម្រូងចម្រាសទាក់ទងទំនាក់ទំនងការទូតវិញ រវាងកម្ពុជា និងអាមេរិក ផ្តើមចេញពី រដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងការបរទេសរបស់ខ្លួនគឺ កាលពីខែសីហាឆ្នាំ២០១៧ បានចេញលិខិតមួយច្បាប់ សម្រេចបញ្ឈប់នូវរាល់សកម្មភាព របស់វិទ្យាស្ថានជាតិប្រជាធិបតេយ្យ (NDI) ព្រមទាំងបានបណ្តេញបុគ្គលិកបរទេស របស់វិទ្យាស្ថាននេះ ចេញពីប្រទេសកម្ពុជា ក្នុងរយៈពេល៧ថ្ងៃ។ ការបញ្ឈប់និងបណ្តេញមន្ត្រី NDI ដូច្នេះ ត្រូវរដ្ឋាភិបាលយោងទៅលើហេតុផលមិនគោរពតាមច្បាប់ស្តីពី សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីសារពើពន្ធ។ តែអ្នកតាមដានសភាពការណ៍កម្ពុជា ខ្លះយល់ថា វាគឺជាការប៉ះពាល់ដល់លទ្ធិប្រជាធិបតេយ្យ និងចរិតនៃនយោបាយ។ ក្រោយបិទវិទ្យាស្ថានជាតិប្រជាធិបតេយ្យ (NDI) បញ្ហារវាងរដ្ឋាភិបាលកម្ពុជា

[37] ដោយ ដើមអំពិល ID:117 ព្រហស្បតិ៍, ២៨ ធ្នូ ២០១៧ 12:17

[38] ដោយ ដើមអំពិល ID:117 ព្រហស្បតិ៍, ២៨ ធ្នូ ២០១៧ 12:17

និងប្រព័ន្ធផ្សព្វផ្សាយ ដែលទទួលបានការឧបត្ថម្ភពី រដ្ឋាភិបាលអាមេរិក ក៏ចាប់ផ្ដើមមើលមុខគ្នាលែងចំ ឈានដល់ការបិទ ការិយាល័យវិទ្យុអាស៊ីសេរី ផ្សាយជាខេមរៈភាសានៅកម្ពុជា និងកាសែតដឹខេមបូឌាដេលី ពាក់ព័ន្ធទៅនឹងបញ្ហាពន្ធជាដើម។ ក្រោយពីការរម្លាយគណបក្សសង្គ្រោះជាតិ ប្រតិកម្មបានធ្លាក់មកឥតល្ហែ ពីសហគមន៍អន្តរជាតិ។ ភ្លាមៗសហរដ្ឋអាមេរិកប្រកាសផ្អាក់ឈប់ផ្ដល់ជំនួយដល់ គ ជ ប។ តែបង្អង់មិនយូរប៉ុន្មាន សម្ដេច ហ៊ុន សែន ឆ្លើយតបវិញដោយជម្រុញ ទៅអាមេរិកឲ្យផ្ដាច់ជំនួយ ទាំងអស់ពីកម្ពុជាតែម្ដងទៅ ព្រោះជំនួយទាំងនោះអ្នកដែលប៉ះពាល់គឺអង្គការសង្គមស៊ីវិលតែប៉ុណ្ណោះ។

រយៈពេលចុងក្រោយនេះ យើងសូមចាប់អារម្មណ៍ លើទំនាក់ទំនងការបរទេសគឺចិន នៅតែប្រកាសបន្តគាំទ្រ ការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងដំណើររបស់ សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជា ទៅចូលរួម ក្នុងកិច្ចសន្ទនាជាន់ខ្ពស់ រវាងគណបក្សកុម្មុយនីស្តចិន ជាមួយគណបក្សនានា ជុំវិញពិភពលោក នៅតែបន្តប្រកាស អំពីគោលជំហរ របស់ខ្លួនគាំទ្រកម្ពុជា លើចំណាត់ការ បង្ក្រាបបដិវត្តន៍ពណ៌នៅកម្ពុជា ខណៈកម្ពុជាបានប្ដេជ្ញាគាំទ្រ គោលនយោបាយចិនតែមួយ។ ប្រទេសចិនត្រូវបានគេដឹងថា ជាប្រទេសម្ចាស់ជំនួយ យ៉ាងធំសម្រាប់កម្ពុជា ដែលជំនួយទាំងនោះបានយក មកអភិវឌ្ឍប្រទេស។ ក្រោយពីកម្ពុជាបានអនុវត្ត ច្បាប់បង្ក្រាបទៅលើបដិវត្តន៍ពណ៌ គឺមិត្តចិនតែងតែចេញ មកអះអាងគាំទ្រជានិច្ច ខណៈប្រទេសផ្ដល់ជំនួយមួយចំនួនទៀត បានសម្ដែងការមិនពេញចិត្ត ពីស្ថានភាពនយោបាយ នៅកម្ពុជា ហើយថាការបោះឆ្នោតឆ្នាំ២០១៨នឹងមានភាពមិនត្រឹមត្រូវ។ ថ្មីៗនេះកាលពីថ្ងៃ ២២ វិច្ឆិកា កន្លងមក ក្នុងជំនួបជាមួយសម្ដេចតេជោ ហ៊ុន សែន នាវិមានសន្តិភាព លោក Cao Jiangming អគ្គរដ្ឋអាជ្ញាមហាអយ្យការ ប្រជាជនកំពូល នៃសាធារណរដ្ឋប្រជាមានិតចិន បានសម្ដែងការគាំទ្ររាល់ចំណាត់ការរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការថែរក្សាស្ថេរភាពនយោបាយ អធិបតេយ្យភាព ឯករាជ្យភាព វិបុលភាព និងការអភិវឌ្ឍន៍។ ខណៈសហភាពអឺរ៉ុប EU និងសហរដ្ឋអាមេរិក ប្រកាសផ្ដាច់ជំនួយ អ្នកការទូតជប៉ុន ប្រចាំកម្ពុជា បានថ្លែងបញ្ជាក់ជំហររបស់ខ្លួនថា ជប៉ុន ដែលជាមិត្តជិតស្និទមួយរបស់កម្ពុជា នឹងបន្តជួយនិងផ្ដល់ជំនួយដល់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ លោក Hironori Suzuki មន្ត្រីកុងស៊ុល ប្រចាំស្ថានទូតជប៉ុន នៅទីក្រុងភ្នំពេញ ត្រូវបានទីភ្នាក់ងារ អង់គ្លេសរ៉យទ័រ ដកស្រង់សម្ដីដែលបានមានប្រសាសន៍តាមសារអេឡិចត្រូនិចថា "វាពិតជាមានសារៈសំខាន់ខ្លាំងណាស់ សម្រាប់ការបោះឆ្នោតនៅឆ្នាំក្រោយ ដែលឆ្លុះបញ្ចាំងពីឆន្ទៈ

របស់ប្រជាពលរដ្ឋកម្ពុជា"។ លោកកុងស៊ីល បញ្ជាក់ថា ជប៉ុននឹងបន្តផ្តល់ជំនួយ សម្រាប់កំណែទម្រង់ការបោះឆ្នោត ហើយនឹងតាមដានស្ថានការណ៍ដោយចិត្តទុកដាក់បំផុត។[39]

## ៣. ការបោះឆ្នោត និងគណកម្មការជាតិរៀបចំការបោះឆ្នោត

បើយើងនិយាយពីការបោះឆ្នោតមួយដែលមានលក្ខណៈប្រជាធិបតេយ្យនេះ ត្រូវបានប្រព្រឹត្តទៅតាមគោលការណ៍សំខាន់៧៥គឺៈ ការបោះឆ្នោតជាសកលៈ ពលរដ្ឋទាំងអស់មានសិទ្ធិបោះឆ្នោត។ ការមិនអនុញ្ញាតឲ្យក្រុមពលរដ្ឋណាមួយបោះឆ្នោតដោយសំអាងទៅលើពូជអំបូរ ភាសា ភេទ ត្រូវហាមឃាត់។ ដោយការបោះឆ្នោតទាមទារឲ្យមានគំនិតចេះដឹង យល់ខុស ត្រូវ ក្នុងការបោះឆ្នោត ជាទូទៅគេមិនដែលអនុញ្ញាតឲ្យពលរដ្ឋដែលពុំទាន់គ្រប់អាយុពេញវ័យ និងពលរដ្ឋដែលវិកលចរិតបោះឆ្នោតឡើយ។ បោះឆ្នោតដោយស្មើភាព សម្លេងមានតម្លៃស្មើគ្នា។ នៅប្រទេសអង់គ្លេស នៅសតវត្សរ៍ទី១៩ មានការបោះឆ្នោតដែលគេប្រគល់ទៅឲ្យមនុស្សមួយចំនួនតាមគុណភាពរបស់គេនូវពហុសម្លេង (ម្នាក់មានសម្លេងច្រើន) ដូចជាមានសញ្ញាប័ត្រ សាកលវិទ្យាល័យ ឬអ្នកដែលជាគ្រួសារ (ចំនួនសម្លេងកំណត់ ទៅតាមចំនួនកូន)។ បោះឆ្នោតដោយផ្ទាល់ មិនមានអ្នកកណ្តាល។ បោះឆ្នោតដោយសេរី មិនមានការកៀបសង្កត់ បោះឆ្នោតដោយសម្ងាត់ មានតែខ្លួនឯងទេបានដឹងដើម្បីចៀសវាងកុំឲ្យមានការភ័យខ្លាចចំពោះការជ្រើសរើសរបស់ខ្លួន។[40]

ដោយមិនរាប់បញ្ចូលការបោះឆ្នោតដែលរៀបចំដោយ UNTAC នៅឆ្នាំ១៩៩៣ គ.ជ.ប បានរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចំនួន៤ដង នឹងកំពុងដំណើរការរៀបចំការបោះឆ្នោតលើកទី៥នៅ ខែកក្កដា ឆ្នាំ២១០៨ ហើយសមាជិកព្រឹទ្ធសភាចំនួន៣ដង នឹងកំពុងដំណើការរៀបចំការបោះឆ្នោតលើកទី៤នៅ ខែកុម្ភៈ ឆ្នាំ២០១៨ ព្រមទាំងសមាជិក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចំនួន២ដង នឹងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ចំនួន៤ដង ដោយជោគជ័យរួចមកហើយ។ ការបោះឆ្នោតឆ្នាំ ២០១៣ បង្ហាញថាប្រជាជនទៅបោះឆ្នោតមានអត្រា៦៩,៦១%ស្មើនឹង៦៧៣៥២៥៤នាក់ក្នុងចំណោមអ្នកចុះឈ្មោះបោះឆ្នោតចំនួន៩៦៧៥៤៥៣នាក់ ហើយការបោះឆ្នោតឆ្នាំ ២០១៧ ប្រជាជនបានទៅបោះឆ្នោតមានអត្រា៩០,៣៧% ដែលស្មើនឹង៧១០៧៣៩៥នាក់ នៅក្នុងចំណោមអ្នកចុះឈ្មោះបោះឆ្នោតចំនួន៧៨៦៥០៣៣នាក់ ដែលអត្រានេះមានកម្រិតខ្ពស់ធៀបនឹងអត្រាប្រជាជនដែលទៅបោះឆ្នោតនៅប្រទេសជាច្រើន។ បរិយាកាស

[39] ដោយ ដើមអំពិល ID:117 ព្រហស្បតិ៍, ២៨ ធ្នូ ២០១៧ 12:17

[40] ម៉ុក ដារ៉ា.នីតិរដ្ឋធម្មនុញ្ញ.២០១៥-២០១៦.ទំព័រទី៤៥

នៃការបោះឆ្នោតនេះបានប្រព្រឹត្តទៅដោយរលូននឹងសន្តិភាព។ ជោគជ័យនៃការបោះឆ្នោតនេះ បានឆ្លុះបញ្ចាំងឲ្យឃើញអំពីការវិវត្តិន៍ជាវិជ្ជមាន ប្រកបដោយមោទនភាពចំពោះលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ ប្រជាពលរដ្ឋមានសិទ្ធិពេញលេញក្នុងការសម្តែងនូវឆន្ទៈរបស់ខ្លួន នៅគ្រប់ដំណាក់កាលនៃដំណើរការបោះឆ្នោត ដើម្បីបង្ហាញអំពីការគាំទ្រចំពោះគណបក្សនយោបាយដែលខ្លួនពេញចិត្តដោយមិនមានការភ័យខ្លាច។ សកម្មជននៃគណបក្សនីមួយៗ បានធ្វើសកម្មភាពនយោបាយរបស់ខ្លួនដោយសេរី ពុំមានការគាបសង្កត់ ឬការគម្រាមគំហែង ពីមជ្ឈដ្ឋានណាមួយឡើយ។ ក្នុងដំណើរការបោះឆ្នោតនេះពុំមានអំពើហិង្សាធ្ងន់ធ្ងរដែលប៉ះពាល់ដល់ដំណើរការបោះឆ្នោត ហើយក៏ពុំឃើញមានរបាយការណ៍ណាមួយអំពីការរំលោភបំពាន ឬការធ្វើឃាត់ខាងនយោបាយដល់សមាជិកគណបក្សនយោបាយណាមួយនោះទេ។ ការបោះឆ្នោតត្រូវបានប្រព្រឹត្តទៅក្រោមការឃ្លាំមើលរបស់អ្នកសង្កេតការអន្តរជាតិ ចំនួន២៩២នាក់ និងអ្នកសង្កេតការជាតិចំនួន៤០១៩២នាក់ ដែលបានវាយតម្លៃថាការបោះឆ្នោតនេះបានប្រព្រឹត្តទៅកាន់តែល្អប្រសើរឡើងជាពិសេសនោះការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់កាលពីខែមិថុនា ឆ្នាំ២០១៧ កន្លងទៅនេះ ហើយប្រពន្ធ័ចុះឈ្មោះបោះឆ្នោតដែលត្រូវបានធ្វើទំនើបកម្ម ពុំត្រូវបានគណបក្សនយោបាយណាមួយ ធ្វើការរិះគន់ ឬយកទៅបង្កើតជាលេស ដើម្បីមូលបង្កាច់លទ្ធផលនៃការបោះឆ្នោតនេះថាមានភាពមិនប្រក្រតីនោះទេ។[41]

ចំណែកឯគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប.) ជាស្ថាប័នឯករាជ្យ និងអព្យាក្រឹត ដែលធានាឲ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។ គ.ជ.ប មានសមត្ថកិច្ចរៀបចំការបោះឆ្នោតជ្រើសតាំងសមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់។ នៅក្នុងដំណាក់កាលនៃការចុះឈ្មោះបោះឆ្នោត គ.ជ.ប. បានធ្វើតាមនីតិវិធីត្រឹមត្រូវ និងតាមច្បាប់កំណត់ ដើម្បីបង្កលក្ខណៈឲ្យប្រជាពលរដ្ឋទាំងអស់អាចទៅចុះឈ្មោះ អាចទៅកែឈ្មោះខុស ឬក៏កែថ្ងៃ ខែ ឆ្នាំ កំណើត និងភេទជាដើម ជាពិសេស បញ្ជីឈ្មោះអ្នកបោះឆ្នោតថ្មីឆ្នាំ ២០១៧ ត្រូវបានធ្វើទំនើបកម្មក្រោមជំនួយឧបត្ថម្ភរបស់រដ្ឋាភិបាលជប៉ុន ដែលមានលក្ខណៈកាន់តែល្អប្រសើរគ្រប់ជ្រុងជ្រោយ។ អាជ្ញាធរពាក់ព័ន្ធ និង គ.ជ.ប. ក៏

[41] ទីស្តីការគណៈរដ្ឋមន្ត្រី. សៀវភៅសស្តីពី ស្ថានការណ៍នយោបាយនៅកម្ពុជា (ការពង្រឹងនីតិរដ្ឋ និងដំណើរការលទ្ធិប្រជាធិបតេយ្យ).ភ្នំពេញ.ឆ្នាំ២០១៨.ទំព័រទី១៦-១៧-១៨

បានបង្កលក្ខណៈនិងបង្កើតបរិយាកាស ឲ្យដំណើរការនៃយុទ្ធនាការបោះឆ្នោតប្រព្រឹត្តទៅដោយរលូន គ្មានការគម្រាមកំហែង និងគ្មានអំពើហិង្សាថែមទៀតផង។ គ្រប់គណបក្សនយោបាយទាំងអស់ មានសិទ្ធិពេញលេញក្នុងការធ្វើយុទ្ធនាការទោះជាទ្រង់ទ្រាយតូច ឬធំក៏ដោយ។ ស្របពេលដែលការរៀបចំការបោះឆ្នោតប្រព្រឹត្តទៅបានកាន់តែល្អប្រសើរឡើង គ.ជ.ប.បានធ្វើកំណែងទម្រង់ជាបន្តបន្ទាប់ សមាជិកត្រូវបានជ្រើសរើសចេញពីគណបក្សនយោបាយមានអាសនៈនៅក្នុងរដ្ឋសភា និងសង្គមស៊ីវិល បញ្ជីឈ្មោះថ្មីនៃអ្នកបោះឆ្នោតត្រូវបានរៀបចំតាមប្រព័ន្ធព័ត៌មានវិទ្យា គ.ជ.ប. បានក្លាយជាស្ថាប័នដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៅឆ្នាំ២០១៤ ជាដើម ។[42]

## ៤. ប្រព័ន្ធឃោសនា និងផ្សព្វផ្សាយព័ត៌មាន

នៅក្នុងរបបប្រជាធិបតេយ្យ គេចាត់ទុកប្រព័ន្ធឃោសនា នឹងផ្សព្វផ្សាយព័ត៌មានមានតួនាទីដ៏សំខាន់ដើម្បីតាមដានពិនិត្យមើល (wath dog) រដ្ឋាភិបាលនឹងស្ថាប័នធំៗដ៏មានអំណាចនៅក្នុងសង្គម ដោយប្រកាន់ភ្ជាប់នូវគោលការណ៍ឯករាជ្យនឹងភាពឥតលម្អៀង។ ក្នុងគោលបំណងដើម្បីឲ្យប្រជាពលរដ្ឋប្រើប្រាស់អំណាចរបស់ពួកគេ ត្រូវតែធ្វើការជ្រើសរើសដោយមានចំណេះដឹងគ្រប់គ្រាន់ និងធ្វើការវិនិច្ឆ័យដោយឯករាជ្យ លុះត្រាតែពួកគេទទួលបានព័ត៌មានពិតនឹងគួរឲ្យទុកចិត្ត។ កាលពីឆ្នាំ១៨៦៤ លោក abraham Lincoln ប្រធានាធិបតីទី១៦ របស់សហរដ្ឋអាមេរិកបានមានប្រសាសន៍ថា ចូលទុកឲ្យប្រជាលពរដ្ឋបានដឹងពីការពិត ហើយប្រទេសជាតិនឹងមានសុវត្ថិភាព។[43] បង្កើតឲ្យមានប្រពន្ធ័ផ្សព្វផ្សាយព័ត៌មានទៅសាធារណជនអំពីសកម្មភាពរបស់រដ្ឋាភិបាល និងបង្កើតឲ្យមានការពិភាក្សាវែកញែក ព្រមទាំងឲ្យមន្ត្រីសាធារណៈប្រកាន់ខ្ជាប់នូវស្តង់ដាធ្វើការងារខ្ពស់បំផុត និងធ្វើសេចក្ដីរាយការណ៍ថា តើរដ្ឋាភិបាលកំពុងរក្សាបាននូវជំនឿពីសាធារណៈជនដែរឬទេ?

ក្រោយពីការបោះឆ្នោត ខែឧសភា ឆ្នាំ១៩៩៣ នឹងការបង្កើតរដ្ឋធម្មនុញ្ញថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ប្រទេសកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិដោយពាក្យសំដី ដោយការសរសេរ និងមធ្យោបាយដទៃទៀតដែលមានចែងយ៉ាងច្បាស់នៅក្នុង

[42] ទីស្តីការគណៈរដ្ឋមន្ត្រី . សៀវភៅសស្តីពី ស្ថានការណ៍នយោបាយនៅកម្ពុជា (ការពង្រឹងនីតិរដ្ឋ និងដំណើរការលទ្ធិប្រជាធិបតេយ្យ).ភ្នំពេញ.ឆ្នាំ២០១៨.ទំព័រទី១៦-១៧-១៨

[43] ម៉ាហ្គារិត ស. ស៊ូលីហែនៈការិយាល័យពត៌មានប្រកបដោយការទទួលខុសត្រូវ ការិយាល័យកម្មវិធីពត៌មានអន្តរជាតិនៃក្រសួងការបរទេសសហរដ្ឋអាមេរិកទំព័រ០៧

រដ្ឋធម្មនុញ្ញ ត្រង់ជំពូកទី៣ មាត្រា៤១ ប្រជាលពរដ្ឋខ្មែរមានសិទ្ធិសេរីភាពខាងបញ្ចេញមតិរបស់ខ្លួន សេរីភាពសារព័ត៌មាន សេរីភាពខាងបោះពុម្ពផ្សាយ សេរីភាពខាងប្រជុំ។ របបសារព័ត៌មានត្រូវរៀបចំឡើងដោយច្បាប់។ដើម្បីផ្តល់សិទ្ធិនេះឲ្យទៅសារព័ត៌មានធ្វើការផ្សព្វផ្សាយ នយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ អរិយធម៌ និងបញ្ហាជាតិក្នុងវិស័យផ្សេងៗទៀតយ៉ាងទូលំទូលាយ ដោយពុំមានការគម្រាមគំហែង ឬការគាបសង្កត់ឡើយ។ នេះជាសមិទ្ធិផលគួរឲ្យចាប់អារម្មណ៍យ៉ាងខ្លាំង នៃការរីកដុះដាលនូវវិទ្យុ និងទូរទស្សន៍ទាំងរបស់រដ្ឋ និងឯកជន ដែលជាតម្រូវការចាំបាច់នៃរបបប្រជាធិបតេយ្យនៅកម្ពុជា ។

ក្រសួងព័ត៌មានជាស្ថាប័នគ្រប់គ្រងសារព័ត៌មានទាំងអស់នៅកម្ពុជា។ ច្បាប់ស្តីពីរបបសារព័ត៌មានមានលក្ខណៈសេរីនិងបើកទូលាយ ក្នុងការបង្កើតអង្គភាពសារព័ត៌មាន ស្ថានីយវិទ្យុ និងទូរទស្សន៍ ភ្នាក់ងារនិងការិយាល័យតំណាងវិទ្យុ ទូរទស្សន៍បរទេស ព្រមទាំងភ្នាក់ងារនិងការិយាល័យតំណាងសារព័ត៌មានបរទេសជាដើម ប៉ុន្តែសារព័ត៌មានក៏ត្រូវបំពេញវិជ្ជាជីវៈរបស់ខ្លួនដោយសុចរិត ផ្សព្វផ្សាយផ្អែកលើការពិត មានភាពឯករាជ្យ ទទួលខុសត្រូវ និងមិនត្រូវមួលបង្កាច់ ឬប្រឌិតបំផ្លើសរឿង ដើម្បីតែផលប្រយោជន៍អាជីវកម្ម និងនយោបាយនោះទេ។ ក្នុងរយៈពេលជិត៣ទសវត្សរ៍ នេះ អង្គភាពស្ថានីយ៍ ភ្នាក់ងារ និងការិយាល័យសារព័ត៌មានចំនួន៨២៦អង្គភាពត្រូវបានអនុញ្ញាតឲ្យដំណើរការ ក្នុងនោះអាជ្ញាប័ណ្ណ ចំនួន៣៣០ត្រូវបានលុប ដោយមូលហេតុមិនដំណើរការ ឬផុតសុពលភាព ចំណែកអាជ្ញាបណ្ណចំនួន៤៩៦កំពុងដំណើរការ។ អ្នកសារព័ត៌មានមានសិទ្ធិសេរីភាពក្នុងការប្រកបវិជ្ជាជីវៈដោយសេរីនិងគ្មានការបំភិតបំភ័យ ប៉ុន្តែមិនត្រូវបំពានលើសិទ្ធិសេរីភាពអ្នកដទៃនោះឡើយ។ មជ្ឈមណ្ឌលសារព័ត៌មានឡើងជាបន្តបន្ទាប់ ដើម្បីពង្រឹងវិស័យព័ត៌មានឲ្យកាន់តែល្អប្រសើរ និងការពារផលប្រយោជន៍របស់អង្គភាពសារព័ត៌មាន។[44]

## ៥. ទំនាក់ទំនងវប្បធម៌ និងលទ្ធិប្រជាធិបតេយ្យ

ប្រទេសកម្ពុជាបច្ចុប្បន្នក្រៅពីវប្បធម៌ជាតិរបស់ខ្លួន រដ្ឋាភិបាលក៏បើកឲ្យមាន សិទ្ធិទូលំទូលាយដល់ពលរដ្ឋគ្រប់ជនជាតិ ដែលមិនមែនជាជាតិខ្មែរ ហើយកំពុងរស់នៅប្រទេសកម្ពុជា ដូចជាជនជាតិ ចាម ចិន ថៃ យួន អ៊ឺរ៉ុបជាដើម ឲ្យប្រារព្ធពិធីទំនៀមទម្លាប់របស់ពួកគេដោយពុំមានការបង្ខិតបង្ខំឲ្យគោរពប្រពៃណីទំនៀមទម្លាប់របស់ខ្មែរឡើយ។ បើកទូលំទូលាយឲ្យប្រជាពលរដ្ឋ

[44] ទីស្តីការគណៈរដ្ឋមន្ត្រី . សៀវភៅសស្តីពី ស្ថានការណ៍នយោបាយនៅកម្ពុជា(ការពង្រឹងនីតិរដ្ឋ និងដំណើរការលទ្ធិប្រជាធិបតេយ្យ).ភ្នំពេញ.ឆ្នាំ២០១៨.ទំព័រទី១១-១២

គោរពសាសនាណាក៏បាន ដូចជាពលរដ្ឋខ្មែរខ្លះគោរពព្រះយេស៊ូ មិនគោរពសាសនាព្រះពុទ្ធ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញទៀតផង។ នេះបង្ហាញឲ្យឃើញអំពីឆន្ទៈរបស់រដ្ឋាភិបាលក្នុងរបបប្រជាធិបតេយ្យ បើកសិទ្ធិសេរីភាពឲ្យពលរដ្ឋទូទៅធ្វើការជ្រើសរើសដោយខ្លួនឯង សម្រាប់ដើរតាមមាគ៌ាណាមួយ។ ចំពោះការសិក្សារៀនសូត្រវិញប្រជាពលរដ្ឋមានសិទ្ធិទៅរៀនសូត្រដោយគ្មាននរណាម្នាក់មកបង្អាក់ ឬបិទសិទ្ធិមិនឲ្យទៅសិក្សា ពួកគេអាចសិក្សាតាមទំនើងចិត្ត ទោះបីក្រៅពីភាសាជាតិខ្លួនក៏ដោយ។ ទោះបីជាប្រជាពលរដ្ឋកម្ពុជានៅមានកម្រិតយល់ដឹងទាប ខ្វះទំនាក់ទំនងជាមួយពិភពខាងក្រៅ រដ្ឋមានការខ្វះខាតយ៉ាងខ្លាំងផ្នែកមធ្យោបាយ មូលដ្ឋានសម្ភារៈ បច្ចេកទេស និងអ្នកឯកទេស សម្រាប់ជម្រុញវិស័យអប់រំ និងសិក្សាធិកា ដែលជាបញ្ហាទាក់ទិនដោយផ្ទាល់ទៅនឹងវិស័យវប្បធម៌ ហើយក៏ជះឥទ្ធិពលយ៉ាងខ្លាំងទៅដល់ការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យក៏ដោយ។ ឯជំនឿប្រពៃណីទំនៀមទម្លាប់ និងសាសនា ក៏រដ្ឋាភិបាលបានផ្តល់សេរីភាពមិនមានការបង្ខំឲ្យប្រជាពលរដ្ឋគោរពតាមទេ បើជនជាតិចាម ឲ្យគេគោរពតាមទំនៀមទម្លាប់របស់គេ បើគេជាជនជាតិ ចិន យួន ឬជនជាតិផ្សេងៗទៀតក៏រដ្ឋាភិបាលផ្តល់សេរីភាពឲ្យធ្វើតាមទំនៀមទម្លាប់របស់ពួកគេដែរ។[45]

## ៦. ដំណើរការសេដ្ឋកិច្ច

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានអះអាងថា កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ មិនបាននាំសេដ្ឋកិច្ចទីផ្សារមកកម្ពុជាដូចការលើកឡើងរបស់បណ្តាប្រទេសមួយចំនួននោះទេ។ ចាប់ពីពេលដែលកម្ពុជា រួចផុតរបបប្រល័យពូជសាសន៍សម័យ ប៉ុល ពត មក បានចាប់ផ្តើមធ្វើជាបណ្តើរជម្រុញឲ្យមានការរីកចម្រើនទៅលើវិស័យ ឯកជន ឲ្យងើបឈរឡើង ក្នុងនោះរាប់ទាំងការផ្តល់កម្មសិទ្ធិ និងបែងចែកដីធ្លីឲ្យប្រជាពលរដ្ឋ។ ចាប់តាំងពីឆ្នាំ១៩៩០ កម្ពុជាបានចាប់ផ្តើមដំណើរការធ្វើឯកជនភូបនីយកម្ម បណ្តារោងចក្ររដ្ឋ ព្រោះពេលវេលាបានមកដល់ ដែលបើកចំហាទីផ្សារ។ បើទោះបីមិនទាន់មានអ្នកវិនិយោគធំៗពីក្រៅក៏ដោយ ប៉ុន្តែក៏ចាប់ផ្តើមមានចលនា នៃចូលមកវិនិយោគនៅកម្ពុជា បានចាប់ផ្តើមបណ្តើរៗនាពេលនោះ។ តាំងពីពេលនោះមកសេដ្ឋកិច្ចកម្ពុជា បានចាប់ផ្តើម លូតលាស់បន្តិចម្តងៗ រហូតដល់បច្ចុប្បន្ន។ សម្តេចគូសបញ្ជាក់ថា ទាក់ទងនឹងសេដ្ឋកិច្ច មានរឿងច្រើន ទម្រាំកម្ពុជាមានសព្វថ្ងៃ មិនមែនជាដំណើរការធម្មតាទេ កម្ពុជាបានធ្វើសេរីភាវូបនីយកម្មសេដ្ឋកិច្ច នៅចុងទសវត្សរ៍ ៨០រហូត

[45] អ៊ុំ សុភក្តិ.ហេង ឌី.អែល យុន. លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅកម្ពុជា.ឆ្នាំ២០០៦.ទំព័រទី២៩-៣១

មក។ បច្ចុប្បន្នកម្ពុជាកំពុងបន្តធ្វើសុក្រឹតកម្ម សេដ្ឋកិច្ចទីផ្សារ។ ជាងនេះទៀត កម្ពុជាប្រឆាំងនឹងការគាំពារនិយម នៃប្រទេសមួយចំនួន ដែលលេចឡើងនូវនយោបាយ គាំពារនិយម។ ប៉ុន្តែសម្តេចនៅតែជឿជាក់ថា នយោបាយគាំពារនិយម នឹងមិនមានជោគជ័យទេ។ ទន្ទឹមនេះ សម្រាប់ប្រទេសនីមួយៗវិញ មិនអាចឯកោនៅម្នាក់ឯងបានឡើយ ត្រូវមានសហប្រតិបត្តិការជាមួយប្រទេសដទៃទៀត ក្នុងការទំនាក់ទំនងដោះដូរ ធ្វើពាណិជ្ជកម្ម ជាមួយគ្នា (ទិញទំនិញពីគ្នាទៅវិញទៅមក) ការធ្វើបែបនេះ គឺជាដំណើរ ធម្មតានៃការរកស៊ីសម្រាប់ សេដ្ឋកិច្ច ក្នុងប្រទេសនីមួយៗលើពិភពលោក។ ទោះបីជាមានអ្នកណាហាមឃាត់មិនឲ្យទិញទំនិញពីកម្ពុជា ប៉ុន្តែក៏មិនអាចហាម ឃាត់ក្រុមហ៊ុនឯកជន មិនឲ្យទិញទំនិញពីកម្ពុជាបានដែរ។ បើអ្នកនោះ ហាមឃាត់ ក្រុមហ៊ុនឯកជនបានមិនឲ្យទិញទំនិញពីកម្ពុជា អ្នកនោះមិនខុសពី ប្រទេសមួយ ដែលមានរបបផ្តាច់ការ ដែលអាចឈានទៅឲ្យក្រុមហ៊ុន ឯកជនមិនឲ្យធ្វើសកម្មភាព ដោយសេរី។ ប្រទេសកាន់របបលទ្ធិប្រជាធិបតេយ្យ គឺជាប្រទេស ដែលមិនដាក់ការកំណត់ណាមួយលើដំណើរការ សេដ្ឋកិច្ច លើកលែងតែវិធានពន្ធដារ និងបទដ្ឋានពាក់ព័ន្ធ។[46]

## ៧. ការកសាងក្របខ័ណ្ឌច្បាប់

ចាប់តាំងពី ឆ្នាំ២០០៣ រហូតមកដល់ពេលនេះ រាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ និងផ្តល់អាទិភាពដល់ការធ្វើកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។ ផែនការយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ជាតិ លិខិតបទដ្ឋានគតិយុត្តិ និងសកម្មភាពជាច្រើន ត្រូវបានដាក់ចេញដើម្បីសម្រេចឲ្យបានជោគជ័យនៃកំណែទម្រង់នេះ។ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនានាត្រូវបានដាក់ចេញនៅក្នុងឯកសារសំខាន់ចំនួន២គឺ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០១៤-២០១៨ និងយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធិភាព ដំណាក់កាលទី៣ នៅឆ្នាំ២០១៣។ លើសពីនេះទៀត ដើម្បីធានានូវឯករាជ្យភាពនៃអំណាចតុលាការ នៅឆ្នាំ២០១៤ រាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយ និងច្បាប់ថ្មីៗ គឺការរៀបចំ និងដាក់ឲ្យអនុវត្តច្បាប់គោល៣ រួមមាន ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ក្នុងពេលដែលស្ថាប័នទ្រទ្រង់លទ្ធិប្រជាធិបតេយ្យ ត្រូវបានបង្កើតឡើងការងារចម្បងរបស់រាជ

[46] ដោយ ជឹម ណារី.សុន្ទរកថាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន.កំពត ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨

រដ្ឋាភិបាលគឺ ត្រូវយកចិត្តទុកដាក់ក្នុងការកសាងក្របខ័ណ្ឌច្បាប់ដែលជាឧបករណ៍សម្រាប់ពង្រឹងទ្រទ្រង់ និងលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ។ ក្នុងរយៈពេល៣ទសវត្សរ៍ចុងក្រោយនេះ ដោយមានការប្តេជ្ញាចិត្តយ៉ាងមោះមុតកម្ពុជាបានប្រកាសឲ្យប្រើច្បាប់ចំនួន៩៩៧ ដែលមានចរិត និងខ្លឹមសារស្របតាមគោលការណ៍នីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស តម្លាភាព និងបម្រើផលប្រយោជន៍សាធារណៈ ហើយការតាក់តែងច្បាប់នេះមានការចូលរួមពីតួអង្គពាក់ព័ន្ធនានា ដើម្បីអាចឆ្លុះបញ្ចាំងនឹងឆ្លើយតបទៅនឹង តថភាពសង្គមជាក់ស្តែង និងធានាឲ្យការអនុវត្តន៍មានភាពរលូន និងប្រសិទ្ធិភាព សម្រាប់ជាឧត្តមប្រយោជន៍ជាតិ និងប្រជាជន ស្របតាមគោលការតាក់តែងច្បាប់នៅតាមបណ្តាប្រទេសប្រជាធិបតេយ្យនានាផងដែរ។ បន្ថែមលើសពីនេះកម្ពុជាបានចូលរួមជាមួយនឹងសហគមន៍អន្តរជាតិ ជាហត្ថលេខីក្នុងកិច្ចព្រមព្រៀង សំខាន់ៗពាក់ព័ន្ធនឹងសន្តិសុខ អំពើភាវរកម្ម និងការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោកព្រមទាំងបានផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងជាច្រើនដែលផ្តល់ផលប្រយោជន៍ដល់មនុស្សជាតិទាំងមូល។ សមាហរណកម្មរបស់កម្ពុជាក្នុងពិភពលោក ដូចបញ្ជាក់ខាងលើនេះ តម្រូវឲ្យកម្ពុជាកសាងគតិយុត្តស្របតាមគម្រោងការអន្តរជាតិនិងបង្កើតស្ថាប័នពាក់ព័ន្ធ ដើម្បីធានាដល់ការអនុវត្តន៍កិច្ចព្រមព្រៀងអន្តរជាតិនានាឲ្យមានប្រសិទ្ធិភាព។ ដើម្បីធានាដល់ការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ និងការការពារសិទ្ធិរបស់ប្រជាពលរដ្ឋ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាច្រើន ត្រូវបានកសាង និងប្រកាសឲ្យប្រើ ដែលក្នុងនោះមានច្បាប់មួយចំនួនដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការរៀបចំការបោះឆ្នោតមានជាអាទិ៍ រដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ របស់គណកម្មការជាតិរៀបចំការបោះឆ្នោត ច្បាប់ស្តីពីការជ្រើសតាំងតំណាងរាស្ត្រ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតនានា ជាមូលដ្ឋានទាំង៤ ដែលមាន ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ពន្ធ័ផ្សេងទៀត។[47] លើសពីនេះទៀតក្នុងគោលដៅធានាឲ្យប្រជាពលរដ្ឋអនុវត្តសិទ្ធិរបស់ខ្លួនដោយរលូន និងគ្មានការគម្រាមគំហែង ក្នុងការចូលរួមគ្រប់ដំណាក់កាល នៃការបោះឆ្នោតតាម

[47] ទីស្តីការគណៈរដ្ឋមន្ត្រី .សៀវភៅសស្តីពី ស្ថានការណ៍នយោបាយនៅកម្ពុជា (ការពង្រឹងនីតិរដ្ឋ និងដំណើរការលទ្ធិប្រជាធិបតេយ្យ).ភ្នំពេញ.ឆ្នាំ២០១៨.ទំព័រទី១២-១៤

បែបប្រជាធិបតេយ្យរដ្ឋាភិបាលបានបង្កើតយន្តការមានឈ្មោះថា គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សម្រាប់ការពារ ការចុះឈ្មោះបោះឆ្នោតដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ ថ្នាក់ក្រោមជាតិចាប់ពីឆ្នាំ២០១៦-២០១៩។ មាត្រា៤៩នៃរដ្ឋធម្មនុញ្ញបានចែងថា ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់។ ក្រោយពីច្បាប់បានប្រកាសឲ្យប្រើ នឹងចូលជាធរមាន អត្ថបទច្បាប់ទាំងនោះត្រូវបានបោះពុម្ពផ្សាយនៅក្នុងរាជកិច្ចដែលជាកម្រងឯកសារផ្លូវការរបស់រដ្ឋ។ ក្រសួងស្ថាប័នធ្វើការផ្សព្វផ្សាយទូលំទូលាយជាមួយភាគីពាក់ព័ន្ធនានាជាពិសេសនោះប្រជាពលរដ្ឋទូទៅដើម្បីបញ្ជ្រាបការយល់ដឹងអំពីខ្លឹមសារនៃច្បាប់ទាំងនេះ ដល់ស្រទាប់មហាជនតាមរយៈសិក្ខាសាលា ការផ្សព្វផ្សាយ និងកម្មវិធីអប់រំផ្សេងៗ ក្នុងគោលដៅជម្រុញការអនុវត្តន៍ឲ្យរលូន និងប្រសិទ្ធិភាព។ ទន្ទឹមនឹងនេះរាជរដ្ឋាភិបាលក៏យកចិត្តទុកដាក់បណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់តាមវិស័យ កងកម្លាំងមានសមត្ថកិច្ច មន្ត្រីតុលាការ ចៅក្រម និងព្រះរាជអាជ្ញា។ រាជរដ្ឋាភិបាលប្តេជ្ញាចិត្តអនុវត្តច្បាប់ឲ្យរឹតតែមានប្រសិទ្ធិភាពដោយ មានធាតុផ្សំពីសមាសធាតុសំខាន់៣ យ៉ាងតិចគឺច្បាប់សង្គតិភាព និងឆ្លុះបញ្ចាំងពីតថភាពពិតក្នុងសង្គម ប្រជាពលរដ្ឋយល់ដឹងអំពីខ្លឹមសារច្បាប់និងគោរពច្បាប់ អ្នកអនុវត្តច្បាប់ត្រូវមានវិជ្ជាជីវៈយល់ដឹងពីខ្លឹមសារច្បាប់ និងអនុវត្តច្បាប់ដោយអព្យាក្រឹត្យ មិនលម្អៀងស្មើភាព និងប្រសិទ្ធិភាព។[48]

ក្នុងរយៈពេល៣ទសវត្សរ៍ចុងក្រោយនេះ ការបង្កើតស្ថាប័នដែលជាយន្តការគ្រប់គ្រង និងអនុវត្តច្បាប់ ត្រូវបានរៀបចំ ហើយច្បាប់ជាច្រើនត្រូវបានអនុម័តដោយស្ថាប័ននីតិប្បញ្ញត្តិ នឹងត្រូវបានប្រកាសឲ្យប្រើជាបន្តបន្ទាប់។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏យកចិត្តទុកដាក់រៀបចំលិខិតបទដ្ឋានគតិយុត្តជាច្រើន លើការពង្រឹងសមត្ថភាពស្ថាប័ន និងបណ្តុះបណ្តាលធនធានមនុស្សមន្ត្រីអនុវត្តច្បាប់ប្រកបដោយវិជ្ជាជីវៈ ព្រមទាំងបញ្ជ្រាបការយល់ដឹងអំពីខ្លឹមសារនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដល់អ្នកពាក់ព័ន្ធទាំងអស់រួមទាំងប្រជាពលរដ្ឋផង។ ការងារទាំងអស់នេះពាក់ព័ន្ធទាំងស្រុងទៅនឹងការលើកកម្ពស់ និងទ្រទ្រង់ដល់ដំណើរការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា។ អាទិភាពចម្បងមួយឆ្ពោះទៅរកការពង្រឹងលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសមួយ គឺការរៀបចំឲ្យមានយន្តការស្ថាប័ន និងក្របខ័ណ្ឌច្បាប់សម្រាប់ដល់ការគាំទ្រដល់

[48] ទីស្តីការគណៈរដ្ឋមន្ត្រី . សៀវភៅសស្តីពី ស្ថានការណ៍នយោបាយនៅកម្ពុជា (ការពង្រឹងនីតិរដ្ឋ និងដំណើរការលទ្ធិប្រជាធិបតេយ្យ).ភ្នំពេញ.ឆ្នាំ២០១៨.ទំព័រទី១៥

ការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងសិទ្ធិមនុស្ស។ ក្នុងន័យនេះ ដោយសារការប្តេជ្ញាចិត្តដ៏មោះមុតបំផុតរបស់រដ្ឋាភិបាល កម្ពុជាបានបង្កើតស្ថាប័ន និងក្របខ័ណ្ឌច្បាប់ចាំបាច់ និងពាក់ព័ន្ធជាច្រើន។ ជារួមយើងសង្កេតឃើញថាស្ថាប័នប្រជាធិបតេយ្យទាំងអស់ខាងលើ បាន និងកំពុងបំពេញការងាររបស់ខ្លួនយ៉ាងសកម្មតែដំណើរការនេះត្រូវទាមទារពេលវេលាដើម្បីពង្រឹងសមត្ថភាព ភាពជាម្ចាស់ និងប្រសិទ្ធិភាពការងាររបស់មន្ត្រីពាក់ពន្ធ័ ឲ្យបានកាន់តែល្អប្រសើរ។[49]

## ៨. តួអង្គសំខាន់ៗក្នុងការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា

ប្រទេសកម្ពុជា ជាប្រទេសមួយដែលបានឆ្លងកាត់នូវសង្គ្រាម និងការរំលោភសិទ្ធិមនុស្សអស់ជាច្រើនទសវត្សរ៍មកហើយ។ ក៏ប៉ុន្តែដោយសារមានការរើបម្រាស់ពីសំណាក់ប្រជាពលរដ្ឋទើប ធ្វើឲ្យប្រទេសមួយនេះមានការវិវត្តន៍ ព្រមទាំងរីកចម្រើននូវលទ្ធិប្រជាធិបតេយ្យគួរឲ្យកត់សម្គាល់។ ដើម្បីឲ្យកាន់តែច្បាស់ថា តើតួអង្គណាខ្លះដែលមានកាតព្វកិច្ចសំខាន់ក្នុងការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា យើងខ្ញុំសុំលើកយកតួអង្គសំខាន់ៗបីគឺ៖

### ៨.១. គណបក្សនយោបាយសេរីពហុបក្ស

អ្វីដែលហៅថា គណបក្ស? "Party" ចេញពីភាសាឡាតាំង បានន័យថា ផ្នែក ឬ ពួក ឬ ក្រុមប្រជាជន ឬ សង្គម។ មតិមួយគិតថា ការចូលរួមក្នុងកិច្ចការគណបក្សនយោបាយដ៏ច្រើនកុះកររបស់ប្រជាជន បានធ្វើឲ្យគេយល់ឃើញថា បញ្ហាសង្គមចាត់ទុកដូចជាបញ្ហាផ្ទាល់ខ្លួន។ មតិដ៏ទៃទៀតបានគិតថា ការចូលរួមទៅក្នុងជួរគណបក្សនយោបាយច្រើនតែជាមនុស្សដែលចង់បំពេញនូវទិសដៅការងារមហិច្ឆតា ដើម្បីបុណ្យស័ក្តិអំណាចរបស់ខ្លួន។[50] គណបក្សនយោបាយជាតួអង្គ និងធាតុដ៏សំខាន់នៅក្នុងការដឹកនាំគ្រប់គ្រងរដ្ឋក្នុងប្រព័ន្ធប្រជាធិបតេយ្យ។ ការចូលរួមសកម្មភាពនយោបាយនិងការប្រកួតប្រជែងក្នុងការបោះឆ្នោត ឆ្លុះបញ្ចាំងអំពីការអនុវត្តន៍គោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។ បច្ចុប្បន្ន កម្ពុជាមានគណបក្សនយោបាយចំនួន២០ ដែលបានចុះបញ្ជី និងត្រៀមចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅឆ្នាំ២០១៨។ គណបក្សនយោបាយអាចចងសម្ព័ន្ធភាព និងមានសេរីភាពក្នុងការរៀបចំកម្មវិធីនយោបាយ ស្របតាមលក្ខន្តិកៈរបស់ខ្លួន ប៉ុន្តែត្រូវគោរពតាមបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពី

[49] ទីស្តីការគណៈរដ្ឋមន្ត្រី. សៀវភៅសស្តីពី ស្ថានការណ៍នយោបាយនៅកម្ពុជា (ការពង្រឹងនីតិរដ្ឋ និងដំណើរការលទ្ធិប្រជាធិបតេយ្យ).ភ្នំពេញ.ឆ្នាំ២០១៨.ទំព័រទី១៥-១៦

[50] ឈុន ណារ៉េត.សេចក្តីផ្តើមវិទ្យាសាស្ត្រនយោបាយ.ភ្នំពេញ.២០១២.ទំព័រទី២៥៨

គណបក្សនយោបាយ និងច្បាប់នានាជាធរមាន។ គណបក្សនយោបាយ មានតួនាទីចូលរួមចំណែកដល់ការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍន៍ប្រទេសដូចជា ការទិតៀនដើម្បីកែលម្អសកម្មភាពរបស់រាជរដ្ឋាភិបាល។ នៅកម្ពុជាគណបក្សនយោបាយមានសិទ្ធិសេរីភាព ក្នុងការធ្វើយុទ្ធនាការបោះឆ្នោត ឃោសនាអំពីកម្មវិធីនយោបាយ ធ្វើពិធីជួបជុំសមាជិក និងចូលរួមរាល់សកម្មភាពនយោបាយដោយសេរី ប៉ុន្តែក៏ត្រូវតែទទួលខុសត្រូវ នូវរាល់សកម្មភាពទាំងឡាយណាដែលផ្ទុយនឹងច្បាប់កំណត់ដែរ។ រាល់ការបោះឆ្នោត មានការចូលរួមប្រកួតប្រជែងពីគណបក្សដែលមាននិន្នាការ និងកម្មវិធីនយោបាយខុសៗគ្នា ដោយសេរី និងស្មើភាព។ គណបក្សធ្វើសកម្មភាពនយោបាយ ស្របតាមច្បាប់ និងនីតិវិធីជាធរមានដោយស្មើភាព និងគ្មានការគម្រាមកំហែង។ បញ្ហាសំខាន់របស់គណបក្សគឺត្រូវសិក្សាផលប្រយោជន៍ក្រុមមនុស្សនៅក្នុងសង្គម និងវិធីការពារពួកគេ។ ដើម្បីការពារផលប្រយោជន៍គណបក្សត្រូវមានសមាជិករបស់ខ្លួននៅក្នុងសភាជាតិ។ ហេតុដូចច្នេះ គណបក្សនយោបាយត្រូវតែតស៊ូដើម្បីបានអំណាចមកកាន់កាប់ និងដឹកនាំ។ ម៉្យាងទៀតគណបក្សនយោបាយ ជាអង្គការបង្រួបបង្រួមប្រជាជនគ្រប់ស្រទាប់វណ្ណៈ ដោយសេរីដោយឈរលើគោលការណ៍មួយច្បាស់លាស់ ដែលបម្រើផលប្រយោជន៍ឲ្យពួកគេ ពិសេសគឺការប្រើប្រាស់អំណាចនយោបាយមកកាន់កាប់ក្នុងដៃឲ្យបានចំទិសដៅ។ សិក្សាលម្អិតអំពីគោលការណ៍រចនាសម្ព័ន្ធ និងកិច្ចការទំនាក់ទំនងជាមួយនឹងគណបក្សដទៃទៀត ដើម្បីបង្កើតក្រុមឃោសនាបោះឆ្នោត និងយុទ្ធសាស្ត្រនានា និងបង្កើតលើកិច្ចសហប្រតិបត្តិការជាមួយបក្សដទៃនៅក្នុងសភា។ ចំណែកឯតួនាទីគណបក្សប្រឆាំងវិញ ត្រូវតែទាមទារឲ្យកែលម្អ ក្នុងខណៈដែលនយោបាយរបស់រដ្ឋាភិបាលមិនបម្រើឲ្យផលប្រយោជន៍របស់ប្រជាជន។

### ៨.២. អង្គការសង្គមស៊ីវិល

សង្គមស៊ីវិលគឺជាបណ្តុំរបស់ពលរដ្ឋប្រកបដោយពុទ្ធិ និងទំនួលខុសត្រូវដែលរស់នៅរួមគ្នាប្រកបដោយប្រព័ន្ធ ហើយមានរចនាសម្ព័ន្ធរៀបចំ កម្រិតខ្ពស់ដើម្បីធ្វើការសម្រេចចិត្តទៅលើអាយុជីវិតរបស់សង្គមរបស់ខ្លួនតាមរយៈការចូលរួមដោយស្ម័គ្រចិត្ត និងដោយមិនគិតកម្រៃ។ សង្គមស៊ីវិលជាស្ថាប័នដែលស្ថិតនៅចន្លោះរដ្ឋាភិបាល និងផ្នែកឯកជន ដោយឯករាជ្យពីឥទ្ធិពលជ្រៀតជ្រែករបស់រដ្ឋាភិបាល ប៉ុន្តែវាមិនមែនជាទម្រង់អនាធិបតេយ្យ ហើយស្ថិតនៅក្រៅការគ្រប់គ្រងរបស់រដ្ឋនោះទេ។ វាត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ច្បាប់សង្គម និងដើម្បីបម្រើឲ្យសង្គម

ទាំងមូល។[51] ចំណែកប្រទេសកម្ពុជា ដែលជាអតីតមហាចក្រព័ត្តិនៅចុងបូព៌ាជាប្រភពវប្បធម៌អរិយធម៌ មិនចេះរឹងស្ងួតមួយរបស់អាស៊ីធ្លាប់មានប្រវត្តិសាស្ត្រ នៃការចូលរួមចំណែករបស់សង្គមស៊ីវិលក្នុងកិច្ចការផ្សេងៗរបស់ប្រទេសឬទេ?

ដោយសារតែប្រទេសកម្ពុជាត្រូវបានគ្របដណ្តប់ដោយស្ថានភាពសង្គ្រាម និងភាពរីករវទើបការសិក្សាស្រាវជ្រាវនៅមានកម្រិត ហើយពុំមានឯកសារណាមួយបញ្ជាក់ឲ្យបានច្បាស់លាស់អំពីបញ្ហានេះទេ។ ប៉ុន្តែប្រសិនបើយើងពិនិត្យមើលតាមប្រវត្តិសាស្ត្រខ្មែរវិញបានបង្ហាញឲ្យឃើញថា នៅចន្លោះឆ្នាំ ១៩៥៥-១៩៦០ សង្គមស៊ីវិលខ្មែរបានដើរតួនាទីមួយចំណែកដែរនៅក្នុងសង្គម។ នៅអំឡុងឆ្នាំនេះ ប្រទេសយើងស្ថិតក្រោមរបបគ្រប់គ្រងបែបប្រជាធិបតេយ្យដោយមានឈ្មោះថា "សង្គមរាស្ត្រនិយម"។ ដូចដែលយើងបានដឹងរួចមកហើយថា ពាក្យ ស៊ីវិល (Civil) គឺសំដៅទៅលើពលរដ្ឋ ឯសង្គមស៊ីវិល (civil Society) គឺសំដៅទៅលើសង្គមរបស់ពលរដ្ឋ។ ពលរដ្ឋជាអ្នកដែលមានតួនាទីយ៉ាងសំខាន់ នៅក្នុងសង្គមបែបនេះ។ ហេតុនេះពាក្យថាសង្គមរាស្ត្រនិយម ពិតជាបានបង្ហាញយ៉ាងច្បាស់អំពីតម្លៃ សារៈសំខាន់ និងតួនាទីរបស់ពលរដ្ឋសម្រាប់សង្គម។ ច្បាស់ជានេះទៀត ការរៀបចំឲ្យមាន "សមាជជាតិ" ជារៀងរាល់ឆ្នាំ ដែលអនុញ្ញាតឲ្យពលរដ្ឋទាំងអស់របស់ប្រទេសចូលរួមស្តាប់ក៏ដូចជា បញ្ចេញមតិយោបល់ដើម្បីស្ថាប័នសង្គម និងការយល់ដឹងអំពីតម្លៃខ្លួនសម្រាប់ សង្គម របស់ពលរដ្ឋ គឺជាទង្វើមួយដែលបើកឱកាសឲ្យពលរដ្ឋបញ្ចេញមតិដោយផ្ទាល់ ដើម្បីចូលរួមចំណែកស្ថាបនាសង្គមរបស់ខ្លួនឲ្យសក្តិសម និងឈ្មោះថា "សង្គមពលរដ្ឋ" ឬ "សង្គមស៊ីវិល" នេះ។ ការធ្វើនូវវេទិការនេះ (សមាជជាតិ) និងការចូលរួមរបស់ពលរដ្ឋខ្មែរ ទោះបីមិនដូចទាំងស្រុង តែវាក៏មានរូបរាងប្រហាក់ប្រហែលគ្នានឹងសភា (Assembly) របស់ក្រិចបុរាណសម័យ ដែលត្រូវបានចាត់ទុកថាជារូបភាពនៃសង្គមស៊ីវិលពិតៗនោះដែរ។ មួយវិញទៀត នៅរាល់សម័យបោះឆ្នោតម្តងៗ ពលរដ្ឋបានប្រើប្រាស់សិទ្ធិនយោបាយរបស់ខ្លួនក្នុងការជ្រើសរើសដោយផ្ទាល់របស់ខ្លួនតាមរយៈសន្លឹកឆ្នោត នូវអ្នកដឹកនាំដែលពិតជាបម្រើផលប្រយោជន៍របស់ខ្លួនពិតប្រាកដ។ អ្នកដឹកនាំដែលទទួលបាន គឺចេញមកពីឆន្ទៈរបស់រាស្ត្រ ហើយត្រូវតែធ្វើការដើម្បីសង្គមរបស់រាស្ត្រ ឬសង្គមស៊ីវិលនេះវិញ។ ឆ្នាំ ១៩៧០ - ១៩៩០ ភាគច្រើននៃការងារទាំងអស់ ក្នុង និងក្រៅប្រទេសស្ថិតក្នុងរូបភាពជាកងកម្លាំងប្រដាប់អាវុធ។ ហេតុនេះសកម្មភាពរបស់សង្គមស៊ីវិលពុំមានរូបរាងធំដុំទេ។ ឆ្នាំ ១៩៩១ តាមរយៈសន្ធិសញ្ញាក្រុងប៉ារីស បានអនុញ្ញាតឲ្យមានអន្តរាគមន៍

[51] ឈុន ណារ៉េត.សេចក្តីផ្តើមវិទ្យាសាស្ត្រនយោបាយ.ភ្នំពេញ.២០១២.ទំព័រទី២៣៦

របស់អង្គការសហប្រជាជាតិនៅក្នុងបញ្ហារបស់ប្រទេសកម្ពុជា។[52] អន្តរាគមន៍នេះបាននាំមកជាមួយផងដែរនូវអន្តរាគមន៍របស់អង្គការមិនមែនរដ្ឋាភិបាល និងសមាគមន៍អន្តរជាតិមួយចំនួន។ អ្នកអន្តរាគមន៍ទាំងនេះបានចូលមកក្នុងប្រទេសកម្ពុជា ប៉ុន្តែពុំទាន់មានលក្ខណៈជាផ្លូវការនោះទេពោល គឺវាស្ថិតនៅក្នុងរូបភាពជាស្រមោលនៅឡើយ។ ឆ្នាំ ១៩៩៣ ក្រោយពេលលេចចេញជារូបរាងច្បាស់ហើយរដ្ឋធម្មនុញ្ញ ខ្មែរត្រូវបានអនុម័ត ដែលផ្តល់បានសិទ្ធិជូនដល់សង្គមស៊ីវិលចូលរួមក្នុងកិច្ចការអភិវឌ្ឍន៍ប្រទេស។ ហេតុនេះហើយដំណើរត្រឡប់មកវិញជាថ្មីរបស់លទ្ធិប្រជាធិបតេយ្យ ដែលចាប់ផ្តើមនៅឆ្នាំ ១៩៩៣ ក៏បាននាំតួនាទីរបស់សង្គមស៊ីវិលត្រលប់មកវិញ។ ជាដំបូង គឺការផ្តល់ឲ្យពលរដ្ឋគ្រប់រូបនូវសិទ្ធិក្នុងគ្រប់វិស័យ ជាពិសេស គឺសិទ្ធិផ្នែកនយោបាយ។ ពលរដ្ឋគ្រប់រូបមានសិទ្ធិបោះឆ្នោត ឈរឈ្មោះឲ្យគេបោះឆ្នោត សិទ្ធិក្នុងការបញ្ចេញមតិយោបល់របស់ខ្លួនដោយសេរី បង្កើតសារព័ត៌មាន បង្កើតអង្គការសមាគមសិទ្ធិបោះពុម្ពផ្សាយ និងសិទ្ធិនានាជាច្រើនទៀត។[53] រហូតមកដល់ពេលនេះ ការអប់រំបណ្តុះបណ្តាលសង្គមស៊ីវិលខ្មែរឲ្យមានការយល់ដឹងច្បាស់លាស់ដើរតួរនាទីយ៉ាងសំខាន់ក្នុងការទប់ស្កាត់រលកចូលនៃវប្បធម៌ខាងក្រៅដែលធ្វើឲ្យ យុវជនលង់លក់នៅក្នុងកាមគុណបាត់បង់គុណធម៌ប្រជាធិបតេយ្យ បាត់បង់វប្បធម៌ប្រពៃណី អត្តសញ្ញាណ និងព្រលឹងជាតិខ្លួនដែលធ្វើឲ្យយុវជនធ្លាក់ចុះអន់ថយ។ សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល មានភារៈកិច្ចចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច សង្គម ដោយឈរលើគោលការណ៍អព្យាក្រឹត្យ និងផលប្រយោជន៍ប្រជាពលរដ្ឋជាធំ ហើយមិនត្រូវបានចូលរួមសកម្មភាពទាំងឡាយណាដែលបម្រើដល់ការងារនយោបាយ គណបក្សនយោបាយ ឬក្រុមដែលមានថវិកាដែលជាជំនួយរបស់បរទេស សប្បុរជន ដើម្បីប៉ុនប៉ងផ្តួលរំលំរដ្ឋអំណាចស្របច្បាប់។

### ៨.៣. ប្រជាពលរដ្ឋ

ប្រទេសប្រជាធិបតេយ្យតម្រូវឲ្យពលរដ្ឋជាអ្នកមានចំណេះដឹង។ កាលណាសង្គមនោះពលរដ្ឋពុំមានចំណេះដឹង ពួកគេពុំយល់ពីកាតព្វកិច្ចរបស់ខ្លួននោះ គេមិនមែនជាសមាជិករបស់សង្គមប្រជាធិបតេយ្យទេ។ ចំពោះស្ថាប័នបែបនេះ ត្រូវបានប្អាតុង ចាត់ទុកថាជាទម្រង់ប្រជាធិបតេយ្យអសុក្រឹត្យ ដែលនឹងនាំមកនូវភាពវឹកវរ ចលាចល ហើយនៅទីបំផុតវានឹងឈានទៅដល់ការគ្រប់គ្រងដោយអំណាចផ្តាច់ការរបស់ជនប្រជាហិង្សាមួយរូប។ នៅប្រទេសប្រជាធិបតេយ្យរដ្ឋាភិ

[52] ឈុន ណារ៉េត.សេចក្តីផ្តើមវិទ្យាសាស្ត្រនយោបាយ.ភ្នំពេញ.២០១២.ទំព័រទី២៣៧-២៣៨

[53] ឈុន ណារ៉េត.សេចក្តីផ្តើមវិទ្យាសាស្ត្រនយោបាយ.ភ្នំពេញ.២០១២.ទំព័រទី២៣៨

បាលមានភារៈកិច្ចបម្រើប្រជាពលរដ្ឋ ប៉ុន្តែរដ្ឋាភិបាលក៏មិនអាចធ្វើបានដែរប្រសិនបើគ្មានការចូលរួមពីប្រជាពលរដ្ឋពាក់ព័ន្ធនឹងកិច្ចការសាធារណៈទេនោះ។ ក្នុងសង្គមប្រជាធិបតេយ្យ ប្រជាពលរដ្ឋមានសិទ្ធិគ្រប់គ្នា រួមទាំងសិទ្ធិចូលរួមដោះស្រាយបញ្ហាដែលពាក់ព័ន្ធកិច្ចការសាធារណៈ។ សិទ្ធិទាំងនេះអនុវត្តទៅលើមន្ត្រីថ្នាក់ខ្ពស់ ទៅលើពាណិជ្ជករធំៗ និងទៅលើប្រជាពលរដ្ឋដែលរស់នៅក្នុងទីក្រុង និងភូមិស្រុកផងដែរ។ ប្រជាពលរដ្ឋអាចចូលរួមនៅក្នុងកិច្ចការសាធារណៈតាមរបៀបច្រើនយ៉ាង ហើយមធ្យោបាយសំខាន់បំផុតនោះ គឺការបោះឆ្នោត។ ប្រជាពលរដ្ឋបោះឆ្នោតឲ្យគណបក្ស ឬបុគ្គលដែលខ្លួនគិតថា អ្នកទាំងនោះនឹងបំពេញការងារល្អបំផុតជូនប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើសសភាជាតិ ហើយបន្ទាប់មកបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ សន្លឹកឆ្នោតរបស់អ្នកស្រុក អ្នកភូមិម្នាក់ មានតម្លៃស្មើរសន្លឹកឆ្នោតរបស់មន្ត្រីមួយរូប។ តាមរបៀបនេះប្រជាពលរដ្ឋអាចធ្វើការត្រួតពិនិត្យមើលនូវអ្វីដែលរដ្ឋាភិបាលកំពុងធ្វើ។ បើគេពិនិត្យឃើញថារដ្ឋាភិបាលកំពុងតែប្រព្រឹត្តខុសឆ្គង ពួកគេអាចបោះឆ្នោតរើសរដ្ឋាភិបាលមួយថ្មីទៀតនៅអណត្តិក្រោយ។ ប្រជាពលរដ្ឋក៏អាចចូលរួមក្នុងគណបក្សនយោបាយ ហើយក៏អាចឈរឈ្មោះឲ្យគេបោះឆ្នោតបានដែរ។ ប្រជាពលរដ្ឋអាចធ្វើញត្តិស្នើសុំឲ្យរដ្ឋាភិបាលជួយដោះស្រាយបញ្ហារបស់គេផងដែរ។ ញត្តិនេះអាចមានរូបភាពជាលិខិតដែលមានជាលាយលក្ខណ៍អក្សរ ឬស្នើសុំជួបមន្ត្រីផ្ទាល់តែម្តង។ និយាយរួមរបបប្រជាធិបតេយ្យគឺអាស្រ័យលើប្រជាពលរដ្ឋរបស់ខ្លួនដោយចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចការ សាធារណៈដែលពាក់ព័ន្ធនឹងខ្លួនគេផ្ទាល់។ បើសិនជាអ្នកចូលរួមចំណែកយ៉ាងសកម្ម អាចជួយរដ្ឋាភិបាលឲ្យធ្វើអ្វីៗ បានត្រឹមត្រូវ។ ប្រសិនបើអ្នកសង្កេតឃើញថា គណបក្សនយោបាយ ឬបេក្ខជនណាមួយមានលក្ខណៈសម្បត្តិល្អបំផុតនោះ ហើយបោះឆ្នោតតាមការពិចារណាត្រឹមត្រូវ នោះអ្នកនឹងទទួលបានរដ្ឋាភិបាលមួយដ៏ល្អ។ ប្រសិនបើពលរដ្ឋផ្តល់យោបល់ល្អៗជូនទៅរដ្ឋាភិបាល អំពីអ្វីដែលជាគោលនយោបាយត្រូវអនុវត្តរដ្ឋាភិបាលនឹងទទួលបាននូវការយល់ដឹងដ៏ប្រសើរមួយកម្រិតបន្ថែមទៀត នូវអ្វីដែលម្ចាស់ឆ្នោតចង់បាន ហើយរដ្ឋាភិបាលអាចជួយដោះស្រាយបញ្ហានេះជូនបាន។ ប្រសិនបើអ្នកមិនចូលរួមនៅក្នុងកិច្ចការសាធារណៈទេនោះ រដ្ឋាភិបាលអាចនឹងខ្ជិលច្រអូសព្រមទាំងអាចប្រព្រឹត្តខុសឆ្គងថែមទៀតផង។ រដ្ឋាភិបាលអាចប្រព្រឹត្តនូវអំពើបែបនេះ ក៏ដោយសារតែប្រជាពលរដ្ឋមិនផ្តោតយកចិត្តទុកដាក់ ហើយនឹងមិនបានដាក់បង្ខំឲ្យរដ្ឋាភិបាលទទួលខុសត្រូវក្នុងការអនុវត្តន៍ឲ្យបានសមរម្យ។ អ្នកត្រូវតែតាមដានលើកិច្ចការរដ្ឋាភិបាល។ ការចូលរួមរបស់ប្រជាពលរដ្ឋមានសារៈសំខាន់ណាស់ ដើម្បីធ្វើឲ្យដំណើរការរបស់រដ្ឋាភិបាលបានល្អត្រឹមត្រូវ។ ការចូលរួមរបស់ប្រជាពលរដ្ឋ

អាចមានទម្រង់ផ្សេងៗ៖ បោះឆ្នោតចូលរួមក្នុងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បង្កើតសមាគម ធ្វើញត្តិស្នើសុំទៅរដ្ឋាភិបាល។ សិទ្ធិ កាតព្វកិច្ច និងស្មារតីប្រជាពលរដ្ឋក្នុងសង្គមប្រជាធិបតេយ្យសិទ្ធិមាន បោះឆ្នោត ចូលរួម ឬ បង្កើតបក្សនយោបាយ ការពារសិទ្ធិខ្លួនឯង និង គោរពសិទ្ធិអ្នកដទៃ បោះឆ្នោត និងរួមចំណែកក្នុងកិច្ចការរដ្ឋ អត់ធ្មត់ អនុគ្រោះ សម្របសម្រួល សហការ ជជែកវែកញែករកខុសត្រូវ។[54]

ជារួមមក ខែតុលា ឆ្នាំ១៩៩១ កម្ពុជាបានចុះកិច្ចព្រមព្រៀងនៅទីក្រុងប៉ារីសដើម្បីបញ្ចប់ជម្លោះនឹងបានបង្កើតរដ្ឋធម្មនុញ្ញមួយ នៅឆ្នាំ១៩៩៣ ដែលប្រកាន់យករបបប្រជាធិបតេយ្យសេរីពហុបក្សជាក់ស្តែងនៅក្នុងជំពូកទី៤ មាត្រា៥១ នៃរដ្ឋធម្មនុញ្ញបានចែងថា ព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស។ ប្រជាពលរដ្ឋជាម្ចាស់វាសនាប្រទេសជាតិរបស់ខ្លួន។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈ រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និង សាលាជម្រះក្តី។ អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និង អំណាចតុលាការ។ ក្រោយបង្កើតរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ប្រទេសកម្ពុជាបានធ្វើការបោះឆ្នោតជាលើកដំបូងដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិ។ បន្ទាប់មក កម្ពុជាបានរៀបចំការបោះឆ្នោតដោយខ្លួនឯងនៅ ឆ្នាំង១៩៩៨ រហូតមកដល់បច្ចុប្បន្ននេះកម្ពុជាបានធ្វើការបោះឆ្នោតចំនួន៥លើកមកហើយ ដែលមានការចូលរួមពីគណបក្សជាច្រើន និងមានអាណត្តិ៥ឆ្នាំម្តង់ ព្រមទាំងបានបង្កើតនូវស្ថាប័នជាច្រើនដែលធានាដល់ដំណើរនៃលទ្ធិប្រជាធិបតេយ្យដូចជា ស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្តិ តុលាការ ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ គណៈកម្មការជាតិរៀបចំការបោះឆ្នោត គណបក្សនយោបាយ ស្ថាប័នព័ត៌មាន និងអង្គការសង្គមស៊ីវិលជាដើម។

[54] វិទ្យាស្ថានកម្ពុជាដើម្បីសិទ្ធិមនុស្ស សហការជាមួយក្រសួងមហាផ្ទៃ.អភិបាលកិច្ចល្អ និង គោលការណ៍ចាត់ចែង.ទំព័រទី ៩២-៩៣

# ជំពូកទី៣ : ភាពខ្លាំង និងភាពខ្សោយក្នុងការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ

ប្រទេសកម្ពុជាគឺជាប្រទេសមួយដែលបានតស៊ូរើបម្រះពីស្ថានភាពអាក្រក់ៗ ជាច្រើនមានទាំងសង្គ្រាម មានទាំងអំពើជិះជាន់រំលោភបំពានសិទ្ធិមនុស្សជាដើម រហូតមកដល់ពេលបច្ចុប្បន្នប្រទេសកម្ពុជាក៏បានកំពុងវិវត្តខ្លួនទៅរកលទ្ធិប្រជាធិបតេយ្យ ដែលមានលក្ខណៈពេញលេញមួយ។ ក្នុងនោះតួអង្គនៃការចូលរួមនីមួយៗក៏មានចំណុចខ្លាំង និងចំណុចខ្សោយរៀងៗខ្លួនផងដែរ។

## ១. ភាពខ្លាំងរបស់គណបក្សនយោបាយសេរីពហុបក្ស

នៅក្នុងផ្នែកនេះយើងនឹងធ្វើការសិក្សាឲ្យមានភាពស៊ីជម្រៅកាន់តែច្បាស់ថា តើអ្វីខ្លះដែលជាភាពខ្លាំងរបស់គណបក្សនយោបាយសេរីពហុបក្ស នៅក្នុងការអនុវត្តន៍ប្រជាធិបតេយ្យនៅកម្ពុជា។ នៅក្នុងកំណាក់កាលនៃការកែលម្អរការសិក្សានេះ យើងបានខិតខំប្រឹងប្រែងវែកញែកបែងចែកឲ្យបានឃើញអំពីភាពខ្លាំងដើម្បីទទួលបាននូវរូបភាពដ៏ល្អប្រសើរមួយ នៃសភាពការណ៍អភិវឌ្ឍលទ្ធិប្រជាធិបតេយ្យមូលដ្ឋាននៅកម្ពុជា។ តាមការសិក្សាបានបញ្ជាក់ឲ្យឃើញថា ភាពខ្លាំងរបស់គណបក្សនយោបាយសេរីពហុបក្ស នៅកម្ពុជាដែលមានចំណុចខ្លាំងរបស់ខ្លួនជាច្រើនក្នុងការជួយជម្រុញឲ្យមានការអនុវត្តន៍ប្រជាធិបតេយ្យឲ្យ បានកាន់តែប្រសើរជាងនេះទៅទៀត។ ចំណុចខ្លាំងទាំងនោះរួមមាន ផែនការ និងយុទ្ធសាស្ត្រ ទិសដៅក្នុងការអភិវឌ្ឍន៍ប្រទេសច្បាស់លាស់ មានរចនាសម្ព័ន្ធពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិត្រឹមត្រូវ មានការត្រួតពិនិត្យវាយតម្លៃ មានឆន្ទៈ និងការប្តេជ្ញាចិត្ត មានសមត្ថភាពគ្រប់គ្រងសមាជិករបស់ខ្លួនពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោយជាតិ មានការគាំទ្រពីសំណាក់ប្រជាពលរដ្ឋយ៉ាងច្រើនកុះករ ហើយក៏មានការទទួលស្គាល់ពីរដ្ឋាភិបាលយ៉ាងត្រឹមត្រូវផងដែរ លើសពីនេះទៀតក៏មានការគាំទ្រពីអង្គការអន្តរជាតិផ្សេងៗ និងប្រទេសមួយចំនួនដែលប្រកាន់ភ្ជាប់នូវលទ្ធិប្រជាធិបតេយ្យដែរ មានប្រភពចំណូលថវិកាច្បាស់លាស់ មានភាពស្មោះត្រង់ ជាពិសេសនោះអ្នកដឹកនាំគណបក្សមានចំណេះដឹងជ្រៅជ្រះបក្សមានធនធានមនុស្សគ្រប់គ្រាន់។ ដោយយោងទៅតាមចំណុចទាំងអស់នេះហើយ ទើបយើងអាចបញ្ជាក់ឲ្យឃើញអំពីភាពខ្លាំងរបស់ គណបក្សនយោបាយនៅកម្ពុជា។ គណបក្សនយោបាយគឺជាដៃគូយ៉ាងសំខាន់ជាមួយនឹងរដ្ឋាភិបាល ក្នុងការអនុវត្តន៍ប្រជាធិបតេយ្យក៏ដូចជាការអភិវឌ្ឍន៍ប្រទេស ហើយក៏ជាអ្នកប្រឆាំង ឬតស៊ូមតិធំជាងគេហើយមានឥទ្ធិពលជាងគេផងដែរ។ គួរបញ្ជាក់

ផងដែរថាប្រទេសប្រកាន់យករបបលទ្ធិប្រជាធិបតេយ្យ គឺចាំបាច់ត្រូវតែមានគណបក្សនយោបាយជាដាច់ខាត បើមិនមានគណបក្សនយោបាយទេនោះមិនហៅថា របបលទ្ធិប្រជាធិបតេយ្យទេ របបប្រជាធិបតេយ្យសូម្បីតែរាជរដ្ឋាភិបាលក៏កើតចេញពីគណបក្សនយោបាយដែរ គណបក្សនយោបាយគឺជាគូប្រគួតប្រជែងនៅពេលមានការបោះឆ្នោតម្តងៗ ហើយបើមានគណបក្សនយោបាយកាន់តែច្រើននោះការអភិវឌ្ឍន៍ក៏មានការរីកចម្រើនកាន់តែខ្លាំងដែរ ។

## ២. ភាពខ្លាំងរបស់ស្ថាប័នទាំងបី

ដូចនៅបណ្តាលប្រទេសប្រកាន់យកលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្សនានាដែរ កម្ពុជាប្រកាន់យកប្រព័ន្ធបែងចែកអំណាចកំពូលជាបីដាច់ដោយឡែកនឹងឯករាជ្យពីគ្នា គឺស្ថាបន័នីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ សំដៅធានានិរន្តរភាពនៃអំណាចរដ្ឋ។ អំណាចទាំងអស់គឺជារបស់ប្រជាពលរដ្ឋហើយប្រជាពលរដ្ឋប្រើសិទ្ធិអំណាចខ្លួនតាមរយៈ រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងតុលាការ។

### ២.១. ស្ថាប័ននីតិប្បញ្ញត្តិ

ប្រទេសកម្ពុជាបានបែងចែកស្ថាប័ននីតិប្បញ្ញត្តិជាពីរថ្នាក់រួមមាន៖ រដ្ឋសភា និងព្រឹទ្ធសភា។ រដ្ឋសភា គឺជាសភាតំណាងរាស្រ្ត ដែលកើតចេញពីការបោះឆ្នោត ជាសកល ដោយសេរី ស្មើភាព និងចំពោះ ហើយតាមវិធីបោះឆ្នោតជាសម្ងាត់ សម្រាប់អាណត្តិ៥ឆ្នាំ។ រដ្ឋសភាមានសិទ្ធិអំណាចជាអាទ៍ បោះឆ្នោតផ្តល់សេក្តីទុកចិត្ត ឫទម្លាក់រដ្ឋាភិបាល ឫសមាជិកគណៈរដ្ឋមន្រ្តី ធ្វើសេក្តីស្នើច្បាប់ អនុម័តច្បាប់ ថវិការដ្ឋ និងផែនការរដ្ឋ ព្រមទាំងផ្តល់សច្ចាប័នលើសន្ធិសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ។ គណៈកម្មការរបស់រដ្ឋសភាមានសិទ្ធិអញ្ជើញរដ្ឋមន្រ្តីមកបំភ្លឺអំពីបញ្ហាពាក់ព័ន្ធនឹងវិស័យដែលខ្លួនទទួលខុសត្រូវ។ ចំណែកក្រុមតំណាងរាស្រ្តមានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់ ពិភាក្សាច្បាប់ស្នើធ្វើវិសោធនកម្មច្បាប់ និងចោទសួររដ្ឋាភិបាល។ បច្ចុប្បន្នរដ្ឋសភាមានសមាជិកចំនួន ១២៣រូបហើយនឹងកើនឡើងដល់១២៥រូបនៅក្នុងការបោះឆ្នោតឆ្នាំ២០១៨។ អង្គការដឹកនាំកំពូលរបស់រដ្ឋសភា គឺគណៈកម្មាធិការអចិន្រ្តៃយ៍រដ្ឋសភា ដែលដឹកនាំដោយប្រធាន និងអនុប្រធានពីរូប ដោយមានប្រធានគណៈកម្មការទាំង១០ ជាសមាជិក។ រដ្ឋសភា ជាស្ថាប័ននីតិប្បញ្ញត្តិកំពូល បន្ទាប់ពីព្រឹទ្ធសភា របស់ប្រទេសកម្ពុជា។ ក្នុងនាមជាស្ថាប័នកំពូលដូច្នេះហើយទើបរដ្ឋសភាបានខិតខំអនុវត្តនូវតួនាទី និងអំណាចសំខាន់ៗមួយចំនួនស្របតាមរដ្ឋធម្មនុញ្ញ ដូចជា រដ្ឋសភា បានធ្វើការផ្តួចផ្តើម និងអនុម័តច្បាប់ ហើយច្បាប់នោះបានធ្វើឡើងស្របតាមពី

ឆន្ទៈទូទៅរបស់រាស្ត្រ។ ម្យ៉ាងវិញទៀតច្បាប់ដែលរដ្ឋសភា បានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ត្រូវបានព្រះមហាក្សត្រឡាយព្រះហស្តលេខាប្រកាសឲ្យប្រើត្រូវចូលជាធរមាន នៅរាជធានីភ្នំពេញ ក្នុងរយៈពេល១០ថ្ងៃគត់ក្រោយថ្ងៃប្រកាសឲ្យប្រើ និងទូទាំងប្រទេសក្នុងរយៈពេល២០ថ្ងៃក្រោយប្រកាសឲ្យប្រើ។ ប៉ុន្តែច្បាប់ណាមួយ ចែងថាជាច្បាប់ប្រញាប់ ត្រូវចូលជាធរមានភ្លាមក្រោយថ្ងៃប្រកាសឲ្យប្រើ។ រដ្ឋសភា ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ និងច្បាប់ផ្សេងៗដែលអនុម័តដោយរដ្ឋសភាតាមមតិភាគច្រើន ២/៣ នៃចំនួនសមាជិកសភាទាំងមូល និងមានសំណើររបស់អ្នកតំណាងរាស្ត្រយ៉ាងតិច ១/៤ នៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ការធ្វើវិសោធនកម្មច្បាប់ នឹងមិនអាចទទួលយកបានទេ បើការធ្វើនោះសំដៅបន្ថយប្រាក់ចំណូលសាធារណៈ រឺបន្ថែមបន្ទុកលើប្រពលរដ្ឋ។ រដ្ឋសភាបានបោះឆ្នោតផ្តល់សេចក្តីទុកចិត្តដល់រាជរដ្ឋាភិបាតាមមតិភាគច្រើន២/៣ នៃសមាជិកសភាទាំងមូល។ នេះជាគោលការណ៍សំខាន់មួយក្នុងចំណោមគោលការណ៍សំខាន់ជាច្រើននៅក្នុងរបបសភានិយម។ នេះវាបង្ហាញនូវឆន្ទៈស្របគ្នាខាងនយោបាយដឹកនាំប្រទេសរវាងស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ។ ជាពិសេសអ្វីដែលគួឲ្យកត់សម្គាល់នោះគឺរដ្ឋសភាបានកើតចេញពីការបោះឆ្នោតដោយស្មើភាព ដោយផ្ទាល់ ដោយសេរី ដោយសម្ងាត់ និងជាសកល។

រីឯព្រឹទ្ធសភាវិញមានសមាជិកចំនួនមិនលើសពីពាក់កណ្តាល នៃចំនួនសមាជិករដ្ឋសភាទេ។ សមាជិក២រូប ត្រូវបានចាត់តាំងឡើងដោយ ព្រះមហាក្សត្រ និងសមាជិក២រូបត្រូវបានជ្រើសតាំងដោយរដ្ឋសភា តាមមតិភាគច្រើន ហើយសមាជិកផ្សេងទៀត ត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកលសម្រាប់អាណត្តិ៦ឆ្នាំ។ ព្រឹទ្ធសភាមានសិទ្ធិអំណាច ជាអាទិ៍ ពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ បន្ទាប់ពីរដ្ឋសភាបានអនុម័តយល់ព្រមរួច និងបញ្ហាសំខាន់ៗមួយចំនួនទៀត។ អង្គការដឹកនាំកំពូលរបស់ព្រឹទ្ធសភា គឺគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដែលដឹកនាំដោយប្រធាន និងអនុប្រធានពីររូប ដោយមានប្រធានគណៈកម្មការទាំង១០ជាសមជិក។ ព្រឹទ្ធសភា ជាចំណែកមួយ នៃអង្គនីតិប្បញ្ញត្តិរបស់ជាតិ ដែលបានរួមចំណែកក្នុងដំណើរការប្រជាធិបតេយ្យ ភាវូបនីយកម្មសង្គម និងការកសាងកម្ពុជា ជានីតិរដ្ឋ ហើយបានរួមវិភាគទាននៅក្នុង ដំណើរការស្ថិរភាវូបនីយកម្មជីវភាពនយោបាយរបស់ជាតិ ដែលជាស្នូលនៃការពង្រឹងនយោបាយ បង្រួបបង្រួម ផ្សះផ្សាជាតិ និងការអភិវឌ្ឍន៍។ ព្រឹទ្ធសភា បានសម្របសម្រួល

ការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល (រដ្ឋធម្មនុញ្ញ មាត្រា១១២ថ្មី)។ ព្រឹទ្ធសភាពិនិត្យ ហើយឲ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តយល់ព្រមជាលើកដំបូងរួចហើយ ព្រមទាំងលើបញ្ហាទាំងពួង ដែលរដ្ឋសភាបានដាក់ឲ្យពិនិត្យ។ បើជាការប្រញាប់រយៈពេលនោះ ត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ។ បើព្រឹទ្ធសភាបានឲ្យយោបល់យល់ព្រម ឬពុំបានឲ្យយោបល់សោះក្នុងរយៈពេលមួយដែលមានកំណត់ទុក ហើយនោះទេច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមហើយនោះ នឹងត្រូវបានយកទៅ ប្រកាសឲ្យប្រើ។ បើព្រឹទ្ធសភាសុំឲ្យកែសម្រួលសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ រដ្ឋសភា ត្រូវយកមក ពិចារណាភ្លាមជាលើកទីពីរ។ រដ្ឋសភា ត្រូវពិនិត្យ និងសម្រេចតែត្រង់បទប្បញ្ញត្តិ ឬចំណុចណាដែលព្រឹទ្ធសភាសុំកែសម្រួល ដោយបដិសេធចោលទាំងមូល ឬទុកជាបានការខ្លះ។ ការបង្វិលទៅបង្វិលមករវាងព្រឹទ្ធសភា និងរដ្ឋសភា ត្រូវធ្វើតែក្នុងរយៈពេលមួយខែ។ រយៈពេលនេះ ត្រូវបន្ថយមកត្រឹមដប់ថ្ងៃ បើត្រូវពិនិត្យសម្រេចពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែពីរថ្ងៃ បើជាការប្រញាប់។ បើរដ្ឋសភាទុកហួសរយៈពេលកំណត់ ឬពន្យារពេលដែលកំណត់ទុកសម្រាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សម្រាប់រដ្ឋសភា និងព្រឹទ្ធសភាត្រូវបន្ថែមស្មើគ្នាដែរ។ បើព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះជាអសារបង់ រដ្ឋសភាមិនអាចនឹងយកមកពិចារណាជាលើកទីពីរបានមុនរយៈពេលមួយខែទេ។ រយៈពេលនេះ ត្រូវបន្ថយមកត្រឹមដប់ប្រាំថ្ងៃ បើពិនិត្យពីថវិកាជាតិ និងហិរញ្ញវត្ថុ ហើយមកត្រឹមតែបួនថ្ងៃ បើជាការប្រញាប់។ ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ជាលើកទី២នេះ រដ្ឋសភា ត្រូវអនុម័តដោយ វិធីបោះឆ្នោតចំហ និងយកតាមមតិភាគច្រើនដាច់ខាត។ សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ណាដែលបានសម្រេចដូចខាងលើនេះហើយនោះ នឹងត្រូវបានយកទៅប្រកាសប្រើ (រដ្ឋធម្មនុញ្ញមាត្រា១១៣ថ្មី)។

### ២.២. ស្ថាប័ននីតិប្រតិបត្តិ

រាជរដ្ឋាភិបាលគឺជាស្ថាប័ននីតិប្រតិបត្តិ ដឹកនាំដោយនាយករដ្ឋមន្ត្រីមួយរូបជាតំណាងរាស្ត្រនៃគណបក្សឈ្នះឆ្នោត អមដោយឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាសមានជិកដែលត្រូវបានបោះឆ្នោតផ្តល់សេចក្តីទុកចិត្តដោយរដ្ឋសភា ហើយព្រះមហាក្សត្រឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។ រាជរដ្ឋាភិបាលមានភារៈកិច្ចដឹកនាំប្រទេស ធ្វើសេចក្តីព្រាងច្បាប់ ធ្វើផែនការអភិវឌ្ឍន៍ស្នើគម្រោងថវិកាជាតិ ការពារលទ្ធិ

ប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស និងការអនុវត្តន៍គោលនយោបាយការបរទេស ជាដើម។ រាជរដ្ឋាភិបាលគ្រប់គ្រង បញ្ជា និងប្រើប្រាស់យោធា នគរបាល និងកងកម្លាំងប្រដាប់អាវុធគ្រប់គ្រងប្រទេស ដើម្បីធានា និងការពារសន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ បូរណភាពទឹកដី និងអធិបតេយ្យភាពជាតិ។ រាជរដ្ឋាភិបាលដឹកនាំការចរចា និងចុះហត្ថលេខាលើ កិច្ចព្រមព្រៀងនានាជាអាទិ៍ កិច្ចព្រមព្រៀងពាក់ព័ន្ធទៅនឹងវិស័យពាណិជ្ជកម្ម សហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេស។ ដោយគោរពតាមគោលការណ៍នៃការបែងចែកអំណាចរដ្ឋ។ រាជរដ្ឋាភិបាលរក្សាកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ននីតិប្បញ្ញត្តិ និងតុលាការ។ ទន្ទឹមនឹងនេះរាជរដ្ឋាភិបាល ត្រូវពិនិត្យជាបន្តបន្ទាប់នូវគោលនយោបាយ និងកំណែទម្រង់លើគ្រប់វិស័យ ជាពិសេសកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដើម្បីជម្រុញការបំពេញការងារឲ្យកាន់តែមានឯករាជ្យភាព និងប្រសិទ្ធិភាព។ រាជរដ្ឋាភិបាលសហការយ៉ាងជិតស្និទ្ធជាមួយវិស័យអង្គការសារព័ត៌មាន សង្គមស៊ីវិល និងហាជីព ក្នុងភាពជាដៃគូ ដើម្បីធានាកំណើនសេដ្ឋកិច្ច លទ្ធិប្រជាធិបតេយ្យសិទ្ធិសេរីភាពជាមូលដ្ឋាន អភិបាលកិច្ចល្អ និងយុត្តិធម៌សង្គម។ រាជដ្ឋាភិបាលទទួលខុសត្រូវចំពោះមុខរដ្ឋសភាអំពីនយោបាយក្នុងស្រុក និងការបរទេស ហើយសមាជិករាជរដ្ឋាភិបាលម្នាក់ៗ ត្រូវទទួលខុសត្រូវចំពោះមុខនាយករដ្ឋមន្ត្រី និងរដ្ឋសភា។ ប្រមុខរាជរដ្ឋាភិបាល និងសមាជិករាជរដ្ឋាភិបាលអាចទៅឆ្លើយបំភ្លឺជូនរដ្ឋសភា ឬឆ្លើយតបជាលាយលក្ខណ៍អក្សរជូនតំណាងរាស្ត្រ តាមការស្នើសុំលើបញ្ហាជាក់លាក់ណាមួយ។

រដ្ឋាភិបាលបានធ្វើឲ្យមានប្រព័ន្ធនយោបាយសង្គមបើកចំហរ រដ្ឋធម្មនុញ្ញញសេរី មន្ត្រីរាជការឈរខាងលទ្ធិប្រជាធិបតេយ្យ មានការប្តេជ្ញាចិត្តឆន្ទៈនយោបាយ សេដ្ឋកិច្ចទីផ្សារសេរីមានការបោះឆ្នោត (៥លើករួចមកហើយ) រដ្ឋាភិបាលបានអនុញ្ញាតឲ្យមជ្ឈមណ្ឌលនៃសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (UNCHR) បើកធ្វើសកម្មភាពដោយចំហ សេរីភាពព័ត៌មាន និងច្បាប់ព័ត៌មានច្បាប់ការងារ (សេរីភាពសហជីបជីវករ) កម្ពុជាទទួលយកសន្ធិសញ្ញា និងសន្និបាតអន្តរជាតិខាងសិទ្ធិមនុស្សមិនត្រឡប់ទៅរកភាពមានគ្រោះថ្នាក់ ឬអន្លង់អន្ទាក់អតីតកាល។ ការកើតឡើងនៃសង្គមស៊ីវិល ដែលមានវត្ថុធាតុជាថាមពលថ្មីការទទួលស្គាល់ពីអន្តរជាតិ មានសហប្រតិបត្តិការជិតស្និតជាមួយម្ចាស់អំណោយអន្តរជាតិ រដ្ឋាភិបាលមានផែនការមេច្បាស់លាស់សម្រាប់អភិវឌ្ឍមានកម្មវិធីនយោបាយបកំណែទម្រង់វិមជ្ឈការ (Decentralization) ប្រជាពលរដ្ឋស៊ីវិល មានឧត្តម

ភាពជាងយោធា ការបង្កើតស្ថាប័ននយោបាយថ្មី (គ.ជ.ប) ការផ្តល់អំណាចឲ្យសភាជាតិតួនាទីថ្មីរបស់គណបក្សប្រឆាំង និងសហប្រតិបត្តិការជាមួយសង្គមស៊ីវិល។[55]

### ២.៣. ស្ថាប័នតុលាការ

ទំនាក់ទំនងស្ថាប័នតុលាការនៅក្នុងសង្គម មានទិសដៅលើរាល់សកម្មភាពទាំងឡាយ ដូចជាវិស័យសេដ្ឋកិច្ច វប្បធម៌ នយោបាយ។ ដោយជួយឧបត្ថម្ភ និងជួយការពារសិទ្ធិ សេរីភាពរបស់គេ។ តុលាការ គឺជាអំណាចដែលត្រូវបានកំណត់ឡើងសម្រាប់វិនិច្ឆ័យស្វែងរកយុត្តិធម៌ ក្នុងទំនាស់រវាងបុគ្គល និងរវាងរដ្ឋ។ អំណាចតុលាការ ជាអាជ្ញាកណ្តាលនៅពេលដែលអំណាចនីតិប្បញ្ញត្តិ និងអំណាចនីតិប្រតិបត្តិមានទំនាស់នឹងគ្នា។ អំណាចតុលាការជាអំណាចឯករាជ្យ (មាត្រា ១២៨ ថ្មី នៃរដ្ឋធម្មនុញ្ញ) ។ បំពេញមុខងារក្នុងអំណាចតុលាការនេះបានត្រឹមត្រូវគឺមានន័យថាសង្គមផ្គត់ផ្គង់បាននូវសន្តិសុខ យុត្តិធម៌សមភាព និងសេរីភាពពលរដ្ឋ។ កិច្ចការរបស់តុលាការ គឺកាត់ក្តីឲ្យបានត្រឹមត្រូវតាមច្បាប់ដែលបានអនុម័ត។ តុលាការមិនមែនជាស្ថាប័នចាប់ចងទេ តែជាស្ថាប័នការពារសិទ្ធិ នៅពេលដែលកើតឡើងនូវការរំលោភសិទ្ធិ។

តុលាការជាស្ថាប័នឯករាជ្យ ដែលធានារក្សាអនាគត់និងការពារសិទ្ធិសេរីភាពពលរដ្ឋ។ អំណាចតុលាការគ្របដណ្តប់លើរឿងក្តីទាំងអស់។ អំណាចនីតិប្បញ្ញត្តិ ឬនីតិប្រតិបត្តិមិនអាចជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់អំណាចតុលាការបានឡើយ។ ព្រះមហាក្សត្រធានា ឯករាជ្យភាព នៃអំណាចតុលាការ ដែលមានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាសេនាធិការ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម លើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រអំពីការតែងតាំងចៅក្រម និងព្រះរាជអាជ្ញាអមសាលាជម្រះក្តី។ ចៅក្រមមានសិទ្ធិជម្រះក្តី និងត្រូវបំពេញកិច្ចការដោយឯករាជ្យ និងគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ ទណ្ឌកម្មវិន័យពាក់ព័ន្ធនឹងករណីអសមត្ថភាព កំហុសផ្នែកវិន័យ និងក្រមសីលធម៌វិជ្ជាជីវៈរបស់ចៅក្រមនិងព្រះរាជអាជ្ញា ត្រូវបានត្រួតពិនិត្យនិងចាត់វិធានការ ដោយក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ទន្ទឹមនឹងនេះដើម្បីបណ្តុះបណ្តាលធនធានមនុស្សបន្ថែមប្រកបដោយសមត្ថភាពនិងវិជ្ជាជីវៈក្នុងវិស័យយុត្តិធម៌ រាជរដ្ឋាភិបាលបានបង្កើតរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ ដែលមានសាលាជំនាញចំនួន៤គឺ សាលាភូមិន្ទចៅក្រម សាលាភូមិន្ទក្រឡាបញ្ជី សាលាភូមិន្ទសារការី និងសាលាភូមិន្ទអាជ្ញាសាលាព្រមទាំងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី។[56]

[55] អ៊ុំ សុភក្តិ.ហេង ឌី.អែល ឃុន. លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅកម្ពុជា.ឆ្នាំ២០០៦.ទំព័រទី៥៩

## ៣. ភាពខ្លាំងរបស់អង្គការក្រៅរដ្ឋាភិបាល ឬសង្គមស៊ីវិល

ចំណុចខ្លាំងរបស់អង្គការពុំមែនរដ្ឋាភិបាលរួមមាន ផែនការយុទ្ធសាស្ត្រច្បាស់លាស់ ចំនួនខាងថវិកា ការទទួលស្គាល់ពីរដ្ឋាភិបាលពីប្រជាពលរដ្ឋ ពីម្ចាស់អំណោយ សហប្រតិបត្តិស្និតជាមួយរដ្ឋាភិបាល មានការ ត្រួតពិនិត្យវាយតម្លៃ និងសិក្ខាសាលាច្រើន មានការត្រួតពិនិត្យពីម្ចាស់អំណោយបង្កើតការអប់រំដោយ ខ្លួនឯង ការស្ថាបនាបទពិសោធន៍ និងព័ត៌មានសហប្រតិបត្តិការរវាងអង្គការ (NGOs) គ្នាឯងមាននិន្នាការឆ្ពោះទៅរកទម្រង់ មានឆន្ទៈ និងការប្តេជ្ញាចិត្ត។ អង្គការពុំមែនរដ្ឋាភិបាល ឬ (NGOs) កំពុងពេញនិយម សន្តិភាព និងស្នេរភាពរដ្ឋាភិបាលទទួលស្គាល់ និងគាំទ្រភាពជាដៃគូរជាមួយរដ្ឋាភិបាល ប្រជាពលរដ្ឋ មានជំនឿ និងត្រូវការអង្គការពុំមែនរដ្ឋាភិបាល។[57]

## ៤. ភាពខ្លាំងប្រជាពលរដ្ឋ

ដើម្បីឲ្យកម្ពុជាសម្បូរដោយអ្នកនយោបាយដែលមានសន្តានចិត្ត និងមានប្រជាធិបតេយ្យពិតប្រាកដ បម្រើប្រជាពលរដ្ឋ និងសង្គម កាត់បន្ថយអ្នកនយោបាយបោកប្រាស់ប្រជាពលរដ្ឋបំផ្លាញផលប្រយោជន៍ជាតិនោះទាមទារឲ្យ ពលរដ្ឋខ្លួនឯងដែលជាម្ចាស់ប្រទេស ត្រូវតែចូលរួមតាមដានសកម្មភាពរបស់អ្នកនយោបាយឲ្យបានច្រើនជាងមុន។ ពលរដ្ឋត្រូវតែ មានមនសិការជានិច្ចថា បញ្ហារបស់ជាតិ ក៏ជាបញ្ហារបស់ខ្លួនឯងដែរ។ ជាងនេះទៅទៀត ពលរដ្ឋត្រូវហ៊ានបញ្ចេញមតិ និងហ៊ានក្រោកតវ៉ា ប្រឆាំងនឹងអ្នកនយោបាយដែលមិនបម្រើប្រជាពលរដ្ឋពិតប្រាកដ។ យ៉ាងណាក៏ដោយចុះ ក្នុងរយៈពេលចុងក្រោយនេះ ពោលគឺក្នុងអំឡុងពេលបោះឆ្នោត និងក្រោយការបោះឆ្នោតអាណត្តិទី៥នេះ ពលរដ្ឋកម្ពុជាហាក់ផ្លាស់ប្តូរផ្នត់គំនិតចាស់របស់ខ្លួនចោលច្រើនគួរឲ្យកត់សម្គាល់ដែរ។ ប្រជាពលរដ្ឋជាច្រើន បានងាកមកតាមដានព័ត៌មាន និងតាមដានស្ថានការណ៍នយោបាយរបស់ប្រទេស។ ពួកគេចាប់ផ្តើមជជែកពីរឿងអ្នកនយោបាយ និងបញ្ចេញយោបល់រិះគន់អ្នកនយោបាយដែលបោកប្រាស់ប្រជាពលរដ្ឋមួយចំនួន ហើយពេលខ្លះពួកគេថែមទាំងក្រោកតវ៉ាប្រឆាំងនឹងអ្នកនយោបាយទាំងនោះទៀតផង។ នេះជាសញ្ញាណល្អ សម្រាប់ប្រទេសដែល

---

[56] សៀវភៅស.ស្តីពីស្ថានការណ៍នយោបាយនៅកម្ពុជា(ទីស្តីការគណៈរដ្ឋមន្ត្រី២០១៨)ទំព័រទី៨-៩

[57] អ៊ុំ សុភក្តិ.ហេង ឌី.អែល យុន. លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅកម្ពុជា.ឆ្នាំ២០០៦.ទំព័រទី៥៨

ប្រកាន់យករបបប្រជាធិបតេយ្យ ហើយវាក៏ជាតម្រូវការដែលមិនអាចខ្វះបានសម្រាប់មាតុភូមិ ដែលធ្លាប់រក់រីនៅក្នុងភ្លើងសង្គ្រាមមួយនេះ។ កន្លងមកនេះ ប្រជាពលរដ្ឋ និងអ្នកតាមដានស្ថានការណ៍នយោបាយមួយចំនួន តែងតែប្រួតគ្នាស្តីបន្ទោស និងរិះគន់អ្នកនយោបាយគ្រប់ៗគ្នា នៅពេលដែលពួកគេសង្កេតឃើញអ្នកនយោបាយខ្មែរខ្លះ មានចរិតអត្មានិយម ពុករលួយ ភូតកុហកប្រជាពលរដ្ឋដើម្បីបំពេញការស្រេកឃ្លានផ្នែកនយោបាយរបស់ខ្លួន។

## ៥. ភាពខ្សោយគណបក្សនយោបាយសេរីពហុបក្ស

ក្នុងពេលបច្ចុប្បន្ន នៅប្រទេសកម្ពុជា ប្រជាប្រិយភាពរបស់គណបក្សនយោបាយបានធ្លាក់ចុះ។ ប្រជាជនបានបាត់បង់ការយកចិត្តទុកដាក់ចំពោះកិច្ចការគណបក្ស ដែលជាកត្តាធ្វើឲ្យមានការចូលរួមបោះឆ្នោតត្រូវធ្លាក់ចុះដោយសារតែ ប្រជាពលរដ្ឋគិតថាប្រជាធិបតេយ្យត្រូវបានស្លាប់ក្រោយតុលាការកំពូលប្រកាសរម្លាយ គណបក្សសង្គ្រោះជាតិ ដែលជាគណបក្ស ប្រឆាំងធំជាងគេនៅប្រទេសកម្ពុជា។ រូបភាពនេះសឲ្យឃើញថាកិច្ចការគណបក្សនយោបាយ ហាក់បីដូចជាមានភាពដោយឡែកពីប្រជាជនព្រោះមិនឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាជន បើនិយាយជារួមទៅគឺមិនបានបំពេញនូវកិច្ចសន្យារបស់ខ្លួននៅចំពោះមុខប្រជាពលរដ្ឋ។ ដោយសារតែមានសកម្មភាពរបស់គណបក្ស អង្គការនយោបាយមហាជន អង្គការនានា និងចលនាផ្សេងៗនេះហើយ ដែលបានបង្កើតមានជាសង្គមស៊ីវិលប្រកបដោយយន្តការ ដំណោះស្រាយដោយខ្លួនឯង និងមានទិសដៅដំណោះស្រាយបម្រើផលប្រយោជន៍មហាជន។ និយាយឲ្យខ្លីទៅយើងក៏មិនអាចសង្ឃឹម និងសន្និដ្ឋានបានដែរថា ចលនាគណបក្សនយោបាយតូចៗ និងអង្គការមហាជន អាចកំណត់អនាគតប្រទេសជាតិ ដំណោះស្រាយវិបត្តិដែលកើតជារឿយៗក្នុងសង្គម និងនាំឲ្យមានវឌ្ឍនភាព ដែលប្រកបដោយវប្បធម៌ប្រជាធិបតេយ្យមួយដ៏ស្អាតស្អំ។ រាល់គ្រប់កិច្ចការរបស់គណបក្សនៅក្នុងសង្គមសុទ្ធតែមានផលប្រយោជន៍ និងមានគោលបំណងច្បាស់លាស់។ ជាពិសេសសកម្មភាពរបស់គណបក្សដើម្បីអំណាច និងមានគោលបំណងច្បាស់លាស់ដើម្បីការពារផលប្រយោជន៍របស់ពួកគេនៅក្នុងប្រព័ន្ធនយោបាយ។ តាមការសិក្សាបានបញ្ជាក់ពីភាពខ្សោយរបស់គណបក្សនយោបាយសេរីពហុបក្ស នៅកម្ពុជាដែលមានចំណុចខ្សោយរបស់ខ្លួនជាច្រើនក្នុងការជួយជម្រុញឲ្យមាន ការអនុវត្តន៍ប្រជាធិបតេយ្យឲ្យបានកាន់តែប្រសើរជាងនេះទៀត។ ចំណុចខ្សោយទាំងនោះរួមមាន កង្វះការយល់ដឹងត្រឹមត្រូវអំពីសេចក្តីត្រូវការ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋ មានមោទនភាពហួស ខ្វះខាតមនោគមន៍វិជ្ជារបស់បក្ស ខ្វះខាតវិធីសាស្ត្រក្នុងការធ្វើ

ឲ្យប្រជាពលរដ្ឋជឿទុកចិត្តបក្សរបស់ខ្លួនមិនសូវជាមានឱកាសបានសម្តែងមតិនៅទីកន្លែងសាធារណៈ ខ្វះខាតប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ពិបាករកមនុស្សហ៊ានលះបង់ដើម្បីជាតិខ្វះការលើកទឹកចិត្តពីរដ្ឋាភិបាល បក្សខ្លះទៀតបង្កើតឡើងមកដើម្បីបំពេញមុខមាត់ និងបម្រើផលប្រយោជន៍ផ្ទាល់ខ្លួន ឬក្រុមរបស់ខ្លួន លាបពណ៌ឲ្យគ្នាទៅវិញទៅមក គោលនយោបាយទន់ខ្សោយ ច្បាប់ធូរលុងពេកងាយស្រួលបង្កើតហើយក៏ងាយស្រួលរម្លាយ ប្រភពចំណូលថវិកាតិចតួចពឹងផ្អែកតែងលើម្ចាស់អំណោយ។ ចំណុចទាំងអស់នេះហើយដែលបង្ហាញពីភាពទុនខ្សោយរបស់គណបក្សនយោបាយ ហើយជាផ្នែកមួយដែលធ្វើឲ្យគណបក្សប្រឆាំងមិនសូវមានការគាំទ្រ ឬអាចនិយាយបានថាមិនអាចយកឈ្នះគណបក្សកាន់អំណាចក្នុងរយៈពេលខ្លីបានឡើយ។

## ៦. ភាពខ្សោយរបស់ស្ថាប័នទាំងបី

### ៦.១. នីតិប្បញ្ញត្តិ

ក្នុងប្រទេសប្រកាន់យកលទ្ធិប្រជាធិបតេយ្យ រដ្ឋសភាដែលជាអង្គនីតិប្បញ្ញត្តិ ឬជាស្ថាប័នតាក់តែងច្បាប់ មានតួនាទីសំខាន់ខ្លាំងណាស់ក្នុងការជួយធ្វើឲ្យសង្គមជាតិស្អាតស្អំ គ្មានអំពើពុករលួយ និងលើកស្ទួយការគោរពច្បាប់។ រដ្ឋសភាអាចសម្រេចគោលដៅទាំងនេះបាន តាមរយៈការធ្វើច្បាប់ល្អ តាមដានសកម្មភាពអនុវត្តច្បាប់របស់រដ្ឋាភិបាល និងកោះហៅមន្ត្រីរដ្ឋាភិបាលមកឆ្លើយបំភ្លឺ ជាដើម។ ប៉ុន្តែបទបញ្ជាផ្ទៃក្នុងរដ្ឋសភារយៈពេលកន្លងមកនេះ ជាឧបសគ្គរាំងមិនឲ្យមានការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យពេញលេញឡើយ។ រដ្ឋសភា ជាស្ថាប័នជាតិកំពូលមួយក្នុងចំណោមស្ថាប័នកំពូលទាំងបី។ ស្ថាប័នកំពូលពីរទៀត មានរាជរដ្ឋាភិបាល និងតុលាការ។ រដ្ឋធម្មនុញ្ញកម្ពុជា កំណត់ឲ្យស្ថាប័នទាំងបីនេះ បែងចែកអំណាចដាច់ពីគ្នា និងប្រកាន់យកប្រព័ន្ធនយោបាយសភានិយម ដែលរដ្ឋសភាមានតួនាទី និងអំណាចធំសម្បើម។ អំណាចទាំងនោះរួមមាន ត្រួតពិនិត្យសកម្មភាពរបស់រដ្ឋាភិបាល រហូតដល់អាចទម្លាក់សមាជិកគណៈរដ្ឋមន្ត្រី ឬទម្លាក់រាជរដ្ឋាភិបាលទាំងមូលទៀតផង។ ប៉ុន្តែ រហូតមកដល់ចុងអាណត្តិទី៥ សហគមន៍ជាតិ និងអន្តរជាតិ មើលឃើញថា រដ្ឋសភាកម្ពុជា មិនត្រឹមតែមិនបានប្រើប្រាស់អំណាចរបស់ខ្លួនឲ្យសមតាមគន្លងប្រជាធិបតេយ្យ ដែលរដ្ឋធម្មនុញ្ញបានប្រគល់អំណាចឲ្យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្លាយជាស្ថាប័នចាំតែប្រថាប់ត្រា ឬសម្រួលកិច្ចការជាប្រយោជន៍នយោបាយ ជូនដល់រាជរដ្ឋាភិបាលកម្ពុជាទៀតផង។ ហើយមានភស្តុជាច្រើនដែលបញ្ជាក់ថាការពិនិត្យ និងការអនុម័តភាគច្រើនដោយ

មិនឆ្លងកាត់ការស្វែងយល់ថាស្របនឹងឆន្ទៈដែររឺទេ។ រដ្ឋសភាមិនបានបំពេញភារៈកិច្ចរបស់ខ្លួនប្រកបដោយអត្ថន័យឡើយ ក្នុងនោះមានកិច្ចការតាមដានត្រួតពិនិត្យសកម្មភាពការងាររបស់រាជរដ្ឋាភិបាលជាដើម។ រដ្ឋធម្មនុញ្ញកម្ពុជា ផ្តល់អំណាចយ៉ាងទូលំទូលាយដល់រដ្ឋសភា និងអ្នកតំណាងរាស្ត្រ។ ប៉ុន្តែបទបញ្ជាផ្ទៃក្នុងរដ្ឋសភាទៅវិញទេ ដែលជាចំណែកមួយនៃបញ្ហារាំងតំណាងរាស្ត្រ មិនឲ្យបំពេញការងារពេញលេញតាមលំនាំសង្គមប្រជាធិបតេយ្យនោះឡើយ។ ឧទាហរណ៍ បទបញ្ជាផ្ទៃក្នុងបានផ្តល់អំណាចច្រើនហួសដល់ប្រធានរដ្ឋសភា រហូតមានឆន្ទានុសិទ្ធិហាមប្រាមមិនឲ្យតំណាងរាស្ត្រសួរដេញដោលមន្ត្រីរដ្ឋាភិបាល នៅពេលពួកគេទៅឆ្លើយបំភ្លឺនៅក្នុងរដ្ឋសភា អំពីបញ្ហាជាតិម្តងៗ។ ប្រការ៣២ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភាបច្ចុប្បន្ន ចែងថាប្រធានរដ្ឋសភាអាចអនុញ្ញាត ឬមិនអនុញ្ញាតឲ្យមានការសួរដេញដោលទេ។ ប្រសិនបើមិនអនុញ្ញាតទេនោះ ចម្លើយរបស់នាយករដ្ឋមន្ត្រី ឬរដ្ឋមន្ត្រី គឺជាការបិទបញ្ចប់នៃសវនាការឆ្លើយបំភ្លឺនៅក្នុងរដ្ឋសភា។ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាឆ្នាំ ២០១៨ បានធ្វើការឲ្យតួនាទីរបស់ព្រឹទ្ធសភាកាន់តែ ទូលំទូលាយ ឡើងថែមទៀត ក្នុងតួនាទីជាតំណាងក្រុមប្រឹក្សាឃុំ-សង្កាត់ទូទាំងប្រទេសដែលកំពុងអនុវត្តនូវ គោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ។ បច្ចុប្បន្ននេះការអភិវឌ្ឍន៍ស្ថាប័នកាន់តែមានសារៈសំខាន់ ប៉ុន្តែនៅមានបញ្ហាមួយចំនួនក្នុងការអនុវត្តន៍ភារៈកិច្ចរបស់ខ្លួនដោយសារតែ ការពិនិត្យអត្ថបទច្បាប់ សេចក្តីព្រាងច្បាប់ភាគច្រើន គឺជាគំនិតផ្តួចផ្តើមរបស់នីតិប្រតិបត្តិដូចជា ប្រទេសប្រកាន់ លិទ្ធប្រជាធិបតេយ្យផ្សេងទៀតដែរ ពុំទាន់មានធនធាន និងស្តង់ដារ គ្រប់គ្រាន់ក្នុង ដំណើរការ នីតិវិធី។ ធនធានដែលគណៈកម្មការជំនាញអាចប្រើបាននៅមានកម្រិត ទាំងផ្នែកស្រាវជ្រាវឯកសារ និងការផ្តល់យោបល់បច្ចេកទេស។ ការងារវិមជ្ឈការវិសហមជ្ឈការដែលរដ្ឋបានអនុវត្តតាំងពីឆ្នាំ ២០០២ កំពុងប្រព្រឹត្តបន្តទន្ទឹមនឹងការបន្ត កសាងច្បាប់ និងបទដ្ឋានចាំបាច់នានា។ វេទិកាពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ សង្គមស៊ីវិលនិងអង្គការក្រៅរដ្ឋាភិបាលពុំទាន់បានរៀបចំជា ប្រព័ន្ធនៅឡើយ។ ក្នុងឋានៈជាស្ថាប័នដែលមានតួនាទីតាមដានការងាររបស់រាជរដ្ឋាភិបាល សមាជិកព្រឹទ្ធសភាមានតួនាទីច្រើន ពាក់ព័ន្ធជាចម្បងទៅនឹងបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋ នៅតាមមូលដ្ឋាននានា ដែលត្រូវឆ្លើយឆ្លងគ្នាជាមួយរាជរដ្ឋាភិបាល និងត្រូវចុះពិនិត្យស្រាវជ្រាវជាក់ស្តែង។ ប៉ុន្តែដោយសារការពិនិត្យអត្ថបទច្បាប់ជាបន្ទុកធ្ងន់ធ្ងរគណៈកម្មការជំនាញមិនអាច ចំណាយ ពេលបានច្រើនឡើយ។ ច្បាប់មួយចំនួនដែលបានអនុម័តមិនទាន់បានអនុវត្តទាំងស្រុងដោយសារផ្សព្វផ្សាយ ច្បាប់នោះនៅមានកម្រិត ហើយការកសាង

លិខិតបទដ្ឋាន បន្ថែមដើម្បីអនុវត្ត ច្បាប់របស់រាជរដ្ឋាភិបាលពុំបានធ្វើទាន់ពេលវេលា។ ក្នុងឋានៈជាតំណាងរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់សមាជិកព្រឹទ្ធសភាខ្វះធនធាន និងមធ្យោបាយធ្វើដំណើរទៅកាន់ភូមិភាគ ដើម្បីផ្សព្វផ្សាយពីសកម្មភាព និងផ្សារភ្ជាប់ទំនាក់ទំនង ជាមួយថ្នាក់មូលដ្ឋានឆ្លើយតមតាមការរំពឹងទុករបស់សាធារណជន។ ក្នុងបរិបទនេះ ព្រឹទ្ធសភាត្រូវតែអភិវឌ្ឍការិយាល័យព្រឹទ្ធសភា តាមភូមិភាគ។ គោលបំណងចម្បងនៃការ រៀបចំនោះគឺដើម្បីតាមដានការវិវត្តក្នុងក្របខ័ណ្ឌឃុំ ឬសង្កាត់ និងទទួលពាក្យបណ្តឹងពីពលរដ្ឋនៅតាម ភូមិភាគទាំងនោះ ដែលត្រូវបញ្ជូនមកព្រឹទ្ធសភាដោយផ្ទាល់ ដើម្បីមាន វិធាន ការតាមនីតិវិធី។

### ៦.២. នីតិប្រតិបត្តិ

រដ្ឋាភិបាលនៅតែមានការរំលោភសិទ្ធិមនុស្សជាបន្ត មានអាទិភាពច្រើនតែខ្វះចំណុចប្រមូលផ្តុំមានវប្បធម៌នៃដំណើរគ្មានទោស (និទណ្ឌភាព) មានការកម្រិតពេលវេលាខ្លី ដើម្បីធ្វើការផ្លាស់ប្តូរធំៗ បរិយាកាសបណ្តុះបណ្តាលបុគ្គលិកនិយម ស្ថាប័នរដ្ឋនៅខ្សោយ កង្វះធនធានមនុស្ស កំហិតថវិកា ខ្សោះប្រាជ្ញា កង្វះការគោរពច្បាប់ កង្វះការត្រួតពិនិត្យ និងការវាយតម្លៃ កង្វះប្រឹក្សាយោបលជាមួយប្រជាពលរដ្ឋ និងការគិតសម្រាប់រយៈពេលវែង កង្វះការស្តាបនាសមត្ថភាព កង្វះសមត្ថភាពនយោបាយ កង្វះនីតិរដ្ឋ ពុករលួយ កង្វះអព្យាក្រឹត្យ មានកម្មវិធីអំពីសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យតិច ប្រើប្រាស់អំណាចរំលោភរដ្ឋធម្មនុញ្ញ។[58]

### ៦.៣. តុលាការ

គោលការណ៍គ្រឹះប្រទេសមួយដែលមានលទ្ធិប្រជាធិបតេយ្យពិតប្រាកដ ប្រទេសនោះត្រូវមានច្បាប់គ្រប់គ្រាន់សម្រាប់ធ្វើការដឹកនាំគ្រប់គ្រង មានការអនុវត្តន៍ច្បាប់យ៉ាងត្រឹមត្រូវធានាបាននូវ សិទ្ធិសេរីភាពផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ ធានានូវយុត្តិធម៌ និងភាពសុខដុមរមនារបស់សង្គម។ ដោយឡែកប្រទេសកម្ពុជារបស់យើង ដើម្បីទទួលបាននូវលក្ខណៈគ្រឹះនៃលទ្ធិនេះក៏ត្រូវតែមានច្បាប់គ្រប់គ្រាន់មានការអនុវត្តន៍ត្រឹមត្រូវ និងប្រកបទៅដោយភាពយុត្តិធម៌ផងដែរ។ បច្ចុប្បន្នប្រទេសយើងមានច្បាប់ដែលសភាជាតិជាអ្នកអនុម័ត ហើយក៏មាននូវអង្គការតុលាការផងដែរសម្រាប់ដោះស្រាយរឿងក្តី គ្រាន់តែថាវាមិនទាន់ឆ្លើយតបទៅនឹង តម្រូវការរបស់សង្គមជាតិតែប៉ុណ្ណោះ ដោយហេតុថានៅតាមតុលាការនៅមានចំណុចខ្វះខាត ដែលត្រូវបំពេញ

[58] អ៊ុំ សុភក្តិ.ហេង ឌី.អែល យុន. លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅកម្ពុជា.ឆ្នាំ២០០៦.ទំព័រទី៥៩-៦០

ឲ្យគ្រប់លក្ខណៈនៃនីត្យានុកូលភាពច្បាប់ ដូចជា ពុំទាន់មានច្បាប់គ្រប់គ្រាន់ដើម្បីឲ្យចៅក្រមព្រះរាជអាជ្ញាក្នុងការអនុវត្តន៍កាត់សេចក្តីរឿងក្តី។ តុលាការខ្វះខាតសាលាជម្រះក្តីតាមផ្នែកនៃរឿងវិវាទតុលាការខ្វះខាតអាជ្ញាសាលាដើម្បីទទួលអនុវត្តកិច្ចការចាំបាច់របស់តុលាការ ខ្វះខាតចៅក្រម ព្រះរាជ្ញាដែលមាននូវធនធានពេញលេញ។ ចំណេះដឹងរបស់ចៅក្រមពេលបច្ចុប្បន្ននេះមានកម្រិតនៅឡើយ ដែលជាហេតុនាំឲ្យ មានការអនុវត្តន៍ច្បាប់នៅមានភាពធូរលុងពុំបានសូវល្អឥតខ្ចោះដូចនៅតាមបណ្តាប្រទេសជឿនលឿននៅលើសកលលោកនៅឡើយ។ ចំណែកសាលាជម្រះក្តីនៅតាមបណ្តាខេត្តមួយចំនួនសព្វថ្ងៃ បានជួបនូវផលវិបាកមួយចំនួនលើធនធានមនុស្សដែរសម្រាប់ដំណើរការក៏ដូចជាកង្វះខាត ចៅក្រម ហើយនិងខ្វះខាតខាងសមត្ថភាពធ្វើការរបស់បុគ្គលិករដ្ឋបាលដែលមានតែបរិមាណតែខ្វះគុណភាព។ មន្ត្រីមួយចំនួនធ្វើការទៅតាមទម្លាប់ពុំមានការបណ្តុះបណ្តាលឲ្យបានត្រឹមត្រូវ ជាមួយនេះដែរភាពមិនពេញលេញទាំងសម្ភារៈប្រើប្រាស់មធ្យោបាយផ្សេងៗ ក្នុងការជម្រះក្តីក៏ដូចជាការអនុវត្តន៍សាលដីកា សំណុំរឿងមួយចំនួននៅកក់ស្ទះបណ្តាលមកពីបញ្ហាគូភាគីនៃរឿងក្តីមិនបង្ហាញមុខពេលសវនាការ។ ចំណែកតុលាការជាន់ខ្ពស់ (តុលាការកំពូល) តុលាការនេះគឺជាស្ថាប័នកំពូលមួយដែលខ្លួនសម្រេចបិទផ្លូវតវ៉ា គឺគ្មានប្តឹងតទៅទៀតទេដូច្នេះចៅក្រមតុលាការកំពូលជាចៅក្រមរៀមច្បង ដែលមានសមត្ថភាពចំណេះដឹងច្បាប់ខ្ពង់ខ្ពស់។ ចៅក្រមសម្រាប់ តុលាការកំពូលគួរតែជ្រើសរើសចៅក្រមដែលមានវ័យចំណាស់មានចំណេះដឹងគ្រប់គ្រាន់ មានបទពិសោធន៍ក្នុងការជម្រះក្តីមានភាពយុត្តិធម៌ពិតៗ ដែលជាគម្រូល្អដល់ចៅក្រមផ្សេងៗទៀត សម្រាប់អនុវត្តតាម។ បើពិនិត្យជារួម យើងអាចមើលឃើញថា ផ្លូវទៅកាន់នីតិរដ្ឋរបស់កម្ពុជា នៅមានឧបសគ្គច្រើននៅឡើយ ដែលត្រូវបន្តដោះស្រាយជាចាំបាច់ ដូចជា ត្រូវផ្លាស់ប្តូរទាំងផ្នត់គំនិតចាស់ របៀបដឹកនាំ និងគ្រប់គ្រងដែលមិនទាន់ល្អ ផ្តាច់អំណាចសំខាន់ៗឲ្យឯករាជ្យពីគ្នា កែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងឲ្យមានយុត្តាធិការច្បាសលាស់ លុបបំបាត់គ្រួសារនិយម បក្សពួកនិយម និង ត្រូវលុបបំបាត់អំពើពុករលួយជាដើម។ បើមិនដូច្នោះទេ យើងមិនអាចសម្រេចនីតិរដ្ឋបានឡើយ។ ប្រសិនបើ នីតិរដ្ឋមិនមានអត្ថិភាពពេញលេញក្នុងសង្គមខ្មែរ មានន័យថា អំពើអយុត្តិធម៌ ទំនាស់ផលប្រយោជន៍ និទណ្ឌភាព ការធ្វើអ្វីៗតាមទំនើងចិត្ត អំពើពុករលួយអសន្តិសុខ និងការភ័យខ្លាចនៅតែបន្តកើតមានក្នុងសង្គមខ្មែរ។ លើសពីនេះទៀតមានករណីជាច្រើន ដែលតុលាការកម្ពុជា ត្រូវបានគេលើកឡើងថា បានចាត់វិធានការផ្លូវច្បាប់លើជនសង្ស័យ តែនៅពេលណាដែលមានប្រតិកម្ម ឬការបញ្ជាពីនាយករដ្ឋមន្ត្រីតែប៉ុណ្ណោះ ដូចជា

ករណី ឧកញ៉ា ថោង សារ៉ាត, ឧកញ៉ា សុខ ប៊ុន, លោក ឈូក បណ្ឌិត និង លោក ហុង សុខហួរជាដើម។ ក្រៅពីនេះ រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ ដែលមិនបានបែងចែកយុត្តាធិការ ឬសមត្ថកិច្ចច្បាប់លាស់ ឬមានចេតនាធ្វើឲ្យស្ថាប័ននានា ស្ថិតនៅក្រោមអំណាចនីតិប្បញ្ញត្តិ អំណាចបក្ស ឬអំណាចបុគ្គល រួមទាំងឥទ្ធិពលនៃអំពើពុករលួយ និងអំណាចផ្តាច់ការ ក៏សុទ្ធតែជាឧបសគ្គធំៗដែលរារាំងមិនឲ្យកម្ពុជាឆ្ពោះទៅរកនីតិរដ្ឋបានដែរ។ ជាលទ្ធផល យើងបានពិនិត្យឃើញថា មានករណីខ្លះ អង្គហេតុ និងអង្គច្បាប់តែមួយ ប៉ុន្តែមានការបកស្រាយខុសគ្នាដោយ អ្នកនយោបាយ អ្នកវិភាគឯករាជ្យ អ្នកច្បាប់របស់សង្គមស៊ីវិល អ្នកច្បាប់របស់បក្សនយោបាយ អ្នកច្បាប់របស់សមាគមមេធាវី សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា និងក្រុមប្រឹក្សាធម្មនុញ្ញ។ ជាក់ស្តែង កន្លងមក ធ្លាប់មានការស្នើសុំឲ្យបកស្រាយផ្សេងៗទៀត ពាក់ព័ន្ធនឹងច្បាប់បោះឆ្នោត ច្បាប់ព្រហ្មទណ្ឌ។ ចំពោះអង្គហេតុតែមួយ ក៏មានការបកស្រាយខុសគ្នាដែរ ដូចជា ករណី លោក ឈូក បណ្ឌិត មតិផ្សេងៗថាមានទោសធ្ងន់ តែតុលការដាក់ទោសស្រាល រីឯលោក ហុង សុខហួរ មតិខ្លះថា ត្រូវឲ្យសុំទោសជាថ្នូរនឹងកំហុសរបស់ខ្លួន តែតុលាការបានឃុំខ្លួនរង់ចាំចោទប្រកាន់ ចំណែកលោក ជា តារា ដែលថ្លែងថាកងខេមរភូមិន្ទគឺជារបស់បក្សប្រជាជនកម្ពុជា មតិខ្លះថាខុសច្បាប់ មតិខ្លះថាមិនខុសច្បាប់ទេ ចំណែកឯ ករណី យុវជន កូកូ ដែលទាក់ទងនឹងបដិវត្តពណ៌ អ្នកខ្លះថាជាការបញ្ចេញមតិ តែរដ្ឋាភិបាលថា ទោសព្រហ្មទណ្ឌ និងករណីការបង្ក្រាបបាតុកម្ម ឬកុបកម្មនៅផ្លូវវែងស្រែង ដោយកម្លាំងរដ្ឋាភិបាល ក៏មានការបកស្រាយខុសគ្នាដែរ។ ទីបំផុត ភាគីរដ្ឋាភិបាល គឺជាភាគីមានប្រៀបលើការបកស្រាយស្ទើរតែគ្រប់ករណីទាំងអស់។

## ៧. ភាពខ្សោយរបស់អង្គការក្រៅរដ្ឋាភិបាល ឬសង្គមស៊ីវិល

ចំណុចខ្សោយរបស់អង្គការពុំមែនរដ្ឋាភិបាលរួមមាន៖ កង្វះការយល់ដឹងត្រឹមត្រូវអំពីសេចក្តីត្រូវការ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋមានមោទនភាពហួសពេក មានអង្គការ (NGOs) ខ្លាំៗតិចតួច មានកម្មវិធីរបស់ (NGOs) ទៅមូលដ្ឋានជនបទតិចតួច ពឹងផ្អែកតែលើម្ចាស់អំណោយ កង្វះភាពជាប់លាប់ប្រកួតប្រជែងគ្នាអំពីបញ្ហា ថវិកា កង្វះសហប្រតិបត្តិរវាង (NGOs) គ្នាឯង ជូនដើរតួជាបក្សប្រឆាំង កង្វះផែនការ និង ការគិតគូរយូរអង្វែងពុំសូវមានឥទ្ធិពល ការបោះពុម្ពផ្សាយ និងការផ្សព្វផ្សាយព័ត៌មានពុំបានទូលំទូលាយដល់ មូលដ្ឋានជនបទ។[59] ពង្រាងច្បាប់ (NGOs)

[59] អ៊ុំ សុភក្ក៏.ហេង ឪ.អែល យុន. លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅកម្ពុជា.ឆ្នាំ២០០៦.ទំព័រទី៥៨

កង្វះសហប្រតិបត្តិការពីអាជ្ញាធរមូលដ្ឋាន កង្វះការយល់ដឹងអំពីតួនាទី និងការទទួលខុសត្រូវរបស់អង្គការ (NGOs) កង្វះមូលនិធិ កង្វះសមត្ថភាព ព័ត៌មាន និងវិជ្ជាជីវៈជំនាញ កង្វះសហប្រតិបត្តិការពីរដ្ឋាភិបាល កង្វះការជឿទុកចិត្តពីប្រជាពលរដ្ឋ កង្វះឯកភាព ការបំបែកបំបាក់អង្គការ (NGOs) ជាឧបករណ៍សម្រាប់ផលប្រយោជន៍នយោបាយ និងសេដ្ឋកិច្ច។[60]

## ៨. ប្រជាពលរដ្ឋ

កន្លងមកនេះ ប្រជាពលរដ្ឋ និងអ្នកតាមដានស្ថានការណ៍នយោបាយ និងលទ្ធិប្រជាធិបតេយ្យមួយចំនួន តែងប្រួតគ្នាស្តីបន្ទោស និងរិះគន់អ្នកនយោបាយគ្រប់ៗគ្នា នៅពេលដែលពួកគេសង្កេតឃើញអ្នកនយោបាយខ្មែរខ្លះ មានចរិតអត្មានិយម ពុករលួយ ភូតកុហកប្រជាពលរដ្ឋ ដើម្បីបំពេញសេចក្តីស្រេកឃ្លានផ្នែកនយោបាយរបស់ខ្លួន និងធ្វើឲ្យប៉ះពាល់ទៅដល់លទ្ធិប្រជាធិតេយ្យ។ ក៏ប៉ុន្តែ អ្នករិះគន់ទាំងនោះភ្លេចគិតថា ហេតុផលដែលនៅកម្ពុជាសម្បូរអ្នកនយោបាយប្រភេទនេះ ក៏មានកំហុសរបស់ពលរដ្ឋដែលជាម្ចាស់ទឹកដីរួមផ្សំផងដែរ។ កំហុសដែលគួរស្តីបន្ទោសពលរដ្ឋទាំងនោះ មានដូចជាឥរិយាបថមិនខ្វល់នឹងរឿងនយោបាយរបស់ពលរដ្ឋដែលជាម្ចាស់ឆ្នោត បណ្តែតបណ្តោយឲ្យអ្នកនយោបាយឱកាសនិយមបោកបញ្ឆោតខ្លួនម្តងហើយម្តងទៀត។ ប្រជាពលរដ្ឋដែលម្ចាស់ឆ្នោត មិនបាននាំគ្នាតាមដានសកម្មភាពរបស់អ្នកនយោបាយទាំងនោះឡើយ ដោយពួកគេម្នាក់ៗគិតតែរឿងផ្ទាល់ខ្លួនតែប៉ុណ្ណោះ។ ប្រជាពលរដ្ឋខ្លះនិយាយថា រឿងនយោបាយ ឬរឿងស្រុកទេស ទុកឲ្យអ្នកនយោបាយ ឬអ្នកដឹកនាំ គេធ្វើទៅបានហើយ តែយើងជាពលរដ្ឋមិនចាំបាច់រវល់នោះទេ គឺគិតតែរឿងការងាររកស៊ីចិញ្ចឹមជីវិតរៀងៗខ្លួនទៅបានហើយ។ ផ្នត់គំនិតរបស់ពលរដ្ឋបែបនេះហើយបានជាធ្វើឲ្យ អ្នកនយោបាយបង្កបញ្ហាសម្រាប់ជាតិមួយចំនួន សំងំពួនជ្រកក្នុងវិថីនយោបាយដោយសប្បាយចិត្តបំប៉នមហិច្ឆតាអាក្រក់របស់ខ្លួន បំផ្លាញប្រទេសជាតិយ៉ាងរីករាយ។ ពេលនោះអ្នកនយោបាយបោកពលរដ្ឋ ពួកគេមិនត្រឹមតែជិះសេះលែងដៃទេគឺថែមទាំងរាំក្បាច់រាំសារាវ៉ាន់និងរាំស្លូទៀតផង។

មួយវិញទៀត ដោយសារផ្នត់គំនិតគាំទ្រទាំងបិទភ្នែករបស់ម្ចាស់ឆ្នោត។ ពលរដ្ឋខ្លះ នៅពេលដែលពួកគេ គាំទ្រគណបក្ស ឬអ្នកនយោបាយណាមួយហើយ គឺរាល់សកម្មភាពរបស់បក្ស ឬអ្នកនយោបាយនោះ ពួកគេតែងគិតថា ត្រឹមត្រូវជានិច្ច បើទោះជាសកម្មភាពនោះខុស ផ្ទុយពីច្បាប់ ពុករលួយ គ្រួសារនិយម និងប៉ះពាល់ដល់ផលប្រយោជន៍ជាតិ ឬប្រជាជនខ្មែរដទៃទៀតក៏

[60] អ៊ុំ សុភក្តិ.ហេង ឌី.អែល យុន. លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅកម្ពុជា.ឆ្នាំ២០០៦.ទំព័រទី៥៨-៥៩

ដោយ។ ពលរដ្ឋទាំងនោះ នៅតែខំប្រឹងការពារទង្វើអាក្រក់របស់បក្ស និងអ្នកនយោបាយទាំងនោះដែរ ពីព្រោះថាបក្ស ឬអ្នកនយោបាយនោះ ជាមនុស្សដែលខ្លួនស្រឡាញ់ខ្លាំងបំផុត បើទោះបីជាពេលខ្លះដឹងថា ខ្លួនត្រូវអ្នកនយោបាយនោះបោកប្រាស់ក៏ដោយ។ ដូច្នេះវាជាសត្យានុម័តហើយថា បើខ្មែរមានពលរដ្ឋធ្វើបែបនេះ ខ្មែរក៏ត្រូវតែមានអ្នកនយោបាយបោកពលរដ្ឋបែបនេះដែរ។ ហើយពលរដ្ឋ ក៏មានកំហុសនៅក្នុងរឿងនេះផងដែរ។ ម្យ៉ាងវិញទៀត ពលរដ្ឋដែលពុំយល់ដឹងពីខ្លួនឯងថាមានតួនាទីយ៉ាងណានៅក្នុងការរួមចំណែកដើម្បីស្ថាបនាប្រទេស ធ្វើឲ្យគេមិនអើពើចំពោះកិច្ចការងារទាំងឡាយ ដើម្បីស្ថាបនាសេចក្តីសុខឲ្យខ្លួន សហាគមន៍ខ្លួន និងសង្គមខ្លួននោះទេ តែបែរជាគាំទ្ររស់នៅក្រោមការគាបសង្កត់កេងយកកម្លាំងពលកម្ម និងភាពលំបាកវេទនា មិនចេះរើបម្រះ។

# សេចក្តីសន្និដ្ឋាន

ឆ្លងកាត់ការស្រាវជ្រាវ និងការវិភាគជាច្រើនតាមរយៈឯកសារនានាយើងសង្កេតឃើញថា លទ្ធិប្រជាធិបតេយ្យគឺជាទម្រង់នៃការដឹកនាំមួយដែលបានចាត់ទុកប្រជាពលរដ្ឋជាធំ ប្រជាពលរដ្ឋជាម្ចាស់ប្រទេស។ ទ្រឹស្តីសកលលោកបានទទួលស្គាល់ថាប្រជាពលរដ្ឋមានសិទ្ធិក្នុងការសម្រេចជោគវាសនាប្រទេសជាតិតាមរយៈការបោះឆ្នោតឲ្យតំណាងរបស់ខ្លួន។ តំណាងដែលឈ្នះក្នុងលទ្ធផលបោះឆ្នោតត្រូវបង្កើតរដ្ឋាភិបាលដើម្បីបម្រើរាស្ត្រ ហើយប្រជាពលរដ្ឋមានសិទ្ធិទម្លាក់នាយករដ្ឋមន្ត្រីតាមរយៈ ការបោះឆ្នោត ប្រសិនបើរដ្ឋាភិបាលនោះមិនបានបំពេញនូវកាតព្វកិច្ចរបស់ខ្លួនបានល្អនោះទេ។ ប្រជាពលរដ្ឋនៅក្នុងប្រទេសប្រជាធិបតេយ្យមានសិទ្ធិសេរីភាពពេញលេញក្នុងការបញ្ចេញមតិ សេរីភាពទទួលបានភាពយុត្តិធម៌ សេរីភាពក្នុងការផ្សព្វផ្សាយ និងទទួលបានព័ត៌មាន។ ការដឹកនាំបែបប្រជាធិបតេយ្យត្រូវមាន រដ្ឋធម្មនុញ្ញមួយដែលស្របទៅតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យដែលជាទ្រឹស្តីពិភពលោក ហើយការបង្កើតច្បាប់ក៏ត្រូវតែស្របទៅតាមរដ្ឋធម្មនុញ្ញផងដែរ។ ចំណែកឯប្រទេសកម្ពុជាវិញគឺជាប្រទេសមួយដែលបានឆ្លងកាត់នូវសង្គ្រាមអស់ជាច្រើនទសវត្សរ៍ រីឯរបបនយោបាយវិញបានផ្លាស់ប្តូរពីមួយសម័យកាលទៅមួយសម័យកាល ហើយលទ្ធិប្រជាធិបតេយ្យនេះ បានឆ្លងកាត់នូវភាពលំបាកវេទនារហូតដល់មានវីរៈជនជាច្រើនបានបូជាជីវិតដើម្បីលទ្ធិមួយនេះ។ រហូតមកដល់ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ កម្ពុជាបានចុះកិច្ចព្រមព្រៀងនៅទីក្រុងប៉ារីសដើម្បីបញ្ចប់ជម្លោះ និងបានបង្កើតរដ្ឋធម្មនុញ្ញមួយនៅឆ្នាំ១៩៩៣ ដែលប្រកាន់យករបបប្រជាធិបតេយ្យសេរីពហុបក្ស។ ជាក់ស្តែងនៅក្នុងជំពូកទី៤ មាត្រា៥១ នៃរដ្ឋធម្មនុញ្ញបានចែងថា ព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស។ ប្រជាពលរដ្ឋជាម្ចាស់វាសនាប្រទេសជាតិរបស់ខ្លួន។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈ រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជម្រះក្តី។ អំណាចបែងចែកដាច់ពីគ្នារវាងអំណាច នីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងអំណាចតុលាការ។ ក្រោយបង្កើតរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ប្រទេសកម្ពុជាបានធ្វើការបោះឆ្នោតជាលើកដំបូងដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិ។ បន្ទាប់មកកម្ពុជាបានរៀបចំការបោះ

ឆ្នោតដោយខ្លួនឯងនៅឆ្នាំង១៩៩៨ រហូតមកដល់បច្ចុប្បន្ននេះកម្ពុជាបានធ្វើការបោះឆ្នោតចំនួន៥លើកមកហើយ ដែលមានការចូលរួមពីគណបក្សជាច្រើន និងមានអាណត្តិ៥ឆ្នាំម្តង់។ កម្ពុជាបានបង្កើតនូវស្ថាប័នជាច្រើនដែលធានាដល់ដំណើរការនៃលទ្ធិប្រជាធិបតេយ្យដូចជា ស្ថាប័ននីតិប្បញ្ញត្តិ នីតិប្រតិបត្តិ តុលាការ ក្រុមប្រឹក្សារដ្ឋម្មនុញ្ញ គណកម្មការជាតិរៀបចំការបោះឆ្នោត គណបក្សនយោបាយ ស្ថាប័នព័ត៌មាន និងអង្គការសង្គមស៊ីវិលជាដើម។ លើសពីនេះទៅទៀតកម្ពុជារៀបចំការប្រព្រឹត្តិទៅនៃដំណើរការជាច្រើននៅក្នុងប្រទេសឲ្យមានលក្ខណៈប្រជាធិបតេយ្យ ជាក់ស្តែងកម្ពុជាបានប្រកាន់យក ដំណើរការសេដ្ឋកិច្ចទីផ្សារសេរីដែលបើកឲ្យប្រជាពលរដ្ឋមានការប្រកួតប្រជែងគ្នា រីឯវប្បធម៌វិញកម្ពុជាមិនបានអភិរក្សណាស់ណានោះទេ គឺទទួលយកនូវវប្បធម៌បរទេសណាដែលយល់ឃើញថាល្អ។ បើនិយាយពីសាសនាវិញបើទោះបីជាជំពូកទី៣ មាត្រា៤៣នៃរដ្ឋធម្មនុញ្ញបានចែងថាពុទ្ធសាសនាជាសាសនារបស់រដ្ឋក៏ដោយ ក៏កម្ពុជាបានបើកសិទ្ធិឲ្យប្រជាពលរដ្ឋជ្រើសរើសយកសាសនាណាដែលខ្លួនពេញចិត្ត និងមានជំនឿ។ បើនិយាយពីការដឹកនាំរបស់ស្ថាប័ននីមួយៗមានចំណុចខ្លាំង និងចំណុចខ្សោយជាច្រើនគួរឲ្យកត់សម្គាល់ ជាពិសេសប្រព័ន្ធនៃការបែងចែកអំណាចរបស់ស្ថាប័នទាំងបី ហាក់ដូចជានៅមិនទាន់ឯករាជ្យពីគ្នានោះទេ។ ចំណែកការចូលរួមរបស់ប្រជាពលរដ្ឋវិញនៅមានកម្រិតទាំងបរិមាណ និងចំណេះដឹងដោយពួកមិនបានយល់ច្បាស់ពីបុព្វសិទ្ធិ និងករណីយកិច្ចរបស់ពួកគេឡើយ។ ដូចនេះក្នុងនាមយើងជាប្រជាពលរដ្ឋត្រូវតែចូលរួមយ៉ាងសកម្មនៅក្នុងជីវភាពនយោបាយ ហើយការចូលរួមនោះត្រូវតែប្រកបទៅដោយចំណេះដឹង ដើម្បីឲ្យប្រទេសមួយនេះមានភាពរីកចម្រើនប្រកបដោយប្រជាធិបតេយ្យ មាននីតិរដ្ឋ សន្តិភាព ស្ថេរភាព ប្រជាពលរដ្ឋរស់នៅដោយសុខុមាលភាព ពេលនោះប្រទេសយើងនឹងក្លាយជាប្រទេសមួយដែលមានកិត្យានុភាព ឧដុង្គឧត្តម ក្នុងសកលលោក។

# អនុសាសន៍

បន្ទាប់ពីបានធ្វើការស្រាវជ្រាវក្នុងប្រធានបទមួយនេះរួចមក ក្រុមយើងខ្ញុំសូមផ្តល់នូវ អនុសាសន៍មួយចំនួន ដើម្បីជាការពង្រឹងប្រសិទ្ធិភាព ព្រមទាំងកែតម្រូវចំណុចខ្វះខាតមួយចំនួន ដើម្បីឲ្យមានការរីកចម្រើន និងបង្កើនប្រសិទ្ធិភាពក្នុងការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យ នៅក្នុងប្រទេសកម្ពុជារបស់យើង។

**អនុសាសន៍នោះមានដូចជា៖**

- បង្កើតច្បាប់ស្តីពីលទ្ធិប្រជាធិបតេយ្យឲ្យបានពេញលេញបន្ថែមទៀត
- អនុវត្តធ្វើឲ្យច្បាប់ស្តីពីលទ្ធិប្រជាធិបតេយ្យ មានប្រសិទ្ធិភាពខ្ពស់
- លើកស្ទួយ នឹងការពារអង្គការ ដែលធានានូវការអនុវត្តន៍ប្រជាធិបតេយ្យ
- ត្រូវផ្សព្វផ្សាយឲ្យប្រជាពលរដ្ឋបានយល់ដឹង អំពីប្រជាធិបតេយ្យបានកាន់តែច្បាស់
- លើកកំពស់ឲ្យប្រជាពលរដ្ឋចូលរួមអនុវត្តប្រជាធិបតេយ្យ
- លុបបំបាត់ច្បាប់មួយចំនួនដែលជាឧបសគ្គក្នុងការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យ។

# ឯកសារយោង

## ១. ឯកសារច្បាប់អន្តរជាតិ

ក. សេចក្តីប្រកាសសកលស្តីពីសិទ្ធិមនុស្ស ថ្ងៃទី ១០ ខែធ្នូរ ឆ្នាំ១៩៤៨

ខ. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧៦

គ. កិច្ចព្រមព្រៀងទីក្រុងប៉ារីស ២៣ តុលា ១៩៩១

## ២. ឯកសារច្បាប់ជាតិ

ក. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

ខ. ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០០៧

គ. ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ២០១៧

ង. ច្បាប់ស្តីពីគណបក្សនយោបាយ១៩៩៨

## ៣.សៀវភៅសំខាន់ៗ

ក. ការ ដេវីដ សៀវភៅគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីនិយម រដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក ឆ្នាំ១៩៩៦

ខ. ក្រសួងឃោសនាសហរដ្ឋអាមេរិក អ្វីទៅដែលហៅថាលទ្ធិប្រជាធិបតេយ្យទីក្រុងវ៉ាស៊ិនតោនឌីស៊ី.ឆ្នាំ១៩៩១

គ. អ៊ឹង ជុនហួរ.សេរីភាព និងយុត្តិធម៌.ឆ្នាំ១៩៩៥

ង. ខុមហ្វ្រែល ជំនួយស្មារតីចំណេះដឹងពលរដ្ឋក្នុងអំឡុងពេលបោះឆ្នោត និងក្រោយពេល បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ២០០៣

ច. គឹម សុខា គៀត សុគន្ធ លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងពលរដ្ឋវិជ្ជា កម្ពុជា ឆ្នាំ ២០០៤

ឆ. ណុប បូផាន់ សៀវភៅលទ្ធិប្រជាធិបតេយ្យ ភ្នំពេញ ឆ្នាំ១៩៥៦

ញ. រៀបរៀងដោយ សាស្ត្រាចារ្យ ម៉ុក ដារ៉ា នីតិរដ្ឋធម្មនុញ្ញ ២០១៥-២០១៦

ដ. ទីស្តីការគណៈរដ្ឋមន្ត្រី សៀវភៅស ស្តីពីស្ថានការណ៍នយោបាយនៅកម្ពុជា (ការពង្រឹងនីតិរដ្ឋ និងដំណើរការលទ្ធិប្រជាធិបតេយ្យ) ភ្នំពេញ ឆ្នាំ២០១៨

ឋ. បណ្ឌិត ឈុន ណារ៉េត សេចក្តីផ្តើមវិទ្យាសាស្ត្រនយោបាយ ភ្នំពេញ ២០១២

ឌ. វិទ្យាស្ថានកម្ពុជាដើម្បីសិទ្ធិមនុស្សសហការជាមួយក្រសួនមហាផ្ទៃ អភិបាលកិច្ចល្អ និងគោលការណ៍ចាត់ចែង

ធ. ភិក្ខុធម្មបាល ខៀវ ជុំ ប្រជាធិបតេយ្យចាស់ទុំ ឆ្នាំ ១៩៧២

## ៤. ឯកសារជាការសែតទស្សនាវដ្តី

ក. ម៉ាហ្គារិត ស ស៊ូលីហែន ការិយាល័យព័ត៌មានប្រកបដោយការទទួលខុសត្រូវការិយាល័យកម្មវិធីព័ត៌មានអន្តរជាតិ នៃក្រសួងការបរទេសសហរដ្ឋអាមេរិក

ខ. ដោយ ដើមអំពិល ID:117 ព្រហស្បតិ៍, ២៨ ធ្នូ ២០១៧ 12:17

ង. ដោយ ជឹម ណារី សុន្ទរកថាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន កំពត ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៨

## ៥. ឯកសារបច្ចេកទេស

ក. អ៊ុំ សុភក្តិ.ហេង ឪ.អែល ឃុន. លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅកម្ពុជា ឆ្នាំ២០០៦